# សេចក្ដីសុខរបស់អ្នក



សុធម្មត្ថេរ ឈុន សុវណ្ណ

# សេចក្ដីសុខរបស់អ្នក



ដោយ


**អនុបណ្ឌិត សុធម្មត្ថេរ ឈុន សុវណ្ណ**

បរិញ្ញាបត្រ-អនុបណ្ឌិត (ស្រីលង្កា)

អតីតទីប្រឹក្សាពុទ្ធសាសនា និងជាសមាជិកគណៈកម្មការនិពន្ធ-បោះពុម្ពផ្សាយ

ទស្សនាវដ្ដី វ៉ាទូយ៏ នៃអង្គការពុទ្ធសាសនា (MWA) សិង្ហបូរី



បោះពុម្ពលើកទី ៣

បានកែសម្រួលជាថ្មី

ព.ស. ២៥៥៣ គ.ស. ២០១០

# [illegible]



ដោយ

[illegible]

( [illegible] ) [illegible]

[illegible]

[illegible] (AWM) [illegible]

[illegible]

[illegible]

[illegible]

ឈ្មោះសៀវភៅ : **សេចក្តីសុខរបស់អ្នក**

អ្នកនិពន្ធ : អនុបណ្ឌិត សុធម្មត្ថេរ **ឈុន សុវណ្ណ**

បោះពុម្ពលើកទី ១ : ពស. ២៥៤៧ គស. ២០០៤

បោះពុម្ពលើកទី ២ : ពស. ២៥៤៨ គស. ២០០៥

បោះពុម្ពលើកទី ៣ : ពស. ២៥៥៣ គស. ២០១០

រក្សាសិទ្ធិ : ដោយអ្នកនិពន្ធ

លេខ ISBN : 978-99963-527-1-3

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង

សៀវភៅនេះ គឺសំរាប់ចែកជូនជាធម្មទានតែប៉ុណ្ណោះ

***The Gift of Truth excels all other Gifts***

***This book is for free distribution only***

// Acknowledgements

The Third Revised Edition of this book, entitled " Your Happiness " in khmer was supported by Samdech, His Excellency, Venerables, and Lay devotees in Cambodia and from Singapore especially my teacher, **Most Ven. Shi Fa Zhao,** ***chief Abbot of GPBT*** and **Samayathy Kulasena and Sons**. I would like to express my heartfelt appreciation to the above mentioned supporters who donated money for the production of this Dhamma Dana- the Gift of Truth.
May the Blessing of the Triple Gem be with them always.

Special Transference of Merit that accrue from this Gift of Truth was done " in loving memory of late **Hetti Arachige Don Kulasena** by **Samayathy Kulasena** and **Sons**."
May he attain Nibbana,

Wat Takhmau,
k/m Takhmau,
S/k Takhmau
Kandal, Cambodia.
02. 02. 2010
Ven. **Chhun Sovann**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## អធិការពុទ្ធិកសិក្សា

សូមប្រគេន និង ចំរើនពរដល់អស់លោកពុទ្ធបរិស័ទទាំងឡាយ អ្នកអានសៀវភៅ "**សេចក្ដីសុខរបស់អ្នក**" ដែលជាស្នាដៃភិក្ខុ **ឈុន សុវណ្ណ** បានរៀបរៀងឡើង ដើម្បីបំរើផលប្រយោជន៍ជាតិ សាសនា ។ តាមយោបល់របស់ខ្ញុំ យល់ឃើញថា "**សៀវភៅសេចក្ដីសុខរបស់អ្នក**" នឹងបានជាផលប្រយោជន៍ច្រើន ក្នុងការប្រតិបត្តិតាមផ្លូវលោក និង ផ្លូវធម៌តរៀងទៅ ។

**ចិរំ តិដ្ឋតុ ពុទ្ធសាសនំ** សូមព្រះពុទ្ធសាសនាតាំងនៅបានយូរអង្វែងតទៅ ។

ភ្នំពេញ.ថ្ងៃទី......ខែ......ឆ្នាំ២០០៤

**អធិការពុទ្ធិកសិក្សា**

**នន្ទ ង៉ែត** បណ្ឌិតសភាចារ្យ

បានពិនិត្យរួចហើយ និងយល់ឃើញថា ខ្លឹមសារក្នុងសៀវភៅនេះ

មានលក្ខណៈល្អប្រពៃជាគុណប្រយោជន៍ដល់ពុទ្ធបរិស័ទគ្រប់ជាន់

ថ្នាក់ ។

រាជធានីភ្នំពេញ ថ្ងៃ ២កើត ខែបុស្ស ព.ស ២៥៤៧ ត្រូវនឹង

ថ្ងៃទី ២៤ ខែ ធ្នូ គ.ស ២០០៣

អ្នកពិនិត្យ

Kresn

សាស្ត្រាចារ្យ ជា គ្រិស្នា

# មាតិកា


ឈ្មោះអត្ថបទ ទំព័រ

-សេចក្តីយល់ឃើញរបស់ សម្តេចព្រះពោធិវង្ស នន្ទ ង៉ែត

- សេចក្តីយល់ឃើញរបស់ សាស្ត្រាចារ្យ ជា ក្រិស្នា

-បុព្វកថា ....................................................................................i

-ទំព័រពិសេស ..............................................................................vi

-ជីវប្បវត្តិសង្ខេបនៃព្រះសម្ពុទ្ធ-ទ្រង់ប្រសូត.......................................01

-សិទ្ធត្ថរាជកុមារ...........................................................................06

-ការយាងចេញសាងផ្នួសរបស់ព្រះសិទ្ធត្ថ.........................................10

-ការស្វែងរកនូវសម្មាសម្ពោធិញ្ញាណ................................................13

-ការបានត្រាស់ដឹង........................................................................17

-៤៥ព្រះវស្សានៃជីវិតសម្មាសម្ពោធិញ្ញាណ.........................................20

-ពុទ្ធនិវាសនដ្ឋាន...........................................................................23

-ការយាងចូលព្រះនិព្វាន.................................................................25

-បញ្ញត្តិសព្ទ "សុខ" ..................................................................... 29

-គោលបំណងព្រះពុទ្ធសាសនា.......................................................32

-តើសេចក្តីសុខអាស្រ័យនៅលើចំនួននៃទ្រព្យសម្បត្តិឬ?...................36

-ឧបសគ្គនៃសេចក្តីសុខ..................................................................40

-សារៈសំខាន់នៃសេដ្ឋកិច្ច...............................................................42

-តើយើងមានសេចក្តីសុខទេ?..............................................................................44
-ភាពក្រីក្រជាឫសគល់នៃសេចក្តីទុក្ខក្នុងលោក...........................................................48
-ការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ.......................................................................................54
-ហេតុដែលនាំមកនូវសេចក្តីវិនាស-អបាយមុខ............................................................59
-ការបណ្តុះបណ្តាលផ្នែកខាងទំនាក់ទំនងសង្គម..........................................................66
-កត្តាខ្លះដែលនាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន...........................................................76
-ជៀសវាងការស្រមើស្រមៃក្នុងសង្គមថ្មីនៃវិទ្យាសាស្ត្រជឿនលឿន....................................79
-សេចក្តីសុខនិងជីវិតគ្រួសារ.............................................................................................83
-សេចក្តីសុខ ៤ យ៉ាង.........................................................................................................91
-ការជៀសវាងនូវភាពលំអៀង.............................................................................................97
-បញ្ចពលី.........................................................................................................................100
-មិត្តភាព និងសេចក្តីសុខ.................................................................................................104
-សេចក្តីសុខគឺបុគ្គលខ្លួនឯងជាអ្នកសាង..........................................................................108
-និព្វានគឺជាសេចក្តីសុខដ៏ឧត្តម..........................................................................................110
-សេចក្តីសន្និដ្ឋាន.............................................................................................................112
-សិង្គាលកសូត្រ...............................................................................................................114
-ឯកសារពិគ្រោះ

## បុព្វកថា

សៀវភៅដែលលោកអ្នកកំពុងអាននេះ គឺជាវណ្ណកម្មលើកទីមួយហើយ ដែលខ្ញុំបានខិតខំព្យាយាមស្រាវជ្រាវសរសេរឡើង ទុកជាចំណងដៃ សម្រាប់ជាពន្លឺដល់លោកអ្នកអានទាំងឡាយ ដែលកំពុងដើរលើវិថីនៃជីវិត ក្នុងសហស្សវត្សថ្មីនេះ។ គោលបំណងរបស់សៀវភៅនេះ គឺចង់បង្ហាញនូវអ្វីដែលហៅថា "**សេចក្តីសុខ**" ដែលមនុស្សយើងគ្រប់រូប តែងតែប្រាថ្នាចង់បាននោះ ហើយចំពោះសេចក្តីសុខនេះទៀតសោត តើព្រះពុទ្ធសាសនាបានមានទស្សនៈយ៉ាងដូចម្តេច?។ ក្នុងនាមយើងជាពុទ្ធសាសនិក ជនអ្នកកាន់ព្រះពុទ្ធសាសនា គប្បីសិក្សាស្វែងយល់ឱ្យបានច្បាស់ដោយខ្លួនឯងនូវអ្វីដែលព្រះសម្មាសម្ពុទ្ធទ្រង់បានបង្រៀន ហើយមានជំនឿជឿជាក់ថា មនុស្សយើងម្នាក់ៗគឺជាចៅហ្វាយនាយរបស់ខ្លួនឯង ដោយគ្មានបុគ្គលណាម្នាក់មកត្រួតត្រាធ្វើចៅហ្វាយនាយលើខ្លួនយើងឡើយ។ ដូច្នេះសេចក្តីសុខ និងសេចក្តីទុក្ខ គឺជាសភាវៈមួយដែលបុគ្គលខ្លួនឯងជាអ្នកបង្កើត ហើយវាមិនមែនជាអ្វីដែលអាទិទេព ឬឥទ្ធិពលដទៃខាងក្រៅ ជាអ្នកផ្តល់ឱ្យឡើយ។ ម្យ៉ាងវិញទៀត គឺចង់បង្ហាញអំពីគោលជំហរពិតរបស់ព្រះពុទ្ធសាសនា អំពីសេចក្តីសុខនេះ។ ដូច្នេះ យើងគប្បីបំភ្លឺបញ្ជាក់នូវបញ្ហាដែលចោទឡើងថា តើព្រះពុទ្ធសាសនាបានផ្តល់អាទិភាពដល់ ឬបញ្ជាក់ច្បាស់លាស់ អំពីសេចក្តីសុខនេះដែរឬទេ? សំណួរបែបនេះ តែងតែចោទឡើងជារឿយៗ ពីមជ្ឈដ្ឋានមួយចំនួនដោយហេតុថា ព្រះពុទ្ធសាសនា បានសំដែងសង្កត់ធ្ងន់ទៅលើសេចក្តីទុក្ខ ដែលមាននៅក្នុងជីវិត។ ជាញឹកញាប់ព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែងនូវកត្តាពីរយ៉ាង គឺ

សេចក្ដីទុក្ខ-**ទុក្ខ** និងការបញ្ចប់ទៅនៃសេចក្ដីទុក្ខ-**និរោធ**។

ជាទូទៅ តាមទស្សនៈព្រះពុទ្ធសាសនាយើងដឹងថា អ្វីៗដែលកើតមានឡើងនៅក្នុងលោកយើងនេះ គឺប្រកបទៅដោយសេចក្ដីទុក្ខ។ នេះពីព្រោះជាធម្មតា អ្វីៗគ្រប់យ៉ាង ដែលមាននៅក្នុងលោកទាំងមូល គឺសុទ្ធតែស្ថិតនៅក្រោមឥទ្ធិពលនៃធម៌ **អនិច្ចំ ទុក្ខំ** និង **អនត្តា** ទាំងអស់។ ដូច្នេះពិភពលោកទាំងមូល គឺពោរពេញទៅដោយសេចក្ដីទុក្ខ។

ដោយសារការសំដែងហើយសំដែងទៀត អំពីសេចក្ដីទុក្ខនេះឯងហើយ បានធ្វើឱ្យបុគ្គលមួយចំនួនមានទស្សនៈថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ គឺជាពាក្យប្រៀនប្រដៅ ដែលប្រកបទៅដោយទុទិដ្ឋិនិយម (Pessimistic teaching)។ ការរិះគន់បែបនេះ គឺវាប្រឆាំងយ៉ាងធ្ងន់ធ្ងរទៅនឹងអ្វី ដែលព្រះពុទ្ធទ្រង់បានសំដែង។ ដោយសារមានការរិះគន់ដូច្នេះហើយ បានធ្វើឱ្យអ្នកនិពន្ធមួយចំនួន បង្ខំចិត្តសរសេរពន្យល់នូវអ្វីទៅដែលជាគោលជំហរពិតរបស់ព្រះពុទ្ធសាសនា។

ឥឡូវនេះយើងដឹងហើយថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា គឺជាពាក្យប្រៀនប្រដៅ ដែលមិនប្រកបទៅដោយទុទិដ្ឋិនិយម ហើយទន្ទឹមជាមួយនឹងគ្នានេះដែរ វាក៏មិនប្រកបទៅដោយសុទិដ្ឋិនិយមដែរ តែវាប្រកបទៅដោយសច្ចនិយម (Neither Pessimistict nor Optimistict but Realistict) នេះគឺដោយសារព្រះពុទ្ធសាសនា បានចង្អុលបង្ហាញពីការណ៍ពិតនៃជីវិត ហើយក៏មិនចង់បំភ័ន្តបុគ្គលរស់ក្នុងសភាពស្ងប់ស្ងាត់ នៃឋានសួគ៌របស់មនុស្សល្ងង់ ម្យ៉ាងវិញទៀត ក៏មិនចង់ធ្វើឱ្យ

បុគ្គលភ័យខ្លាច និងសោកសៅជាមួយនឹងអារម្មណ៍ស្រមើស្រមៃ ដែលប្រកបទៅដោយសេចក្តីខ្វល់ខ្វាយ និងអំពើបាបឡើយ ។

សៀវភៅនេះខ្ញុំបានដាក់ឈ្មោះថា **សេចក្តីសុខរបស់អ្នក** ដោយហេតុថា សេចក្តីសុខគឺជាសភាវៈមួយដែលនៅក្នុងកណ្តាប់ដៃបុគ្គលគ្រប់រូប ហើយវាមិនមែនជារង្វាន់ ដែលបុគ្គលណាម្នាក់ផ្តល់ឱ្យឡើយ ។ ដូច្នេះសេចក្តីសុខនេះ គឺជាអ្វីដែលបុគ្គលខ្លួនឯង ជាអ្នកសាងឡើងដើម្បីខ្លួនឯង ។

ក្នុងទីនេះខ្ញុំក៏បានដកស្រង់ **សិង្គាលកសូត្រ** ពីគម្ពីរ **ទីឃនិកាយ** ជាភាសាខ្មែរផងដែរ ដោយខ្ញុំយល់ឃើញថា ព្រះសូត្រនេះមានសារៈសំខាន់ សម្រាប់យើងគ្រប់គ្នា ។ ប្រសិនបើលោកអ្នកអាន ចង់អានបន្ថែមទាំងភាសាបាលីថែមទៀតនោះ សូមទៅអានក្នុងគម្ពីរ **សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ**.....១៩ ទំព័រ ៦៧-៩៣ ។ សូមបញ្ជាក់ថា ខ្ញុំបានរក្សាទុកនូវអត្ថន័យដើមទាំងស្រុងរបស់ព្រះសូត្រនេះ ដោយមិនបានកែប្រែអ្វីទាំងអស់ ។

សៀវភៅនេះ បន្ទាប់ពីបានសរសេររួចរាល់ហើយ ខ្ញុំបានយកសំណៅនេះ ទៅប្រគេន និងជូន ព្រះញាណកោសល **សៅរ៍ ចន្ទថុល្ល** អគ្គាធិការរងពុទ្ធិកសិក្សា ទទួលបន្ទុកគរុកោសល្យ និងវិក្រិតការ ព្រះភិក្ខុ អនុបណ្ឌិត អគ្គធិរោ **ឃី សុវណ្ណរតនា** បង្រៀននៅពុទ្ធិកសាកលវិទ្យាល័យ សីហនុរាជ្យ លោកសាស្ត្រាចារ្យ **ខាវ គ្រិស្នា** និងលោក **ម៉ែន បតស្សរា** ឱ្យជួយពិនិត្យ និងកែសម្រួល ។ រួចហើយ ខ្ញុំក៏បានយកទៅប្រគេនសម្តេច ព្រះពោធិវង្ស **នន្ទ ង៉ែត** ជាព្រះអគ្គាធិការពុទ្ធិកសិក្សា

ទូទាំងប្រទេសពិនិត្យទៀត និងសម្រេច ដើម្បីមានលទ្ធភាពបោះពុម្ពផ្សាយជូនពុទ្ធបរិស័ទអាន ស្រាវជ្រាវតទៅ។

អ្នកនិពន្ធជឿជាក់ថា ទោះបីជាមានការខំប្រឹងប្រែង ព្យាយាមពិនិត្យ ផ្ទៀងផ្ទាត់ ដោយយកចិត្តទុកដាក់យ៉ាងណាក៏ដោយ ក៏នៅតែមានការភ្លាំងភ្លាត់ ខុសឆ្គង និងខ្វះខាត ទាំងអត្ថន័យ និងអក្ខរាវិរុទ្ធ ត្រង់កន្លែងណាមួយដោយអន្លើៗ ដោយអចេតនាពុំខានឡើយ។ អាស្រ័យហេតុនេះ អ្នកនិពន្ធសូមអភ័យទោសអំពីសំណាក់ព្រះថេរានុថេរគ្រប់ព្រះអង្គ ដែលជាពហុសូត្រ ឯកឧត្តម លោកជំទាវ ព្រមទាំងអស់លោក អ្នកអានទាំងអស់ចំពោះកំហុសឆ្គងទាំងឡាយ ក្នុងគ្រាបោះពុម្ពលើកទីមួយនេះ ហើយសូមព្រះថេរានុថេរគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ ព្រមទាំងអស់លោកអ្នកអានទាំងអស់មេត្តាជួយឱ្យជាយោបល់ ឬសរសេរជាសំបុត្រ រំឭកដល់ខ្ញុំផង ដើម្បីឱ្យខ្ញុំបានកែតម្រូវឱ្យកាន់តែប្រសើរឡើង ទុកជាឯកសារល្អមួយ ក្នុងការអប់រំទូន្មានខ្លួនយើង តាមបែបទស្សនៈព្រះពុទ្ធសាសនា ក្នុងគ្រាបោះពុម្ពលើកក្រោយៗទៀត។

ខ្ញុំសូមថ្លែងអំណរអរព្រះគុណ និងអរគុណចំពោះសម្តេច ព្រះពោធិវង្ស ព្រះតេជគុណ លោកសាស្ត្រាចារ្យ ដែលបានជួយពិនិត្យ និងសម្រេច។ ទន្ទឹមជាមួយនឹងគ្នានេះដែរ ក៏សូមថ្លែងអំណរគុណចំពោះព្រះតេជគុណជ **Ven. Shi Fa Zhao** *Chief Incu- mbent of Golden Pagoda Buddhist Temple, Singapore.* ដែលបានណែនាំ និង ជម្រុញខ្ញុំឱ្យខិតខំសិក្សារៀនសូត្ររហូតមក។ ហើយក៏សូមថ្លែងអំណរគុណចំពោះព្រះភិក្ខុ សូរប្បញ្ញោ **ឆាំ សុគឿន** ដែលបានខំព្យាយាមវាយជាអក្សរពុម្ពបញ្ចូលទៅក្នុងកុំព្យូទ័រ រហូតដល់ចប់សព្វគ្រប់ទាំងស្រុង។ម្យ៉ាងវិញទៀត

សូមថ្លែងអំណរគុណចំពោះព្រះថេរានុថេរគ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទទាំងអស់ ដែលបានចំណាយធនធាន ចូលចាប់មគ្គផល ក្នុងការបោះពុម្ពសៀវភៅនេះ។

នៅទីអវសាន អ្នកនិពន្ធសូមឧទ្ទិសស្នាដៃនេះ ជូនចំពោះប្រជាពលរដ្ឋទាំងអស់អ្នកនៅក្នុងនិងក្រៅកម្ពុជរដ្ឋ ក៏ដូចជាប្រជាជនទាំងអស់ អ្នករស់នៅក្នុងពិភពលោកទាំងមូល សូមឱ្យបានដល់នូវសេចក្ដីសុខនិងសន្តិភាពកុំបីឃ្លាតក្លាយ ទៅជាប្រការដទៃឡើយ។

វត្តតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្ដាល
ថ្ងៃទី ១៥ កុម្ភៈ ពស.២៥៤៧
គស.២០០៤
អនុបណ្ឌិត សុធម្មត្ថេរ **ឈុន សុវណ្ណ**

## ធំព័រពិសេស

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការ ថ្វាយបង្គំ ចំពោះព្រះដ៏មានព្រះភាគ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

.................................

ព្រះសម្មាសម្ពុទ្ធ គឺជាព្រះបរមសាស្ត្រាចារ្យមួយព្រះអង្គ រកបុគ្គលណាមួយស្មើគ្មាន-**អនុត្តរោ** ព្រះអង្គមានមហាករុណាគុណ និងបញ្ញាគុណ រកអ្នកឯណាមួយឱ្យស្មើនឹងព្រះអង្គគ្មាន។ ព្រះធម៌ គឺជាសភាវៈដែលព្រះអង្គរកឃើញ ហើយរស់នៅអាស្រ័យនឹងព្រះធម៌នេះឯង។ ព្រះសង្ឃគឺសំដៅលើសហគមន៍ ពួក ឬក្រុមដែលមានបុគ្គលប្រកបទៅដោយសីលធម៌ និងគុណធម៌ ជាអ្នកគោរព និងប្រតិបត្តិតាមឱវាទរបស់ព្រះពុទ្ធអង្គ។ ពុទ្ធបរិស័ទសម្គាល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ថាជាតិសរណៈ ឬព្រះត្រ័យរតនៈ ឬក៏កែវទាំងបី។ សម្រាប់ព្រះសង្ឃ លោកមានកាតព្វកិច្ចពិសេសពីព្រោះលោកជាសមណៈសក្យបុត្ត ឬពុទ្ធបុត្ត។ ដូច្នេះព្រះសង្ឃលោកមានកេរ្តិ៍ដំណែលដ៏អស្ចារ្យនេះ។ ព្រះពុទ្ធអង្គទ្រង់បានលះបង់ ក្នុងមួយជីវិតនៃការត្រាស់ដឹង "**សម្មាសម្ពោធិញ្ញាណ**" របស់ព្រះអង្គ ដើម្បីសេចក្តីសុខ និងសេចក្តីចំរើនដល់មនុស្សសត្វក្នុងលោក។ ក្នុងមួយជីវិត គឺព្រះអង្គធ្វើកិច្ចការ មិនសម្រាប់ជាប្រយោជន៍របស់ព្រះអង្គ

ផ្ទាល់ឡើយ តែទ្រង់ធ្វើជាប្រយោជន៍ដល់បុគ្គលដទៃ។ ព្រះពុទ្ធអង្គមិនគ្រាន់តែជាអ្នកបង្ហាញផ្លូវយើងទៅកាន់ព្រះនិព្វានប៉ុណ្ណោះទេ ទ្រង់ថែមទាំងបង្ហាញផ្លូវយើង ធ្វើយ៉ាងណាដើម្បីរកសេចក្ដីសុខឱ្យបានក្នុងបច្ចុប្បន្នជាតិនេះទៀតផង។

ដោយមានមហាករុណាទិគុណដ៏ជ្រាលជ្រៅ ដល់សត្វលោកដូច្នេះហើយ ទើបព្រះអង្គធ្វើដំណើរទៅគ្រប់ទីកន្លែង តាមផ្លូវពិបាកដោយព្រះបាទ ដើម្បីបំពេញភារកិច្ចរបស់ព្រះអង្គជូនសត្វលោក។ ព្រះអង្គជួបមនុស្សគ្រប់មជ្ឈដ្ឋាន គ្រប់វណ្ណៈខ្ពស់ទាបបង្រៀនធម៌ និងសំដែងធម៌ដល់ពួកគេ ទ្រង់ពន្យល់ដល់ពួកគេនូវបញ្ហាជីវិត និងឱ្យចេះដោះស្រាយនូវបញ្ហាទាំងអស់នោះ ដោយខ្លួនឯងទៀតផង ដោយមិនចាំបាច់ពឹងផ្អែកទៅលើអាទិទេព ឬឥទ្ធិពលដទៃខាងក្រៅឡើយ។

មនុស្សទាំងឡាយបានទទួលស្គាល់ និងប្រតិបត្តិតាមដំបូន្មានដ៏ល្អរបស់ព្រះ-អង្គ។ ព្រះរាជាមានចិត្តអាក្រក់ គ្មានសទ្ធាជ្រះថ្លា ក្លាយទៅជាព្រះរាជាមានចិត្តល្អមានសទ្ធាជ្រះថ្លា អ្នកមានទ្រព្យសម្បត្តិ ស្វិតកំណាញ់ ក្លាយទៅជាអ្នកមានចិត្តសប្បុរសចៅហ្វាយនាយមានចិត្តអាក្រក់ គ្មានចិត្តមេត្តា ក្លាយទៅជាអ្នកមានចិត្តល្អ ចេះសណ្ដោសប្រណី ឃាតករ ចោរលួចប្លន់ ក្លាយទៅជាមនុស្សល្អត្រឹមត្រូវ។ ព្រះអង្គទ្រង់នាំមកនូវការសាមគ្គី ត្រង់កន្លែងណាខ្វះការសាមគ្គី ទ្រង់នាំមកនូវសន្តិភាព ត្រង់កន្លែងណាមានជម្លោះ ទ្រង់នាំមកនូវសេចក្ដីសុខ ត្រង់កន្លែងណាមានសេចក្ដីទុក្ខ។ ព្រះអង្គទ្រង់ណែនាំដល់មនុស្សទាំងឡាយ ឱ្យជៀសវាងនូវអំពើបាបទាំងពួង ហើយឱ្យធ្វើតែអំពើល្អ ធ្វើចិត្តរបស់ខ្លួនឱ្យបរិសុទ្ធ" **សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**

**សចិត្តបរិយោធបនំ**....."។ ព្រះអង្គទ្រង់បានបង្ហាញនូវតម្លៃ នៃសេចក្ដីព្យាយាម ហើយជានិច្ចកាលតែងតែរំលឹកដាស់តឿន ដល់មនុស្សទាំងឡាយ ឱ្យមានវិរិយខ្ពស់ និង ភាពវៃឆ្លាត។ ព្រះអង្គទ្រង់បង្ហាញពីលទ្ធផលអាក្រក់ នៃភាពអាត្មានិយម ហើយទ្រង់ ជម្រុញឱ្យមនុស្សចេះជួយសង្គ្រោះ ធ្វើទានចំពោះអ្នកមានទុក្ខលំបាក អ្នកមានទ្រព្យ ចូរធ្វើជាម្លប់ ជាទីពឹងពុំនាក់ដល់គ្នាអ្នកគ្មានវាសនាល្អដូចខ្លួន ជួយតាមលទ្ធភាព និង សមត្ថភាពដែលខ្លួនមាន។ ព្រះអគ្គសាវ័ករបស់ព្រះអង្គ ដែលដឹកនាំដោយព្រះសារីបុត្ត និងព្រះមោគ្គលាន ប្រព្រឹត្តប្រតិបត្តិតាមឱវាទរបស់ព្រះអង្គ។ ជីវិតជាព្រះអរហន្តរបស់ ព្រះអគ្គសាវ័កទាំងនោះ ប្រព្រឹត្តទៅដើម្បីនាំមកនូវ សេចក្ដីសុខចំរើនរុងរឿង ដល់ មនុស្សជាតិ ដោយជួយដោះស្រាយ នូវរាល់បញ្ហាទាំងឡាយ ដែលកើតមានឡើង នៅ ក្នុងជីវិតរបស់ពួកគេ។ កាតព្វកិច្ចរបស់ព្រះសង្ឃ គឺគោរពប្រតិបត្តិតាមឱវាទ និងគំរូដ៏ ល្អរបស់ព្រះពុទ្ធអង្គ និងព្រះអគ្គសាវ័កទាំងនោះ។ នៅពេលដែលព្យាយាម ដើម្បីឱ្យ បានសម្រេចប្រយោជន៍ផ្ទាល់ខ្លួន ព្រះសង្ឃត្រូវតែបំពេញភារកិច្ច របស់ខ្លួនជូនដល់ ប្រជាពុទ្ធបរិស័ទ ពីព្រោះព្រះសង្ឃ រស់នៅអាស្រ័យនឹងបច្ច័យ៤ របស់ពុទ្ធបរិស័ទ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់តែងតែរំលឹក ដល់ពួកសាវ័ករបស់ព្រះអង្គថា" ភិក្ខុ អ្នក បួសក្នុងសាសនានេះ គឺរស់នៅអាស្រ័យទៅលើសទ្ធា និងការឧបត្ថម្ភពីពុទ្ធបរិស័ទ"។ ដូច្នេះ អ្នកទាំងអស់គ្នា ត្រូវតែតបស្នងសងសទ្ធាពុទ្ធបរិស័ទវិញ ដោយការសំដែងធម៌ក្ដី ដោយការបង្រៀនធម៌ក្ដី បង្ហាញពុទ្ធបរិស័ទឱ្យធ្វើតែអំពើល្អ ហើយវៀរចាកអំពើបាប ទាំងពួង បង្ហាញឱ្យពួកគេដើរលើវិថីល្អ ឆ្ពោះទៅកាន់ឋានសួគ៌ និងព្រះនិព្វាន។ រាល់

កិច្ចការទាំងនោះ គប្បីត្រូវបានធ្វើឡើងជាសន្សឹមៗ ឆ្ពោះទៅកាន់ការកំចាត់បង់នូវ សេចក្តីលោភ" លោភៈ" សេចក្តីក្រោធ" ទោសៈ" និង សេចក្តីវង្វេង" មោហៈ" ដើម្បីឱ្យបាន សម្រេចនូវសេចក្តីសុខដ៏ឧត្តម ។

**ពិភពលោក** គឺជាផ្ទះសំណាក់រយៈពេលខ្លីតែប៉ុណ្ណោះ សម្រាប់យើងគ្រប់រូប យើងចាកចេញទៅ ដោយមិនអាចយកអ្វីទៅជាមួយបាន ក្រៅពីការបន្សល់ទុក និងការស្តាយស្រណោះ នូវអនុស្សាវរីយ៍អតីតកាលរបស់យើងឡើយ ។ ដូច្នេះ ចូរយើងធ្វើអំពើល្អ ដើម្បីសេចក្តីសុខដល់ខ្លួនយើងផង និង ដល់មនុស្សក្នុងលោកទាំងឡាយផង ។

ឈ. សុវណ្ណ

# ជីវប្រវត្តិសង្ខេបនៃព្រះសម្ពុទ្ធ

## ទ្រង់ប្រសូត

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ប្រសូត គឺដើម្បីសេចក្ដីសុខ និងសេចក្ដីល្អដល់មនុស្សលោក។ ការចាប់បដិសន្ធិរបស់មហាបុរសនេះ គឺជាការកម្រពេកណាស់។ មានតែព្រះពុទ្ធមួយព្រះអង្គប៉ុណ្ណោះ ក្នុងរយៈពេលមួយដ៏យូរអង្វែង។ នេះពីព្រោះដោយសារបុគ្គលត្រូវតែបំពេញ នូវបារមីទាំងឡាយ ដើម្បីឱ្យបានត្រាស់ជាព្រះពុទ្ធ។ នៅពេលបុគ្គលកំពុងបំពេញបារមី ដើម្បីឱ្យបានត្រាស់ជាព្រះពុទ្ធ បុគ្គលនោះត្រូវបានហៅថា "**ព្រះពោធិសត្វ**"។

មុនពេលព្រះសម្មាសម្ពុទ្ធបច្ចុប្បន្ន ជាម្ចាស់នៃយើងទ្រង់ប្រសូតជាព្រះសិទ្ធត្ថ ព្រះអង្គទ្រង់បានយោនយកកំណើត ចុងក្រោយរបស់ព្រះអង្គ ជាព្រះពោធិសត្វ ដែលមាន ព្រះនាមថា **ព្រះបាទវេស្សន្តរ**។ បន្ទាប់ពីបានសោយទីវង្គត ពីឋានមនុស្សលោកយើងនេះទៅ ព្រះអង្គក៏បានទៅចាប់បដិសន្ធិ នៅក្នុងឋានតុសិត។ នៅក្នុងជីវិតចុងក្រោយ មុនពេលបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានព្រះនាមថា សន្តុសិតទេវបុត្រ។ នៅក្នុងខណៈនោះពេលវេលាដ៏សមគួរ ក៏បានឈានចូលមកដល់ទេវតាជាច្រើនអង្គ ក៏បានចូលទៅអារធនាព្រះពោធិសត្វឱ្យចុះចាកពីទេវលោកមកចាប់បដិសន្ធិក្នុងឋានមនុស្សលោក ដើម្បីត្រាស់ជាព្រះពុទ្ធ ជួយចំលងមនុស្សសត្វ ឱ្យរួចចាកផុតពីសេចក្ដីទុក្ខ ក្នុងវាលវដ្ដសង្សារ។ ព្រះពោធិសត្វក៏បានទទួលយល់ព្រម នូវការអារធនារបស់ពពួកទេវតាទាំងនោះ។ មុននឹងចុះមកចាប់បដិសន្ធិក្នុងឋានមនុស្សលោក

ព្រះអង្គទ្រង់ប្រមើលមើល នូវបញ្ចមហាវិលោកនៈទាំង ៥ គឺៈ កាល១ ប្រទេស១ ទ្វីប១ ត្រកូល១ និងមាតា១។ បន្ទាប់ពីបានប្រមើលមើល នូវបញ្ចមហាវិលោកនៈទាំង ៥ រួចហើយ ព្រះពោធិសត្វ ក៏សម្រេចចិត្តចុះចាកពីតុសិតទេវលោក ហើយចាប់បដិសន្ធិក្នុងឋានមនុស្សលោក។

ក្នុងកាលនោះ មានសក្យមួយព្រះអង្គទ្រង់ព្រះនាមថា **ព្រះបាទសុទ្ធោទនៈ**។ ព្រះរាជធានីរបស់ព្រះអង្គឈ្មោះថា **កបិលពស្ដុ** នៅភាគខាងត្បូងឆៀងខាងកើតនៃប្រទេសឥណ្ឌា។ព្រះអគ្គមហេសីរបស់ព្រះអង្គទ្រង់ព្រះនាមថា **សិរិមហាមាយាទេវី**។

ពេលនោះគឺក្នុងខែអាសាធដែលប្រជាជនឥណ្ឌា ទាំងរាស្ត្រនាម៉ឺនសព្វមុខមន្ត្រីប្រារព្ធធ្វើបុណ្យមួយដ៏អធិកអធម។ ទីក្រុងទាំងមូលគឺត្រូវបានរៀបចំជាស្រេច ដើម្បីប្រារព្ធធ្វើបុណ្យនេះ។ ព្រះរាជា និងព្រះអគ្គមហេសីរបស់ព្រះអង្គ ក៏បានប្រារព្ធធ្វើនូវបុណ្យនេះ អស់រយៈពេល ៦ យប់ និង៦ ថ្ងៃផងដែរ។ នៅក្នុងថ្ងៃទី ៧ គឺជាថ្ងៃពេញបូណ៌មី ដែលព្រះនាងសិរិមហាមាយាទេវី រក្សានូវឧបោសថសីល។ ក្នុងរាត្រីព្រះនាងក៏ចូលទៅផ្ទំក្នុងព្រះក្រឡាបន្ទំរបស់ព្រះនាង។ នៅក្នុងរាត្រីនោះ ព្រះនាងក៏បានយល់សុបិននិមិត្តដូចតទៅ។

មានទេវបុត្រ៤អង្គ បានមកលើកព្រះនាងទាំងគ្រែដង្ហែទៅកាន់ព្រៃហេមពាន្ត។ បន្ទាប់មកមានទេពធីតា ៤ អង្គទៀតបានស្រង់ទឹកឱ្យព្រះនាងនៅក្នុងអនោត្តស្រះ។ បន្ទាប់ពីស្រង់ទឹករួចហើយ ពួកគេក៏បានស្លៀកសំលៀកបំពាក់ឱ្យព្រះនាង និងប្រដាប់ដោយគ្រឿងអលង្ការ គ្រឿងក្រអូបផ្សេងៗឱ្យព្រះនាង ហើយក៏ឱ្យព្រះនាងផ្ទំលើ

សុវណ្ណមញ្ចាបែរព្រះសិរៈទៅទិសខាងកើត ក្នុងប្រាសាទមាស ។ នៅពេលដែលព្រះនាងកំពុងតែផ្ទំលក់ មានកូនដំរីសមួយយ៉ាងល្អអស្ចារ្យ ដើរចូលមករកព្រះនាង ជាមួយនឹងផ្កាឈូកសនៅក្នុងប្រមោយ ។ កូនដំរីសនោះក៏បានចូលមកជិតព្រះនាង ហើយដើរប្រទក្សិណជុំវិញគ្រែពាជុំ បន្ទាប់មកក៏ហាក់បីដូចជា ចូលទៅក្នុងព្រះឧទររបស់ព្រះនាងផ្នែកខាងស្តាំ ។ ក្រោកពីផ្ទំនាព្រឹកព្រលឹម ព្រះនាងក៏បានទូលថ្វាយនូវដំណឹងនៃសុបិនរបស់ព្រះនាង ដល់ព្រះបាទសុទ្ធោទនីតាមដំណើរ ។ ព្រះរាជាក៏ទ្រង់ត្រាស់ទៅអ្នកបំរើឱ្យទៅហៅព្រាហ្មណ៍ មកពន្យល់នូវសុបិននេះ ។ ពួកព្រាហ្មណ៍ទាំងនោះក៏បានមកដល់ ហើយគន់គូរជើងលេខតាមបែបព្រាហ្មណ៍និយម បន្ទាប់មកពួកគេក៏បាននិយាយថា " សូមទ្រង់ព្រះមេត្តាជ្រាប បើតាមជើងលេខនេះ បញ្ជាក់ឱ្យឃើញថាព្រះនាងទ្រង់មានគភ៌ហើយ ។ ព្រះនាងនឹងមានព្រះរាជបុត្រដ៏ឆ្នើមមួយអង្គ ព្រះរាជបុត្រនេះប្រសិនបើ ទ្រង់គង់នៅជាជីវិតឃរាវាស គ្រប់គ្រងផែនដីនឹងបានក្លាយទៅជាស្តេចចក្កពត្តិ ហើយប្រសិនបើទ្រង់ចេញទៅសាងផ្នួស ស្វែងរកមោក្ខធម៌នឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ទ្រង់ដល់នូវព្រះសម្មាសម្ពោធិញ្ញាណ គ្មានបុគ្គលណាមួយស្មើឡើយ " ។ ទាំងពីរព្រះអង្គ គឺព្រះបាទសុទ្ធោទនី និងព្រះនាងសិរីមហាមាយាទេវី មានព្រះទ័យត្រេកអរជាពន់ពេក នៅពេលដែលទ្រង់បានជ្រាបនូវរឿងនេះ ហើយសង្ឃឹមយ៉ាងមុតមាំថា ព្រះរាជបុត្រនឹងប្រសូត ។

ព្រះបាទសុទ្ធោទនី បានមើលថែរក្សាព្រះនាងយ៉ាងយកព្រះទ័យទុកដាក់ជាទីបំផុត ។ ព្រះអង្គទ្រង់បានប្រទាននូវអ្វី១ទាំងអស់ដល់ព្រះនាង ឱ្យតែព្រះនាងត្រូវការ ។

នៅក្នុងព្រះបរមរាជវាំង ក៏ដូចជានៅក្នុងព្រះនគរទាំងមូល គឺពោរពេញទៅដោយសេចក្តីសុខ។ មានតន្ត្រីប្រគំជាប់ជានិច្ច ដើម្បីឲ្យព្រះនាង មានព្រះទ័យសប្បាយរីករាយ។ មន្ត្រីមុខមុខការទាំងឡាយតែងតែមកថ្វាយព្រះពរចំពោះព្រះអង្គជានិច្ច។

ពេលវេលាកន្លងទៅបាន១០ខែ ហើយពេលវេលាប្រសូតបុត្ត ក៏ឈានចូលមកដល់។ យោងតាមប្រពៃណីទំនៀមទំលាប់ ក្នុងសម័យកាលនោះនាប្រទេសឥណ្ឌា ព្រះនាងសិរីមហាមាយា មានបំណងទៅប្រសូតបុត្ត នៅឯនគរខាងព្រះមាតាបិតារបស់ព្រះនាង។ ដូច្នេះ ព្រះបាទសុទ្ធោទនៈ ក៏បានឲ្យអ្នកបំរើរាជអាមាត្យ រៀបចំគ្រែស្នែង ហើយដង្ហែព្រះនាងទៅកាន់នគរទេវទហៈ ជានគររបស់ព្រះវររាជមាតាបិតា របស់ព្រះនាង។

ពេលនោះគឺនៅក្នុងថ្ងៃសុក្រ ពេញបូណ៌មី ខែពិសាខ ឆ្នាំច។ នៅពេលដែលក្បួនដង្ហែបានកំពុងឆ្លងកាត់ឧទ្យានលុម្ពិនី ព្រះនាងក៏មានអារម្មណ៍អស់កំលាំង។ ព្រះនាងក៏បានក្រឡេកមើលជុំវិញ ហើយបានឃើញដើមសាលព្រឹកមួយដើម មានមែកសាខាប្រកបទៅដោយ ក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់ នាចន្លោះនគរទេវទហៈ និងនគរកបិលព័ស្តុ។ ព្រះនាងត្រាស់ឲ្យអ្នកបំរើនាំព្រះនាង ទៅកាន់កន្លែងនោះ។ នៅពេលដែលព្រះនាងកំពុងតែសម្រាក ព្រះនាងដឹងថា ពេលវេលាប្រសូតបុត្របានឈានចូលមកដល់។ រំពេចនោះអ្នកបំរើ ក៏បានចូលគាល់ព្រះនាង។

ខ្យល់ជំនោរដ៏ត្រជាក់ បានបក់មកត្រសៀកៗ ប៉ះត្រូវនឹងស្លឹករុក្ខជាតិ ដែលនៅជុំវិញ ឮសូរដូចជាសំលេងនៃតូរ្យតន្ត្រី ដែលកំពុងប្រគំរណ្តំដួងចិត្ត។ ដំណក់នៃទឹកភ្លៀង

ដ៏ត្រជាក់ ក៏បានធ្លាក់ចុះមកប្រុយៗពីអាកាសវេហាស៍ ។ សំលេងបក្សាបក្សីទាំងឡាយបានស្រែកច្រៀងនូវចំរៀងដ៏ពិរោះ នៅពេលដែលពពករសាត់អណ្ដែតលើផ្ទៃអាកាសបាំងបាត់រស្មីនៃព្រះសូរិយា ដែលមានពន្លឺដ៏អស្ចារ្យ ចាំងបាចសាចមកលើដែនពសុធាធារដូរដ៏ត្រកាលនេះ ។ ក្លិនពិដោរនៃបុប្ផាទាំងឡាយជុំវិញ បានផ្សព្វផ្សាយទៅគ្រប់ទិសទី ដែលបង្កើតបាននូវបរិយាកាស ដ៏សែនមនោរម្យ ។

អ្នកបំរើបានលាន់មាត់ថា " ល្អណាស់ ! ព្រះរាជទារកល្អប្លែកណាស់ " ។ ព្រះនាងសិរិមហាមាយាបានខ្សឹបតិចៗថា " យកឱ្យខ្ញុំមើលបន្តិច " ។ អ្នកបំរើក៏បានបីទ្រទារកដែលមានពណ៌ដូចមាស ហើយបង្ហាញព្រះនាង ។ ខណៈនោះស្ត្រីបំរើម្នាក់ក៏បាននិយាយឡើងថា យើងត្រូវតែវិលត្រឡប់ទៅព្រះរាជដំណាក់វិញ ហើយថ្វាយដំណឹងដល់ព្រះបាទសុទ្ធោទនី អំពីការប្រសូតនៃព្រះរាជបុត្ត ហើយថាពួកយើងទាំងអស់គ្នា កំពុងតែនៅឯលុម្ពិនីឧទ្យាន ។

# សិទ្ធត្ថរាជកុមារ

ព្រះមាតា និងទារកត្រូវបានយាងវិលត្រឡប់មកកាន់ ព្រះរាជដំណាក់វិញ ជាមួយនឹងក្បួនដង្ហែដ៏អធឹកអធម។ ប្រជានុរាស្ត្រក្នុងក្រុងកបិលព័ស្តុទាំងមូល បានប្រារព្ធធ្វើបុណ្យថ្វាយព្រះពរជ័យ ដល់ព្រះរាជបុត្ររបស់ព្រះរាជាពួកគេ។ ទាំងពីរព្រះអង្គ គឺព្រះបាទសុទ្ធោទនី និងព្រះនាងសិរិមហាមាយា មានសេចក្តីសប្បាយរីករាយជាពន្លឹកចំពោះការប្រសូតព្រះរាជបុត្តដ៏អស្ចារ្យនេះ។ ប៉ុន្តែបន្ទាប់មកសេចក្តីក្រៀមក្រំមួយបានកើតឡើង នៅក្នុងព្រះរាជដំណាក់ទាំងមូល។ ព្រះនាងសិរិមហាមាយាទ្រង់ប្រឈួន ហើយអាការជំងឺរបស់ព្រះនាងចេះតែដុនដាបទៅៗឥតបានធូរស្បើយសោះ ហើយរយៈពេល ៧ ថ្ងៃ ព្រះនាងក៏បានសោយទិវង្គតទៅ បន្សល់ទុកនូវព្រះរាជទារកដែលទើបនឹងប្រសូតឱ្យកំព្រាមាតា។ ក្នុងព្រះនគរទាំងមូល ពោរពេញទៅដោយសេចក្តីទុក្ខក្រៀមក្រំនៃការបាត់បង់ព្រះនាង។ ចាប់តាំងពីពេលនោះមក ព្រះរាជទារកក៏ត្រូវបានមើល ថែដោយព្រះនាងមហាបជាបតិគោតមី ដែលត្រូវជាប្អូនស្រីបង្កើតរបស់ព្រះនាងសិរិមហា-មាយា។ ព្រះនាងថែរក្សាព្រះរាជកុមារបីដូចជាព្រះរាជបុត្រ ដែលប្រសូតចេញពីព្រះឧទររបស់ព្រះនាងផ្ទាល់អ៊ីចឹង។ ព្រះនាងមិនដែលធ្វើឱ្យព្រះរាជកុមារមានអារម្មណ៍ថាខ្លួនគ្មានមាតាឡើយ។ ពេលវេលាបានកន្លងទៅ ព្រះបាទសុទ្ធោទនី ថ្ងៃមួយក៏បានអញ្ជើញ ពួកព្រាហ្មណ៍មកគន់គូរមើលជោគវាសនា និងដាក់ឈ្មោះឱ្យព្រះរាជបុត្ររបស់ព្រះអង្គ។ ព្រាហ្មណ៍ ទាំង១០៨នាក់ បានប្រសិទ្ធិនាមព្រះរាជកុមារថា **ព្រះសិទ្ធត្ថ** ដែលមានន័យថា *អ្នកធ្វើឱ្យសម្រេចប្រយោជន៍គ្រប់យ៉ាង ដើម្បីសេចក្តីសុខដល់មនុស្ស*

*សត្វក្នុងត្រៃភព*។ ពួកព្រាហ្មណ៍ទាំងនោះ បន្ទាប់ពីបានគន់គូរមើល យ៉ាងយកចិត្តទុកដាក់ ហើយក៏បានទាយទុកនូវជោគវាសនា របស់ព្រះរាជកុមារពីរយ៉ាងគឺ ប្រសិនបើជាព្រះសិទ្ធត្ថ នៅជាគ្រហស្ថគ្រប់គ្រងរាជ្យនឹងបានក្លាយទៅជាស្តេចចក្កពត្តិ តែប្រសិនបើលះបង់រាជសម្បត្តិ ចេញសាងផ្នួសនឹងបានត្រាស់ជា ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ។ ព្រាហ្មណ៍ខ្លះ ក្នុងចំណោមព្រាហ្មណ៍ទាំងនោះបានគិតថា ព្រះសិទ្ធត្ថក្លាយទៅជាព្រះពុទ្ធ។ ប៉ុន្តែព្រាហ្មណ៍ម្នាក់ក្មេងជាងគេ ក្នុងចំណោមព្រាហ្មណ៍ទាំងនោះដែលមានឈ្មោះថា កោណ្ឌញ្ញ បានទស្សន៍ទាយតែម្យ៉ាងថា ព្រះសិទ្ធត្ថកុមារពិតជានឹងចេញសាងផ្នួស ហើយបានត្រាស់ជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ។

ក្រោមការបីបមថ្នមថៃ របស់ព្រះនាងបជាបតិគោតមី និងព្រះបាទសុទ្ធោទន៍ ព្រះសិទ្ធត្ថកុមារមានវ័យចំរើនជាលំដាប់ ប្រកបទៅដោយប្រជាប្រិយភាពល្អឥតខ្ចោះ អ្នកផងស្រឡាញ់ចូលចិត្ត រាប់អានគ្រប់គ្នា។ ព្រះអង្គជាព្រះរាជបុត្តដ៏ល្អ គោរពតាមដំបូន្មានរបស់ព្រះវររាជបិតា ជាសិស្សដ៏វៃឆ្លាត ជាកល្យាណមិត្ត និងជាចៅហ្វាយនាយ ដែលមានសប្បុរសធម៌។ ព្រះវររាជបិតាបានផ្តល់ឱ្យអ្វីៗគ្រប់យ៉ាងដល់ព្រះអង្គ ហើយធ្វើឱ្យព្រះអង្គសប្បាយគ្រប់បែបយ៉ាង នៅក្នុងវ័យកុមារភាព ជាមួយមិត្តសំឡាញ់ទាំងឡាយ មានការជិះសេះ ហែលទឹក ទស្សនាសត្វបក្សាបក្សី និងសត្វម្រឹគីម្រឹគាទាំងឡាយនៅក្នុងព្រៃក្បែរៗ។ យប់ និងថ្ងៃកន្លងទៅ បានប្រែក្លាយព្រះសិទ្ធត្ថកុមារទៅជាយុវជនដ៏ស្រស់សង្ហាគួរជាទីពេញចិត្តនៃមនុស្សផងទាំងពួង។ នៅពេលដែលព្រះអង្គចេញដំណើរទៅទីណា ឬក៏ជិះសេះនៅតាមដងវិថីនានាក្នុងរាជធានី មនុស្សម្នាទាំងឡាយបានភ្លូកភ្លឹក ក្រឡេកមើលព្រះអង្គ

គ្រប់ៗគ្នា ដោយស្មានថាជាទេវបុត្តចុះមកពីឋានសួគ៌។ ព្រះសិទ្ធត្ថបានសិក្សាចប់ សិល្បវិជ្ជាទាំងឡាយ ដែលគ្មានបុគ្គលណាម្នាក់អាចប្រៀបផ្ទឹមបាន។ បងប្អូនជីដូនមួយរបស់ព្រះអង្គ គឺទេវទត្ត ដែលជាមនុស្សតែមួយគត់ ដែលចង់យកឈ្នះលើព្រះអង្គគ្រប់បែបយ៉ាង ។ ប៉ុន្តែ ទេវទត្តមិនអាចយកឈ្នះលើព្រះសិទ្ធត្ថបានឡើយ ។ ដូច្នេះហើយបានជាទេវទត្តចេះតែមាន សេចក្ដីច្រណែននឹងព្រះសិទ្ធត្ថគ្រប់ពេលវេលា។ ទេវទត្តនឹកគុំក្នុងចិត្តថាព្រះសិទ្ធត្ថ ជាដៃគូប្រឆាំងរបស់ខ្លួន។

ព្រះបាទសុទ្ធោទនី ទ្រង់តែងតែចង់ឃើញព្រះរាជបុត្ររបស់ព្រះអង្គ ក្លាយទៅជាស្ដេចនៃសក្យវង្ស។ ដូច្នេះហើយបានជាព្រះអង្គ ធ្វើឱ្យព្រះសិទ្ធត្ថសប្បាយក្នុងផ្លូវលោក ក្នុងគោលបំណងឱ្យភ្លេចអំពីការសាងផ្នួស ដោយព្រះអង្គនៅចាំបានអំពីការទស្សន៍ទាយរបស់ព្រាហ្មណ៍ទាំងឡាយនោះ។ ព្រះបាទសុទ្ធោទនីបានឱ្យគេកសាងប្រាសាទ៣ ដើម្បីតម្រូវ នឹងរដូវកាលទាំង៣ សម្រាប់ព្រះសិទ្ធត្ថ។ ព្រះអង្គបានឱ្យគេប្រគំតន្ត្រីរាល់រាត្រីមានទាំងស្រីរបាំរាំកំដរទៀតផង។ មិនត្រឹមតែប៉ុណ្ណោះ ព្រះអង្គបានឱ្យគេផ្ដល់ឱ្យ ព្រះសិទ្ធត្ថនូវក្រយាស្ងោយ និងសំលៀកបំពាក់ដ៏ល្អប្រណិតៗគ្រប់ពេលវេលា។ លុះដល់ព្រះជន្មបាន១៦ព្រះវស្សា ព្រះវររាជបិតា ក៏បានរៀបចំអភិសេកព្រះសិទ្ធត្ថ ជាមួយនឹងព្រះនាងពិម្ពាយសោធរា ដែលជាព្រះរាជបុត្រីរបស់ ព្រះបាទសុប្បពុទ្ធ។ ព្រះរាជបុត្រនិងព្រះរាជបុត្រី ទាំងពីរព្រះអង្គស័ក្ដិសមគ្នាណាស់ ប្រៀបបានបីដូចជាទេវបុត្រនិងទេវធីតានាឋានសួគ៌ា។ ពួកគេស្រឡាញ់គ្នាហើយយល់ព្រះទ័យគ្នាទៅវិញទៅមកទៀតផង។ ពួកគេបានរស់នៅជាមួយគ្នាយ៉ាងសប្បាយរីករាយ ហើយ

លុះកាលកន្លងទៅបានយូរបន្តិច ព្រះនាងពិម្ពាក៏ប្រសូតបានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមថារាហុលកុមារ ។

# ការយាងចេញសាងផ្នួសរបស់ព្រះសិទ្ធត្ថ

ស្ថិតក្នុងវ័យនេះ ព្រះសិទ្ធត្ថរស់នៅមានសេចក្តីសុខណាស់ ទោះបីព្រះអង្គចង់បានអ្វី ក៏បានតាមព្រះទ័យប្រាថ្នា។ ព្រះអង្គមានភរិយាដ៏ស្រស់ស្អាត មានប្រាសាទ៣ សម្រាប់រដូវទាំង៣ កាលគឺ ហេមន្តរដូវ១ គិម្ហរដូវ១ និងវស្សានរដូវ១ មានការសប្បាយគ្រប់ប្រភេទ គ្មានខ្វះចន្លោះអ្វីឡើយនៅក្នុងជីវិតរបស់ព្រះអង្គ ប៉ុន្តែព្រះអង្គតែងតែមានអារម្មណ៍ថា អ្វី១គ្រប់យ៉ាងបានបង្ហាញឱ្យឃើញថា វាគួរឱ្យមានសេចក្តីសង្ឃឹមទុកចិត្ត និងទៀងទាត់ តែតាមការណ៍ពិតវាមិនដូច្នោះឡើយ។ ព្រះអង្គទ្រង់យល់ឃើញថា នៅថ្ងៃណាមួយមនុស្សទាំងឡាយនៅជុំវិញព្រះអង្គ នឹងមិនសប្បាយរីករាយ។ បុគ្គលខ្លះមានជម្លោះទាស់ទែងគ្នា បុគ្គលខ្លះបាត់បង់ញាតិសាលោហិតមិត្តជាទីស្រឡាញ់របស់ខ្លួន។ ជាញឹកញាប់ព្រះអង្គតែងតែឃើញមនុស្សរងទុក្ខវេទនាដោយភាពក្រីក្រ នៅពេលដែលព្រះអង្គ កំពុងតែសោយសុខលើគំនរមាសប្រាក់។ ព្រះអង្គតែងតែឮដំណឹង អំពីការស្លាប់របស់មនុស្សម្នាទាំងឡាយក្នុងសង្គ្រាម។ ទោះបីជាព្រះអង្គព្យាយាមបំភ្លេចចោល នូវរឿងទាំងអស់នេះយ៉ាងណាក៏ដោយ ក៏វាចេះតែជាប់តាម នៅក្នុងចិត្តារម្មណ៍របស់ព្រះអង្គជានិច្ច គ្រប់ពេលវេលា។ ជាញឹកញាប់ព្រះអង្គតែងតែអង្គុយម្នាក់ឯង សញ្ជឹងនឹកគិតអំពីបញ្ហាទាំងអស់នេះ។ ជីវិតឃរាវាសគឺវាស្មុគ្រស្មាញ ហើយពោរពេញទៅដោយឧបសគ្គ ដូច្នេះទើបបានជាព្រះអង្គ មិនអាចស្វែងរកនូវសេចក្តីសុខខាងផ្លូវចិត្តបាន។ ថ្ងៃមួយនៅពេលដែលព្រះអង្គកំពុងតែយាង

កំសាន្តក្នុងឱទ្យាន ក៏បានឃើញនូវទេវទូត ៤ យ៉ាងគឺ មនុស្សជរា១ មនុស្សឈឺ១ មនុស្សស្លាប់១ និងអ្នកបួស១[១] ។ បន្ទាប់ពីបានឃើញទេវទូតទាំង៤ នេះមក ព្រះអង្គតែងតែនឹកគិតហើយមានព្រះទ័យព្រួយបារម្ភ តែព្រះអង្គចាប់ព្រះទ័យទៅលើភេទអ្នកបួស ។ ចាប់តាំងពីពេលនោះមកព្រះអង្គទ្រង់មានព្រះទ័យនឿយណាយបន្តិចម្តងៗ អំពីជីវិតឃរាវាស ។ រាជបំរើទាំងឡាយ បានកត់សម្គាល់នូវហេតុការណ៍ ដែលបានកើតឡើងចំពោះព្រះសិទ្ធត្ថ ដូច្នេះហើយក៏ទៅក្រាបទូលថ្វាយ នូវដំណឹងនេះដល់ព្រះបាទសុទ្ធោទនី ។ នៅពេលដែលទ្រង់បានជ្រាបនូវដំណឹងនេះហើយ ព្រះបាទសុទ្ធោទនីទ្រង់ក៏បានឱ្យរាជបំរើប្រើគ្រប់មធ្យោបាយ ធ្វើយ៉ាងណាឱ្យព្រះសិទ្ធត្ថមានការសប្បាយរីករាយចិត្ត បំភ្លេចចោលនូវរឿងទាំងអស់នោះ ចំណែកឯព្រះនាងពិម្ពាក៏បានព្យាយាមគ្រប់បែបយ៉ាងផងដែរ ។

១៣ឆ្នាំកន្លងផុតទៅហាក់បីដូចជាមួយពព្រិចភ្នែក ព្រះនាងពិម្ពាសង្ឃឹមថានឹងប្រសូតព្រះរាជបុត្រមួយព្រះអង្គ។ ព្រះសិទ្ធត្ថរីឯរិតតែមានអារម្មណ៍ស្មុគ្រស្មាញ ថែមទៀត នៅពេលដែលឃើញព្រះនាងពិម្ពា ស្ថិតនៅក្នុងស្ថានភាពបែបនេះ ។ ព្រះអង្គទ្រង់នៅចាំបាន ក្នុងថ្ងៃដែលព្រះអង្គរៀបអភិសេក ជាមួយព្រះនាងពិម្ពា ប៉ុន្តែឥឡូវនេះអ្វីៗគ្រប់យ៉ាងគឺត្រូវបានផ្លាស់ប្តូរ ។

ព្រះនាងពិម្ពា ប្រសូតបានព្រះរាជបុត្រាមួយព្រះអង្គ ។ នៅពេលដែលព្រះសិទ្ធត្ថបានដឹងនូវដំណឹងនេះភ្លាម ទ្រង់មានព្រះទ័យសប្បាយរីករាយឥតឧបមា ។ ព្រះអង្គចង់

---

[១] ទ្រង់យាងទៅកំសាន្តមួយលើកឃើញទេវទូតមួយ

ទៅមើលព្រះរាជបុត្រ និងព្រះនាងពិម្ពា ប៉ុន្តែវំពេចនោះ ព្រះអង្គទ្រង់យល់ ឃើញថា *ព្រះរាជបុត្រនេះនឹងជាចំណងចងអញ ទៅនឹងជីវិតឃរាវាសមិនខាន* ដូច្នេះព្រះអង្គគ្រាន់តែលបចូលទៅក្នុងបន្ទប់ ចង់បីទ្រព្រះរាជបុត្រ តែបានឃើញព្រះនាងពិម្ពា កំពុងតែផ្ទំលក់ ដាក់ព្រះហស្ដម្ខាងទៅលើព្រះរាជបុត្រ។ ដូច្នេះព្រះអង្គក៏គិតឃើញថា *ប្រសិនបើអញចង់លះបង់នូវសិរីរាជសម្បត្តិ ដើម្បីសាងផ្នួស នេះគឺជាពេលវេលា ដ៏សមគួររបស់អាត្មាអញ នឹងត្រូវទៅហើយ ប្រសិនបើមិនដូច្នោះទេ ចំណងនេះនឹង ចងអញ ពន្លិចឱ្យរឹតតែជ្រៅជាមិនខាន*។ បន្ទាប់ពីទ្រង់បានព្រះតម្រិះច្បាស់ដូច្នេះហើយ ព្រះអង្គក៏បានហៅឆន្នអាមាត្យឱ្យយកសេះកណ្ឋកមក ដើម្បីចេញដំណើរទៅរាត្រីត្រជាក់ស្ងាត់ ជ្រងំនៅខាងក្រៅព្រះរាជដំណាក់ ដំណក់នៃទឹកសន្សើម ក្នុងរាត្រីកាលបានធ្លាក់ចុះមកយ៉ាងស្ងៀមស្ងាត់ គ្របដណ្ដប់គ្រប់ទិសទី។ ម្ដងទៀតព្រះអង្គបានលបចូលទៅក្នុងបន្ទប់ដើម្បីមើលព្រះរាជបុត្រ និងព្រះនាងពិម្ពានាឱកាសចុងក្រោយ។ ព្រះអង្គមានអារម្មណ៍ថា ព្រះបាទាទាំងពីររបស់ព្រះអង្គធ្ងន់ទៅៗ ជាមួយនឹងការរំជួលចិត្ត សង្កត់បេះដូងជាប់ដោយមិនអាចឈប់បង្អង់យូរតទៅទៀតបានឡើយ។ ព្រះអង្គក៏បានឱ្យសញ្ញាដល់ឆន្នអាមាត្យចេញដំណើរទៅ។ នៅក្នុងរាត្រីដ៏សែនស្ងាត់ព្រះអង្គបានយាងដោយសេះកណ្ឋកតាមពីក្រោយដោយឆន្នអាមាត្យក៏បានលិចបាត់បន្តិចម្ដងៗ ទៅក្នុងរាត្រីដ៏ងងឹត។

*សូមចំណាំរដូវទាំង៣:* ១-ហេមន្តរដូវ គឺរដូវមានទឹកសន្សើម ជារដូវរងា មាន៤ខែ រាប់ពីថ្ងៃ១រោចខែកត្តិក ដល់ថ្ងៃ១៥កើតខែផល្គុន។ ២-គិម្ហរដូវ គឺរដូវក្ដៅ មាន៤ខែ រាប់ពីថ្ងៃ១រោចខែផល្គុន ដល់ថ្ងៃ១៥កើតខែអាសាឍ។ ៣-វស្សានរដូវ គឺរដូវភ្លៀង មាន៤ខែ រាប់ពីថ្ងៃ១រោចខែអាសាឍ ដល់ថ្ងៃ១៥កើតខែកត្តិក។

# ការស្វែងរកនូវសម្មាសម្ពោធិញ្ញាណ

ធ្វើដំណើរដោយសេះ អស់រយៈពេលជាច្រើនម៉ោង រហូតដល់ពេលទៀបភ្លឺ ព្រះអង្គក៏បានឆ្លងទៅត្រើយម្ខាងនៃស្ទឹងអនោមា។ ព្រះអង្គបានដោះសំលៀកបំពាក់ និងគ្រឿងអលង្ការទាំងឡាយ ហើយស្លៀកសំលៀកបំពាក់ជាអ្នកបួស កាត់ព្រះកេសា កោរពុកមាត់ ពុកចង្កា រួចហើយក៏បញ្ជូនឆន្នអាមាត្យ និងសេះកណ្ឋក ព្រមទាំងសំលៀកបំពាក់ និងគ្រឿងអលង្ការទាំងអស់ មកព្រះរាជដំណាក់វិញ។ ជាមួយនឹងសំលៀកបំពាក់បែបនេះ គឺព្រះពោធិសត្វ ព្រះអង្គចាប់ផ្ដើមធ្វើដំណើរឆ្លងកាត់ផ្លូវឆ្ងាយ ព្យាយាមជំនះនូវឧបសគ្គទាំងឡាយ ដើម្បីចង់ដឹងនូវបញ្ហា និងការណ៍ពិតនៃជីវិត។

ព្រះពោធិសត្វមានអារម្មណ៍ថា ជីវិតអ្នកបួសគឺវាពិបាកណាស់ នៅពេលដែលព្រះអង្គបើកគ្របបាត្រមើលទៅក្នុងបាត្រ ឃើញចង្ហាន់ដែលព្រះអង្គទើបទទួលបានពីការបិណ្ឌបាត្រ ព្រះអង្គមានអារម្មណ៍ចង់ក្អួត ដោយព្រះអង្គមិនធ្លាប់ជួបប្រទះ នូវអាហារបែបនេះពីមុនមក។ បន្ទាប់មក ព្រះពោធិសត្វបានដាស់តឿនខ្លួនឯងថា អាត្មាអញបានសម្រេចចិត្តលះបង់នូវជីវិតសុភមង្គល ក្នុងព្រះរាជដំណាក់ ដើម្បីមកស្វែងរកនូវមោក្ខធម៌។ ដោះស្រាយនូវរាល់បញ្ហាទាំងឡាយ ដែលស្មុគស្មាញនៅក្នុងចិត្តរួចហើយ ទើបព្រះពោធិសត្វសំរេចចិត្ត សោយអាហារទាំងនេះ។ ទទួលសោយអាហាររួចហើយ ព្រះអង្គទ្រង់សំរាកមួយស្របក់ បន្ទាប់មកក៏បានធ្វើដំណើរបន្តទៅទៀត ដែលមិនវិលត្រឡប់ក្រោយវិញឡើយ។

ថ្ងៃមួយព្រះពោធិសត្វបានជួបនឹងព្រះបាទពិម្ពិសារ ដែលជាស្តេចមានអានុភាព ច្រើនក្នុងដែនមគធៈ។ ព្រះបាទពិម្ពិសារ បានត្រាស់ហៅព្រះពោធិសត្វ មកជួយគ្រង រាជ្យរបស់ព្រះអង្គដោយចែកទ្រព្យសម្បត្តិពាក់កណ្តាលឱ្យ ព្រះពោធិសត្វបានបដិសេធ នូវព្រះរាជសំណើរនេះ ប៉ុន្តែទ្រង់បានសន្យាថា មកជួបព្រះបាទពិម្ពិសារវិញនៅពេល ណាដែលព្រះអង្គបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ។ បន្តបន្ទាប់ពីនោះមកព្រះពោធិ សត្វបានធ្វើដំណើរបន្តទៅទៀត ដើម្បីស្វែងរកគ្រូល្បីៗ។

ព្រះពោធិសត្វបានជួបនឹងគ្រូល្បីម្នាក់ឈ្មោះ អាឡារតាបស។ ព្រះអង្គបានខំ ប្រឹងសិក្សាសព្វមុខវិជ្ជា ហើយទីបំផុតក៏បានសម្រេច សមាបត្តិ៧ ពីតាបស ប៉ុន្តែលុះ ក្រោយមក ព្រះពោធិសត្វទ្រង់បានជ្រាបថា ការបង្រៀនរបស់លោកអាចារ្យនេះ គឺអស់ត្រឹមនេះហើយ ៗមិនអាចផ្តល់ឱ្យនូវសេចក្តីសុខពិត ដែលព្រះអង្គកំពុងស្វែងរក នោះឡើយ។ ដូច្នេះព្រះពោធិសត្វក៏បានធ្វើគារវកិច្ចអរគុណ និងលាអាឡារតាបស ធ្វើ ដំណើរបន្តទៅមុខទៀត។

បន្ទាប់មក ព្រះពោធិសត្វទ្រង់បានជួបនឹងគ្រូដ៏ល្បីឈ្មោះ ម្នាក់ទៀតគឺ ឧទករាមបុត្រ។ ដូចជាអាឡារតាបសដែរ ព្រះអង្គបានរៀនចប់អស់នូវវិជ្ជារបស់គាត់ ហើយទ្រង់ចំរើននូវសមាបត្តិ៨។ ជាមួយនឹងការសម្រេចបាននូវសមាបត្តិ៨ នេះព្រះ ពោធិសត្វនៅតែមិនពេញព្រះទ័យ ហើយក៏បានធ្វើគារវកិច្ចអរគុណ ចំពោះតាបស រួចក៏ធ្វើដំណើរតទៅមុខទៀត រហូតដល់តំបន់មួយឈ្មោះថាឧរុវេលនិគម។ ថ្លែងពី កោណ្ឌញ្ញ និងព្រាហ្មណ៍៤ នាក់ទៀត ដែលបានចេញទៅបួសតាមព្រះអង្គ ហើយនៅជា

មួយខុទករាមបុត្រនោះ ក៏បានធ្វើដំណើរចេញទៅជាមួយព្រះពោធិសត្វដែរ។

ព្រះពោធិសត្វមិនអស់សង្ឃឹមឡើយ ព្រះអង្គទ្រង់តាំងនូវមហាបធាន គឺការព្យាយាមធំក្នុងទីនេះ។ ព្រះពោធិសត្វទ្រង់សញ្ជឹងគិតថា ផ្លូវណាគួរអាត្មាអញ គប្បីបដិបត្តិ បន្ទាប់មកព្រះអង្គក៏សម្រេចចិត្តយកផ្លូវអត្តកិលមថានុយោគ គឺធ្វើទុក្ករកិរិយា។ ទ្រង់សម្រេចចិត្តដូច្នេះហើយ ព្រះអង្គធ្វើទារុណកម្មខាងផ្លូវរាងកាយរបស់ព្រះអង្គ។ ព្រះពោធិសត្វបានកាត់បន្ថយនូវការទទួលទានចំណីអាហារ និងទឹករហូតដល់រាងកាយទាំងមូល នៅសល់តែស្បែកដណ្ដប់ឆ្អឹង ស្ទើងស្មាធិ៍សមាធិទាល់តែដួលដេកសន្លប់លើផែនដី។ ក្នុងខណៈពេលដែលព្រះពោធិសត្វ កំពុងតែដួលដេកសន្លប់លើផែនដី ទេវតាដែលជាបក្សពួកនៃមារក៏នឹកស្មានថា ព្រះពោធិសត្វព្រះអង្គសុគត ទើបថ្វាយដំណឹងនេះដល់ព្រះវររាជបិតា គឺព្រះបាទសុទ្ធោទន៍។ សក្កទេវរាជ បានយកពិណ ដែលមានខ្សែ៣ មកដេញថ្វាយព្រះពោធិសត្វជាប្រស្នា រឹតខ្សែ១ តឹងពេក សំឡេងមិនពិរោះរឹតខ្សែ១ទៀតធូរពេក សំឡេងក៏មិនពិរោះ ហើយរឹតខ្សែចុងក្រោយ គឺខ្សែកណ្ដាលសំឡេងពិរោះល្អ។

ព្រះអង្គមានស្មារតីឡើងវិញ ទ្រង់ស្វែងយល់ឃើញថា ការបដិបត្តិអស់រយៈកាល៦ ព្រះវស្សាកន្លងមកនេះ មិនបានសម្រេចប្រយោជន៍ទាល់តែសោះ ពីព្រោះអាត្មាអញប្រព្រឹត្តបដិបត្តិ តឹងរឹងហួសប្រមាណ ដែលធ្វើឱ្យរាងកាយ និងចិត្តចុះខ្សោយ។ ដូច្នេះព្រះអង្គក៏សម្រេចចិត្ត លះបង់ផ្លូវនេះចោល-**ទុក្ករកិរិយា**។ ថ្លែងពីបញ្ចវគ្គិយ៍ភិក្ខុ៥ អង្គ លុះបានឃើញព្រះពោធិសត្វ លះបង់ចោលនូវការបដិបត្តិនេះ ក៏សម្រេច

ចិត្តចាកចេញទៅ ទុកឱ្យព្រះពោធិសត្វនៅតែមួយព្រះអង្គឯង ដោយនឹកគិតថា ព្
ប្រយោជន៍អ្វីនឹងនៅបំរើព្រះអង្គ ពីព្រោះសូម្បីតែបដិបត្តិផ្លូវដ៏តឹងរឹង មិនបានសម្រេ
នូវសម្មាសម្ពោធិញ្ញាណផង ចុះទំរាំតែលះបង់ផ្លូវនេះចោល ហើយសោយអាហារវិ
នោះ តើនឹងសម្រេចអ្វីទៅកើត។ ថាដូច្នោះហើយ ពួកបញ្ចវគ្គិយ៍ភិក្ខុក៏ជៀសចេញ
កាន់ព្រៃឥសិបទនមិគទាយវ័ន។

# ការបានត្រាស់ដឹង

នៅពេលលះបង់ចោលការបដិបត្តិ អត្តកិលមថានុយោគោ រាងកាយ និងកំលាំងរបស់ព្រះពោធិសត្វ ក៏បានប្រែក្លាយទៅជាធម្មតាវិញបន្តិចម្តងៗ។ បន្ទាប់មក ព្រះពោធិសត្វក៏បានដឹងថា ចិត្តរបស់ព្រះអង្គក៏ភ្លឺស្វាងដែរ។ ដូច្នេះព្រះអង្គចាប់ផ្តើមគិតរិះថានឹងត្រូវធ្វើយ៉ាងណាទៀត បន្ទាប់ពីនេះទៅ។

ព្រឹកមួយ បន្ទាប់ពីបានលុបលាងព្រះភ័ក្ត្ររួចហើយ ព្រះពោធិសត្វបាននិមន្តស្វែងរកកន្លែងស្ងាត់មួយ ដើម្បីគង់ស្ងឹងស្មាធិ៍ រកនូវវិធីដែលនឹងត្រូវបដិបត្តិ។ ឃើញដើមជ្រៃមួយដើមធំ ដែលមានមែកសាខា ព្រះពោធិសត្វក៏ទ្រង់និមន្តទៅ ហើយគង់ក្រោមម្លប់ជ្រៃនោះ។ ថ្លែងពីនាងទារិកាម្នាក់ឈ្មោះ សុជាតា ជាធីតារបស់សេន កុដុម្ពីកសេដ្ឋី ដែលនៅក្នុងស្រុកនោះ បន្ទាប់ពីនាងមានវ័យចំរើនឡើងហើយ នាងក៏ទៅតាំងនូវសេចក្តីប្រាថ្នា ទៀបនឹងដើមជ្រៃនោះថា" នៅពេលដែលនាងខ្ញុំមានប្តី សូមឱ្យមានជាតិត្រកូលស្មើគ្នា ហើយសូមឱ្យមានកូនប្រុសច្បង"។

ចំណេរចេរកាលខាងក្រោយមក សេចក្តីប្រាថ្នារបស់នាង ក៏បានសម្រេចពិតប្រាកដមែន។ ដើម្បីសំដែលនូវកតញ្ញូតាចមិដល់ទេវតា ដែលនៅថែរក្សាដើមជ្រៃនោះ ក្នុងការធ្វើសុបិនរបស់នាងឱ្យបានសម្រេច នាងក៏បានរៀបចំនូវដង្វាយ ដ៏ពិសេសគឺមធុបាយាស-*បាយដាំលាយជាមួយនឹងទឹកដោះគោ ឬទឹកឃ្មុំ* ដើម្បីថ្វាយ ដល់ទេវតាដែលជាម្ចាស់នៃដើមជ្រៃនោះ។ ពេលនោះ នាងបានឃើញព្រះពោធិសត្វ កំពុងតែគង់តាំងសមាធិក្រោមដើមជ្រៃ នាងគិតថា ទេវតាមានចិត្តត្រេកអរ នូវអ្វីដែលនាង

បានធ្វើ បានជាមកចាំទទួលដោយផ្ទាល់តែម្តង។ ឃើញដូច្នោះ នាងបានថ្វាយចង្ហាន់នោះដល់ព្រះពោធិសត្វ ព្រមជាមួយនឹងភាជន៍ ហើយជៀសចេញទៅ។ នេះគឺជាចង្ហាន់ចុងក្រោយហើយ ដែលព្រះពោធិសត្វ ទ្រង់បានទទួលពីនាងសុជាតា មុនពេលបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។

ក្រោកពីអាសនៈ ព្រះពោធិសត្វទ្រង់បានយាងទៅកាន់ស្ទឹងនេរញ្ជរា ដើម្បីស្រង់ទឹក បន្ទាប់មកក៏ឆាន់ចង្ហាន់ ដែលព្រះអង្គទ្រង់ពូតបានចំនួន៤៩ ពុំនូត ប៉ុន១គ្រាប់ត្នោត។ បន្ទាប់ពីបានឆាន់ចង្ហាន់រួចហើយ ព្រះអង្គទ្រង់យកភាជន៍ ទៅដាក់ក្នុងស្ទឹង ហើយផ្សងថា" ប្រសិនបើអាត្មាអញបានត្រាស់ជាព្រះពុទ្ធ ក្នុងថ្ងៃនេះពិតប្រាកដមែន សូមឱ្យភាជន៍មាសនេះ អណ្តែតច្រាស់ទឹកឡើងទៅ" ដូចក្តីផ្សងពិតប្រាកដមែន ភាជន៍មាសនោះក៏អណ្តែតច្រាស់ទឹកឡើងទៅបាន៨០ហត្ថ រួចហើយក៏លិចចុះក្នុងពិភពកាឡនាគបាត់ទៅ ហើយទង្គិចនឹងភាជន៍របស់ព្រះពុទ្ធ៣អង្គពីបូរាណ ហើយសៀតស៊កទ្រពីខាងក្រោមភាជន៍ទាំងនោះ។

បន្ទាប់មក ព្រះពោធិសត្វទ្រង់បានយាងទៅសម្រាកក្នុងសាលវ័ន ទៀបឆ្នេរស្ទឹង ហើយនៅសាយណ្ហសម័យ ព្រះអង្គទ្រង់ទៅគង់ទៀបគល់ព្រះពោធិព្រឹក្ស ដោយបន្លឺនូវសច្ចវាចាថា " ប្រសិនបើអាត្មាអញ មិនបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធក្នុងថ្ងៃនេះទេ អាត្មាអញនឹងមិនក្រោកពីកន្លែងនេះឡើយ ស្បែក សរសៃ ឆ្អឹង ឈាម របស់អាត្មាអញចូររីងស្ងួត អស់ទៅក៏ដោយចុះ" ។

រាត្រីកាលក៏ឈានចូលមកដល់ ព្រះច័ន្ទមូលក្រឡង់លើផ្ទៃមេឃានាថ្ងៃ ១៥ កើត ខែពិសាខ បានបាចសាចនូវពន្លឺពណ៌មាសរបស់ខ្លួនមកលើផែនដី។ រុក្ខជាតិទាំងឡាយជុំវិញ ធ្វើចលនារិច១ ដែលប៉ះត្រូវដោយខ្យល់ជំនោរត្រសៀក១ នាំមកជា

មួយនូវក្លិនពិដោរដ៏ក្រអូបនៃបុប្ផាទាំងឡាយ ដែលហាក់បីដូច ជាទន្ទឹងរង់ចាំនៃការត្រាស់ដឹងរបស់ព្រះពោធិសត្វ។ បរិយាកាសជុំវិញមានពន្លឺភ្លឺថ្លា ដោយរស្មីនៃដួងព្រះច័ន្ទ ព្រះពោធិសត្វដឹងថាចិត្តារម្មណ៍ របស់ព្រះអង្គក៏ភ្លឺឡើងដែរ។

បន្ទាប់មក ព្រះពោធិសត្វក៏បានប្រមូលអារម្មណ៍ សញ្ជឹងគិតនៅពេលដែលព្រះអង្គនៅជាកុមារ បានធ្វើសមាធិសម្រេចបានឈានទី១ នៅពេលដែលគេនាំព្រះអង្គ ទៅចូលរួមក្នុងពិធីបុណ្យច្រត់ព្រះនង្គ័ល។ ខណៈនោះព្រះពោធិសត្វទ្រង់បានជ្រាបថា នេះគឺជាវិធីដែលគួរស្ទឹងស្ទាធីពិតប្រាកដ។ លោភៈ ទោសៈ ភាពងោកងុយរបស់ចិត្ត និងភាពរំខានរបស់ចិត្តក៏បានអស់ទៅបន្តិចម្ដងៗ។ ចិត្តរបស់ព្រះអង្គក៏ចាប់ផ្ដើមស្ងប់ទៅៗ ហើយបន្ទាប់មកចិត្តរបស់ព្រះអង្គ ត្រូវបានគ្រប់គ្រងទាំងស្រុង។ ព្រះពោធិសត្វក៏បានបន្តតម្រង់ចិត្តដែលគ្រប់គ្រងបាននោះដើម្បីចំរើនអភិញ្ញាទៀត។ តាមរយៈអភិញ្ញាទាំងនេះ ព្រះអង្គបានដល់នូវ **បុព្វេនិវាសានុស្សតិញ្ញាណ** គឺប្រាជ្ញាជាគ្រឿងដឹងនូវអតីតជាតិរបស់ព្រះអង្គតាំងពីជាតិទី១ ទី២ ទី៣ ទី៤......ដ៏រាបដល់សែនជាតិ ។ល។ **ទិព្វចក្ខុ** គឺប្រាជ្ញាជាគ្រឿងដឹងនូវសត្វដែលច្យុត និងកើត ថោកទាប ឬខ្ពង់ខ្ពស់.....ដែលប្រព្រឹត្តទៅតាមកម្មជារបស់ខ្លួន និង **អាសវក្ខយញ្ញាណ** គឺប្រាជ្ញាជាគ្រឿងផ្ដាច់នូវអាសវៈទាំងឡាយ។ ដូច្នេះចិត្តរបស់ព្រះអង្គក៏បានរំដោះ ហើយព្រះអង្គក៏បានដឹងដែរថា ព្រះអង្គបានរួចចាកអំពីសេចក្ដីទុក្ខ-**ទុក្ខ**។ ព្រះអង្គទ្រង់បានជ្រាបច្បាស់អំពីបញ្ហានៃជីវិត និងកងទុក្ខទាំងពួង។ ដោយសារព្រះអង្គបានជ្រាបច្បាស់អំពីបញ្ហានៃជីវិត និងកងទុក្ខដែល ព្រះអង្គនិងមនុស្សសត្វ ទាំងអស់ជួបប្រទះនោះ ទើបព្រះអង្គក្លាយទៅជាព្រះសម្មាសម្ពុទ្ធ។

# ៤៥ព្រះវស្សានៃជីវិតសម្មាសម្ពោធិញ្ញាណ

ព្រះពោធិសត្វព្រះជន្មបាន២៩ ព្រះវស្សា នៅពេលដែលព្រះអង្គយាងចេញសាងផ្នួស។ ព្រះអង្គទ្រង់បានចំណាយអស់រយៈពេល៦ ព្រះវស្សា ក្នុងការស្វែងរកនូវសម្មាសម្ពោធិញ្ញាណ។ នៅទីបំផុតព្រះអង្គក៏បានសម្រេច សម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកបុគ្គលណាមួយប្រៀបផ្ទឹមពុំបាន ក្នុងព្រះជន្ម៣៥ ព្រះវស្សា។ ក្នុងរយៈពេល៤៥ព្រះវស្សានៃជីវិតសម្មាសម្ពោធិញ្ញាណ ព្រះអង្គបានបង្រៀនធម៌ និងសំដែងធម៌ដើម្បីនាំមកនូវសេចក្តីសុខ និងសេចក្តីចំរើនដល់សត្វលោកទូទៅ។

ប្រកបដោយបញ្ញាគុណ និងករុណាគុណ ព្រះអង្គទ្រង់អាចយល់ នូវបញ្ហានៃសេចក្តីទុក្ខ របស់សត្វលោកទាំងឡាយ ហើយបង្ហាញផ្លូវនៃការរំដោះខ្លួនឱ្យរួចចាកទុក្ខឆ្ពោះទៅកាន់សេចក្តីសុខ។ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ **សត្ថា ទេវមនុស្សានំ** ជាអ្នករកឃើញផ្លូវ **មគ្គស្ស អាក្ខាតា** ជាអ្នកមានមហាករុណា **មហាការុណិកោ**។

ព្រះអង្គមានមហាករុណា ចំពោះសត្វលោកទាំងអស់ស្មើៗគ្នា ឥតមានលំអៀង។ ព្រះអង្គទ្រង់មិនបានបែងចែកនូវការខុសប្លែកគ្នា រវាងអ្នកមាន និងអ្នកក្រ អ្នកខ្ពស់និងអ្នកទាប អ្នកមានអំណាច និងអ្នកឥតអំណាច។ល។ ព្រះអង្គទ្រង់បានរួចចាកផុតពីភាពរើសអើង ហើយទ្រង់ខំធ្វើតែអំពើល្អដល់សត្វលោក ដោយករុណាតែម្យ៉ាងប៉ុណ្ណោះ។ ព្រះអង្គទ្រង់មិនគិតអំពីឋានៈ ឬមុខងាររបស់បុគ្គល ដែលមករកព្រះអង្គ

ឡើយ ព្រះអង្គទ្រង់គិតតែបញ្ហារបស់បុគ្គល ហើយណែនាំ និងដោះស្រាយប៉ុណ្ណោះ ។

ព្រះអង្គទ្រង់មិនដែលតាំងប្រកាសថា ព្រះអង្គគឺជាអាទិទេពឡើយ តែព្រះអង្គទ្រង់ប្រកាសថា ខ្លួនព្រះអង្គ គឺជាគ្រូមួយអង្គប៉ុណ្ណោះ ព្រះអង្គគឺជាគ្រូដែលបានរកឃើញផ្លូវនេះ ហើយទ្រង់បង្ហាញដល់មនុស្សទាំងឡាយឱ្យដើរតាម ប្រសិនបើអ្នកទាំងនោះ ចង់បានសេចក្តីសុខមែននោះ ។ ព្រះអង្គទ្រង់មិនដែលប្រើអំណាច ឬឥទ្ធិពលរបស់ព្រះអង្គ គ្របសង្កត់ទៅលើបុគ្គលណាមួយឡើយ ។ ព្រះអង្គទ្រង់មិនដែល បង្ខិតបង្ខំឱ្យបុគ្គលជឿ គោរពតាមពាក្យប្រៀនប្រដៅ របស់ព្រះអង្គឡើយ ប៉ុន្តែព្រះអង្គទ្រង់ត្រាសថា បុគ្គលគប្បីមកមើលដោយខ្លួនឯង នូវពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ហើយប្រតិបត្តិតាម ប្រសិនបើគេមានបំណង ។ ព្រះអង្គទ្រង់មិនដែលបង្គាប់ ឱ្យបុគ្គលដទៃបដិបត្តិ នូវអ្វីដែលព្រះអង្គមិនបានបដិបត្តិឡើយ ។ ព្រះអង្គទ្រង់ឱ្យបុគ្គលដទៃបដិបត្តិ នូវអ្វីដែលព្រះអង្គទ្រង់បានបដិបត្តិ ។ ត្រង់គុណលក្ខណៈនេះឯងហើយ ដែលធ្វើឱ្យព្រះអង្គក្លាយទៅជាគ្រូ គ្មានបុគ្គលណាមួយប្រៀបផ្ទឹមបាន ។ ព្រះអង្គគឺជាគ្រូ ជាសាស្ត្រាចារ្យ រកបុគ្គលណាមួយប្រៀបផ្ទឹមពុំបាន ដូច្នេះហើយទើបបានជាព្រះរាជាទាំងឡាយ ក្រាបថ្វាយបង្គំព្រះអង្គ ប្រជាជនគ្រប់ស្រទាប់វណ្ណៈ គ្រប់មជ្ឈដ្ឋានមករកព្រះអង្គ ឱ្យជួយដោះស្រាយនូវបញ្ហារបស់ពួកគេ ពួកសេដ្ឋីបានចំណាយធនធានរបស់ខ្លួន ដើម្បីកសាងវត្តថ្វាយព្រះអង្គ ព្រះរាជាមួយចំនួនបានលះបង់រាជសម្បត្តិរបស់ខ្លួន ដើម្បីតម្កល់ខ្លួនជាសាវ័កដ៏ល្អរបស់ព្រះអង្គ ។ ទោះបីជាមានការសរសើរ ការគាំទ្រដូច្នេះ ពីគ្រប់មជ្ឈដ្ឋាន គ្រប់ស្រទាប់វណ្ណៈ យ៉ាងណាក៏ដោយ ក៏ព្រះអង្គនៅតែមាន

ព្រះទ័យស្ងប់ មិនកំរើកញាប់ញ័រជានិច្ចប្រៀបបានបីដូចជាសសរស្ដម្ភដ៏រឹងមាំ មិនកំរើកញាប់ញ័រ ដោយត្រូវខ្យល់ព្យុះបោកបក់មកពីទិសទាំង៤។

អ្នកខ្លះរិះគន់ ព្យាបាទ តាមធ្វើឃាតព្រះអង្គ អ្នកខ្លះទៀតសរសើរ តែព្រះអង្គទ្រង់មានព្រះទ័យមិនរំភើបញាប់ញ័រឡើយ ហើយទ្រង់យល់ថា នេះគឺជាផ្នែកមួយនៃជីវិត ដែលនឹងត្រូវផ្លាស់ប្ដូរជានិច្ចប៉ុណ្ណោះ។ គោលបំណងនៃការត្រាស់ដឹងរបស់ព្រះអង្គ គឺចង់នាំមកនូវសេចក្ដីសុខ ដល់សត្វលោកគ្រប់រូបតែប៉ុណ្ណោះ។ ដើម្បីឱ្យបានសំរេច នូវគោលបំណងនេះ ព្រះអង្គទ្រង់បានឧទ្ទិស ជីវិតសម្ភាស ម្ដោ ធិញ្ញាណរបស់ព្រះអង្គ អស់រយៈពេល៤៥ ព្រះវស្សាគត់។ ព្រះអង្គ យាងពីកន្លែងមួយទៅកន្លែងមួយគ្រប់ច្រកល្ហក ដើម្បីសំដែងធម៌និងបង្រៀនធម៌ ដល់មនុស្សទាំងឡាយទាល់តែព្រះអង្គយាងទៅមុខទៀតលែងរួច។ មហាករុណាគុណរបស់ព្រះអង្គ គឺឃើញច្បាស់នៅពេលដែលព្រះអង្គទ្រង់រៀបយាងចូលកាន់ព្រះនិព្វាន ព្រះអង្គបានសំដែងធម៌និងអនុញ្ញាតឱ្យសុភទ្ទ បួសក្នុងសំណាក់ព្រះអង្គ។

# ពុទ្ធនិវាសនដ្ឋាន

សម្ដេចព្រះភគវន្ត អនន្តញ្ញាណ តាំងពីបានត្រាស់ដឹងជាព្រះពុទ្ធស្រេច ទ្រង់ត្រេចចរប្រកាសព្រះពុទ្ធសាសនាដឹកនាំវេនេយ្យជនជាច្រើនតំបន់ ឱ្យចូលកាន់ព្រះពុទ្ធសាសនានេះ។ ទីកន្លែងដែលព្រះអង្គគង់ចាំវស្សាមាន១៤កន្លែង បើរាប់ជាគ្រា ដែលលើក ពីកន្លែងមួយទៅកន្លែងមួយនោះមាន១៨ គ្រាគឺ គ្រាទី១-វស្សាទី១ ព្រះអង្គទ្រង់គង់ ចាំវស្សានៅព្រៃឥសិបទនមិគទាយវ័ន ជិតក្រុងពារាណសី គ្រាទី-២ វស្សាទី២ ទី៣ ទី៤ ព្រះអង្គទ្រង់គង់ចាំវស្សានៅក្នុងវត្តវេឡុវនារាមជិតក្រុងរាជគ្រឹះ គ្រាទី៣-វស្សាទី៥ ព្រះអង្គទ្រង់គង់ចាំវស្សានៅក្នុងកូដាគារសាលាព្រៃមហាវ័ន ជិតក្រុងវេសាលី គ្រាទី៤-វស្សាទី៦ព្រះអង្គទ្រង់គង់ចាំវស្សានៅលើមកុឌបពិត ក្នុងដែនមគធៈ គ្រាទី៥-វស្សាទី៧ ព្រះអង្គទ្រង់ឡើងទៅគង់ចាំវស្សានៅក្នុងឋានតាវតឹង្ស លើថ្មបណ្ឌុកម្ពល សិលាសនៈ ត្រាស់ប្រទានព្រះសត្តប្បករណាភិធម្ម ៧ គម្ពីរ ប្រោសពុទ្ធមាតា គ្រាទី៦-វស្សាទី៨ ព្រះអង្គទ្រង់ឡើងទៅគង់ចាំវស្សានៅក្នុងភេសកលាវ័នក្នុងតគ្គរាជជនបទ គ្រាទី៧-វស្សាទី៩ ព្រះអង្គទ្រង់គង់ចាំវស្សានៅព្រៃបាលិលេយ្យកៈ គ្រាទី៨-វស្សា ទី១០ ទី១១ ព្រះអង្គទ្រង់គង់ចាំវស្សានៅក្នុងដងព្រៃ ជិតស្រុកព្រាហ្មណ៍ឈ្មោះ សាលេយ្យកៈគ្រាម គ្រាទី៩-វស្សាទី១២ ព្រះអង្គទ្រង់គង់ ចាំវស្សានៅក្រោមដើមស្ដៅ ដែលនឡេរុយក្សរក្សា គ្រាទី១០-វស្សាទី១៣ ព្រះអង្គទ្រង់គង់ចាំវស្សានៅភ្នំ បាលេយ្យកៈបពិត គ្រាទី១១-វស្សាទី១៤ព្រះអង្គទ្រង់គង់ចាំវស្សានៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី គ្រាទី១២-វស្សាទី១៥ ព្រះអង្គទ្រង់

គង់ចាំវស្សានៅក្នុងវត្តនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ គ្រាទី១៣-វស្សា ទី១៦ ព្រះអង្គទ្រង់គង់ចាំវស្សានៅក្នុង អាឡវី ដើម្បីប្រោសអាឡវយក្ស គ្រាទី១៤-វស្សាទី១៧ ទី១៨ ទី១៩ព្រះអង្គទ្រង់ គង់ចាំវស្សានៅក្នុងវេឡុវនារាម ជិតក្រុងរាជ គ្រឹះ គ្រាទី១៥-វស្សាទី២០ដល់ ទី២៩ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងជេតវនមហាវិហារ ជិតក្រុងសាវត្ថី គ្រាទី១៦-វស្សាទី៣០ ដល់៣៥ ព្រះអង្គគង់ចាំវស្សានៅក្នុងវត្តបុព្វារាម គ្រាទី១៧-វស្សាទី៣៦ ដល់ទី ៤៤ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងជេតវនមហាវិហារ ជិតក្រុងសាវត្ថី គ្រាទី១៨-វស្សាទី៤៥ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងស្រុក វេឡុវនគ្រាម ជិតក្រុងវេសាលី។ រួមទីកន្លែងដែល ព្រះអង្គធ្លាប់គង់ចាំវស្សា ត្រូវជា ១៤កន្លែង រួមគ្រាត្រូវជា ១៨គ្រា រួមវស្សាទាំងអស់ មាន៤៥វស្សា។

## ពុទ្ធកិច្ច៥ប្រការ

១-**បុព្វណ្ហេ បិណ្ឌបាតញ្ច** ក្នុងវេលាព្រឹកទ្រង់ត្រេចទៅដើម្បីបិណ្ឌបាត្រ

២-**សាយណ្ហេ ធម្មទេសនំ** ក្នុងវេលារសៀលទ្រង់សំដែងធម៌ទេសនា ដល់សាធារ ណៈជន

៣-**បទោសេ ភិក្ខុឱវាទំ** ក្នុងវេលាព្រលប់ទ្រង់ប្រទានឱវាទ ដល់ពួកភិក្ខុទាំងឡាយ

៤-**អឌ្ឍរត្តេ ទេវបញ្ហានំ** ក្នុងវេលាពាក់កណ្តាលអាធ្រាត្រទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា

៥-**បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ** ដល់វេលាបែកបច្ចូសម័យ ទ្រង់ប្រមើលមើល នូវសត្វដែលមានភព្វ និងឥតភព្វ។

*ចំណាំ* ត្រង់ពុទ្ធនិវាសនដ្ឋាននេះគឺស្រង់ចេញពីសៀវភៅពុទ្ធប្បវត្តិកថា របស់អាចារ្យ ឈឹម ស៊ុមនី ទំព័រ១៣៤-១៣៦

# ការយាងចូលព្រះនិព្វាន

ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងព្រះជន្ម៨០ ព្រះវស្សាគត់។ ព្រះអង្គទ្រង់មានព្រះកាយកោងបន្តិច ហើយស្មាទាំងពីរក៏ធ្លាក់បន្តិចផងដែរ ប៉ុន្តែ ព្រះអង្គអាចលែលកយាងទៅមុខទៀតបាន ដោយគ្មានការពិបាក។ ព្រះអង្គទ្រង់មិនប្រើឈើច្រត់ ហើយស្ទើរតែគ្រប់ពេលវេលា ព្រះអង្គទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អានាថបណ្ឌិកសេដ្ឋី។

ថ្ងៃមួយ ព្រះបាទអជាតសត្តុ បានបញ្ជូនអ្នកតំណាងព្រះអង្គម្នាក់ឈ្មោះវស្សការ មកជួបនឹងព្រះអង្គ ក្នុងគោលបំណងដើម្បីស្វែងរក នូវព្រះយោបល់ពីព្រះអង្គអំពីពួកវជ្ជី។ បន្ទាប់ពីការជួបបានចប់សព្វគ្រប់ហើយ ព្រះអង្គទ្រង់បានសំដែងនូវ **សត្តអបរិហានិយធម៌** គឺជាធម៌ដែលនាំមកនូវសន្តិភាព និងការអភិវឌ្ឍន៏៧ យ៉ាង។ បន្ទាប់ពីបានប្រទានឱវាទដល់ពួកភិក្ខុ អំពីបញ្ហាផ្សេងៗ ដែលអាចនាំមកនូវសេចក្ដីសុខចំរើនដល់ពួកភិក្ខុសង្ឃ ព្រះអង្គទ្រង់យាងចេញទៅ នៃដំណើរចុងក្រោយរបស់ព្រះអង្គ។

ហែហមដោយភិក្ខុសង្ឃជាច្រើនអង្គ ជាមួយនឹងព្រះអានន្ទផង ព្រះអង្គទ្រង់បានយាងពីទីក្រុងមួយទៅទីក្រុងមួយ ពីភូមិមួយទៅភូមិមួយ។ ព្រះអង្គទ្រង់បានឆ្លងកាត់នូវតំបន់ទាំងឡាយ ដូចជា អម្ពលត្ថិកា នាលន្ទា បាត្តលី រួចហើយឆ្លងទន្លេគង្គាហើយក៏បានយាងទៅដល់ភូមិមួយឈ្មោះ កោតិគ្រាម។ តពីនោះមក កាត់តាមធារទឹកព្រះអង្គក៏យាងមកដល់វេសាលី។ ទីកន្លែងនោះហើយដែល អម្ពបាលី ដ៏ល្បីឈ្មោះម្នាក់បានមកគាល់ព្រះអង្គ ។នៅពេលដែលព្រះអង្គយាងមកដល់ភូមិមួយឈ្មោះវេឡុវគ្រាម

ឬបេឡុវគ្រាម រដូវចូលព្រះវស្សាក៏បានឈានចូលមកដល់។ ក្នុងខណៈពេលដែលសាវ័កទាំងអស់គង់ចាំព្រះវស្សា ក្នុងក្រុងវេសាលី ព្រះអង្គបានគង់ចាំព្រះវស្សានៅឯវេឡុវគ្រាមនេះតែម្ដង។ ទីនេះគឺជាកន្លែងដែលព្រះអង្គ ទ្រង់មានអាពាធជាទម្ងន់។ ព្រះអានន្ទមានសេចក្ដីព្រួយបារម្ភជាខ្លាំង។ ព្រះអានន្ទបានគិតថា ព្រះអង្គប្រហែលជានឹងបរិនិព្វាន ដូច្នេះព្រះអានន្ទ ក៏បានអង្វរព្រះអង្គឱ្យទ្រង់ប្រទាននូវឱវាទចុងក្រោយ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងខណៈពេលនោះ ព្រះអង្គបានជាសះស្បើយឡើងវិញ។ នៅថ្ងៃក្រោយបន្ទាប់ ព្រះអង្គក៏បានយាងទៅបិណ្ឌបាត្រ ក្នុងក្រុងវេសាលី។ រួចមកព្រះអង្គក៏បានយាងទៅកាន់វិហារសាសនាមួយឈ្មោះចបាល។

ព្រះអង្គទ្រង់ជ្រាបថា ថ្ងៃបរិនិព្វានរបស់ព្រះអង្គ កាន់តែខិតចូលមកជិតហើយ។ព្រះអង្គទ្រង់រំពឹងគិតនូវបេសកកម្មរបស់ព្រះអង្គ ក្នុងកំឡុងពេល៤៥ព្រះវស្សាដែលព្រះអង្គបានធ្វើជូនសត្វលោកទាំងឡាយ។ ព្រះអង្គទ្រង់មានព្រះទ័យ សប្បាយរីករាយដោយព្រះអង្គទ្រង់ឃើញថា ព្រះអង្គមានជ័យជំនះក្នុងបេសកកម្មនេះ។ មានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាជាច្រើន ដែលចេះស្ទាត់ជំនាញ នូវអ្វីដែលព្រះអង្គទ្រង់បានបង្រៀន។ គណៈសង្ឃ ភិក្ខុ ភិក្ខុនី ត្រូវបានបង្កើតឡើយយ៉ាងរឹងមាំ។ ព្រះអង្គទ្រង់ត្រៀមចាំចូលកាន់ព្រះនិព្វានជាស្រេច។ ព្រះអង្គបានបន្តដំណើររបស់ព្រះអង្គ ឆ្លងកាត់ភូមិ ស្រុក និងទីក្រុង ជាច្រើនដូចជា ភណ្ឌ ហត្ថិ អម្ព ជម្ពូ ភាគៈ។ វាគឺនៅក្នុងស្រុកភាគៈនេះហើយដែលព្រះអង្គទ្រង់បានឆាន់ចង្ហាន់ចុងក្រោយរបស់ព្រះអង្គ ដែលប្រគេនដោយនាយចុន្ទ។ បន្ទាប់ពីបានឆាន់នូវចង្ហាន់ដ៏ពិសេស រៀបចំថ្វាយដោយនាយចុន្ទមក

ព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ទោះបីព្រះអង្គទ្រង់ប្រឈួនជាទម្ងន់យ៉ាងនេះក៏ដោយ ក៏ព្រះអង្គទ្រង់ខំធ្វើដំណើរតទៅទៀត ឆ្ពោះទៅក្រុងវេសាលី។ ប្រឈួនរបស់ព្រះអង្គ រេះតែធ្ងន់ទៅៗ ធ្វើឱ្យព្រះកាយពលចេះតែខ្សោយទៅៗជាលំដាប់។ នៅតាមផ្លូវព្រះ-អង្គ មានកំលាំងកាន់តែខ្សោយ ហើយស្រេកទឹកទៀតផង ដូច្នេះ ព្រះអង្គក៏ទ្រង់ត្រាស់ហៅព្រះអានន្ទឱ្យដួសទឹកមកថ្វាយព្រះអង្គបន្តិច។ ប៉ុន្តែទឹកនៅក្នុងបឹងក្បែរនោះ ល្អក់កកឃើញសុទ្ធតែភក់ បន្ទាប់មកទឹកនោះ ក៏បានថ្លាដូចកញ្ចក់ឡើងវិញ ដោយអំណាចបុណ្យបារមីរបស់ព្រះអង្គ ហើយព្រះអានន្ទក៏បានយកទឹកនោះ មកថ្វាយព្រះអង្គ។ ទោះបីជាមានការលំបាកយ៉ាងណាក្ដី ព្រះអង្គទ្រង់ក៏បានយាងមកដល់ទន្លេមួយឈ្មោះកកុដ្ឋា ហើយព្រះអង្គក៏បានស្រង់ទឹក សំអាតព្រះកាយ ក្នុងទន្លេនោះ។ បន្ទាប់ពីបានស្រង់ទឹករួចហើយ ព្រះអង្គក៏មានកំលាំងបន្តិច រួចហើយក៏បានយាងមកសាលវ័នរបស់ពួកក្សត្រមល្ល នាក្រុងកុសិនារា។ មកដល់ទីនេះ ព្រះអង្គទ្រង់ប្រឈួនជាខ្លាំង ដែលមិនអាចបន្តដំណើរទៅមុខទៀតបានឡើយ។ ព្រះអង្គទ្រង់ត្រាស់ទៅនឹងព្រះអានន្ទថាម្នាលអានន្ទ ចូរអ្នករៀបចំសង្ឃាដីឱ្យមានក្បាលដំណេក បែរទៅទិសខាងជើងក្នុងចន្លោះសាលព្រឹក្សទាំងគូឱ្យតថាគតឱ្យឆាប់មក។

ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ នាគ្រានោះទ្រង់មិនអាចក្រោកឡើងបានទៀតឡើយ។ បុប្ផទាំងឡាយលើដើមសាលព្រឹក្សរុក្ខជាតិជុំវិញ ហាក់បីដូចជាមានសភាពស្ងប់ស្ងាត់ ក្រៀមក្រំ យំសោកស្ដាយស្រណោះ នៃការបាត់បង់នូវព្រះសាស្ដាជាម្ចាស់ ហើយបានរុះរោយធ្លាក់ចុះមកលើព្រះកាយ របស់ព្រះអង្គបន្តិចម្ដងៗ នាំមកនូវ

ក្លិនពិដោររបស់ខ្លួន ផ្សព្វផ្សាយទៅទីទាំងពួងជុំវិញ។ ព្រះអានន្ទដោយមិនអាចទប់ទឹកនេត្រាបាន នៅពេលឃើញព្រឹត្តិការណ៍បែបនេះ ក៏ឈរទ្រហោយំ រៀបរាប់ជាអនេកកប្បការ។ ព្រះអង្គទ្រង់ក៏បានលួងលោមព្រះអានន្ទ ហើយមានពុទ្ធដីកាសរសើរពីគុណសម្បត្តិរបស់ព្រះអានន្ទ ដោយប្រការផ្សេងៗ។ រំពេចនោះមានបុរសម្នាក់ឈ្មោះសុភទ្ទចូលមកដល់ ក្នុងខណៈពេលដែលព្រះអង្គ ទៀបនឹងឈានចូលកាន់ព្រះនិព្វានហើយនោះ ព្រះអង្គទ្រង់ក៏សំដែងធម៌ដល់សុភទ្ទ ហើយអនុញ្ញាតឱ្យបួសតែម្ដងទៅ។ បន្ទាប់ពីប្រទានឱវាទចុងក្រោយ ដល់សាវ័កទាំងអស់នោះហើយ ព្រះអង្គទ្រង់តាំងសមាធិ នៅទីបំផុតក៏យាងចូលកាន់មហាបរិនិព្វាន ក្នុងសាលវ័នឱទ្យាន នាចន្លោះដើមសាលព្រឹក្សទាំងគូ ទៀបក្រុងកុសិនារា ក្នុងថ្ងៃអង្គារ៍ ពេញបូណ៌មី ខែវិសាខ ឆ្នាំម្សាញ់បញ្ចស័ក ក្នុងវេលារាត្រីទៀបភ្លឺនោះឯង។

## បញ្ញត្តិស័ព្ទ

## " **សុខ** "

ពាក្យថា " **សុខ** " គឺជាពាក្យបាលី។ នៅក្នុងវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យនេះអាចជា គុណនាមផង និងជានាមផង។ តែក្នុងទីនេះគឺសំដៅយកជានាម ដែលមានន័យថា " សេចក្ដីសប្បាយ សេចក្ដីសុខ ដំណើរស្រណុក មានសុខ បានសុខ ។ល។

ពាក្យថាសុខនេះ គឺជាកំណត់សំគាល់ នូវប្រភេទលក្ខណៈ និងគំរិតនៃសេចក្ដីសប្បាយ នៅក្នុងន័យ និងបរិយាកាសផ្សេងៗ។ ដើម្បីធ្វើឱ្យយល់ច្បាស់អំពីបញ្ញត្តិស័ព្ទ " **សុខ** " នេះឱ្យកាន់តែច្បាស់នោះ អ្នកសិក្សាគប្បីពិនិត្យ នូវអត្ថន័យផ្សេងៗ ដែលជាកំណត់សម្គាល់ពាក្យថាសុខ នៅក្នុងភាសាបាលីនេះ។ បើនិយាយឱ្យទូលំទូលាយទៅ " សុខ" ឬសេចក្ដីសុខ ចែកចេញជាពីរយ៉ាង ដូចដែលមាននៅក្នុង **បដិសម្ភិទាមគ្គ** គឺសុខខាងផ្លូវកាយ និងសុខខាងផ្លូវចិត្ត។

ទោះបីជាសេចក្ដីសុខនេះ ត្រូវបានបែងចែកយ៉ាងនេះក៏ដោយក៏នៅទីបំផុតគឺវាសំដៅយកសភាវៈ ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត។ ចំពោះសេចក្ដីសុខខាងផ្លូវកាយក៏ដូចគ្នាដែរ នៅទីបំផុតគឺវាសំដៅយកការពិសោធន៍ផ្សេងៗ ដែលប្រព្រឹត្តទៅតាមផ្លូវ ចិត្តា-រម្មណ៍។ សេចក្ដីសុខនេះចែកចេញជាពីរយ៉ាងទៀតគឺ **បព្វជិតសុខ** និង **គិហិសុខ**។ **បព្វជិតសុខ** គឺជាសេចក្ដីសុខរបស់អ្នកបួស រីឯ **គិហិសុខ** វិញគឺជាសេចក្ដីសុខរបស់គ្រហស្ថ អ្នកនៅគ្រប់គ្រងផ្ទះ។ **នេក្ខម្មសុខ** គឺមានអត្ថន័យប្រហាក់ប្រហែលនឹង

**បព្វជិតសុខ** ដែរ ហើយជាញឹកញាប់គឺសំដៅយកសេចក្ដីសុខ ដែលកើតអំពីការសាងផ្នួស លះបង់ការជាប់ជំពាក់នូវវត្ថុ ឬរឿងរ៉ាវផ្សេងៗក្នុងលោក។ មានសេចក្ដីសុខពីរយ៉ាងទៀតគឺ **សាមិសសុខ** និង **និរាមិសសុខ**។ **សាមិសសុខ** គឺសំដៅយកសេចក្ដីសុខដែលកើតអំពីការសប្បាយរីករាយ ជាមួយនឹងរបស់ ឬវត្ថុ ដែលនាំឱ្យកើតចំណង់តណ្ហា។ **និរាមិសសុខ** គឺជាសេចក្ដីសុខដ៏ឧត្ដម ដែលកើតអំពីការចំរើន អប់រំ ខាងផ្លូវចិត្ត។ សេចក្ដីសុខប្រភេទនេះ គឺកើតពីសេចក្ដីស្ងប់ខាងផ្លូវចិត្ត របស់ព្រះសម្មាសម្ពុទ្ធ និងព្រះអរហន្តសាវ័កទាំងឡាយ។ ដូច្នេះហើយជាទូទៅ គឺវាមិនមានទំនាក់ទំនង ជាមួយនឹង វេទនាឡើយ " **អវេទយិតសុខ** "។

នៅក្នុងធម្មបទមានវគ្គមួយ ដែលបង្ហាញអំពីកំណត់សម្គាល់ ទៅលើពាក្យថា " សុខ " ដែលកំណត់ប្រភេទ និងកម្រិតនៃសេចក្ដីសុខផ្សេងៗគ្នា ដូចជាការរស់នៅជាសុខ ដោយមិនមានពៀរវេរានឹងគ្នា ក្នុងចំណោមមនុស្សដែលមានពៀរវេរានឹងគ្នា ការរស់នៅជាសុខ ដោយមិនមានរោគ ក្នុងចំណោមមនុស្សដែលមានរោគ ការរស់នៅជាសុខ ដោយមិនមានសេចក្ដីខ្វល់ខ្វាយ ក្នុងចំណោមមនុស្សដែលមានសេចក្ដីខ្វល់ខ្វាយ កិលេសជាគ្រឿងកង្វល់ មិនមានដល់បុគ្គលទាំងឡាយណា បុគ្គលទាំងឡាយនោះរស់នៅជាសុខ ។ល។ ធម្មបទក្នុងវគ្គនេះ ក៏បានបញ្ជាក់ច្បាស់ផងដែរ នូវអ្វីដែលជាសេចក្ដីសុខ ដោយបង្ហាញនូវចំណាប់អារម្មណ៍របស់អ្នកមានសម្បត្តិ ចំពោះទុគ៌តភាពនៃជីវិតប្រចាំថ្ងៃរបស់ពួកគេ ដូចជាសេចក្ដីស្រេកឃ្លាន សេចក្ដីទុក្ខព្រោះបញ្ចក្ខន្ធ ជាដើម។ ម្យ៉ាងវិញទៀតវាក៏បានបង្ហាញ នូវកត្តាដែលនាំមកនូវសេចក្ដីសុខផងដែរ។

កត្តាទាំងនោះ ដូចជាមានសុខភាពល្អ មានអាយុយឿនយូរ មានគ្រឿងឧបភោគ បរិភោគគ្រប់គ្រាន់ សេពគប់ជាមួយនឹងបុរសជាបណ្ឌិត បានជួបជាមួយក្រុមគ្រួសារ សាច់ញាតិ ជាទីស្រឡាញ់ ។ល។ ហើយទីបំផុត និព្វាន គឺជាសេចក្ដីសុខដ៏ឧត្តម " **និព្វានំ បរមំ សុខំ**។ ប៉ុន្តែ ព្រះពុទ្ធសាសនាមិនកំណត់ព្រំដែនត្រឹមតែសេចក្ដីសុខខាងផ្លូវចិត្តប៉ុណ្ណោះទេ។ នៅពេលដែលសំដែង អំពីសេចក្ដីសុខខាងផ្លូវចិត្ត ព្រះពុទ្ធសាសនាក៏បានសំដែងផងដែរ នូវលក្ខណៈ និងប្រភេទនៃសេចក្ដីសុខ ដែលបុគ្គល ជាឃរាវាស អាចទទួលបាន ក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ដែលកើតចេញអំពីសម្ភារៈ ដូចជាសេចក្ដីសុខជាជីវិតកូនប្រុសស្រី ឪពុកម្ដាយ ជីវិតអាពាហ៍ពិពាហ៍ជាដើម ។ល។ មិនត្រឹមតែប៉ុណ្ណោះ ព្រះពុទ្ធសាសនាក៏បានបង្ហាញ នូវហេតុដែលនាំមកនូវសេចក្ដីសុខ និងឧបសគ្គផ្សេងៗ ដែលជាហេតុនាំមកនូវសេចក្ដីទុក្ខ ដល់បុគ្គលផងដែរ។

## គោលបំណងព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា គឺជាទស្សនវិជ្ជា និងជាសាសនា។ នៅត្រង់ចំណុចនេះ គឺតែងតែមានបញ្ហាចោទឡើងថា តើព្រះពុទ្ធសាសនាគឺជាទស្សនវិជ្ជា ឬជាសាសនា? វាគ្មានបញ្ហាអ្វីទេ ទោះបីបុគ្គលហៅ ព្រះពុទ្ធសាសនា ថាជាសាសនា ឬជាទស្សនវិជ្ជា ឬក៏អ្វីក៏ដោយនោះ។ ទោះបីបុគ្គលចាត់ទុកព្រះពុទ្ធសាសនាជាអ្វីក៏ដោយ ព្រះពុទ្ធសាសនា គឺនៅតែជាព្រះពុទ្ធសាសនាដដែល។ ដូចដែលបុគ្គលហៅផ្កាកូលាប ដោយឈ្មោះទីទៃៗ ប៉ុន្តែ ក្លិនរបស់វាគឺនៅតែជាក្លិនផ្កាកូលាប។ ក្នុងករណីនេះ សច្ច ក៏ដូចគ្នាដែរ មិនថាព្រះពុទ្ធសាសនា គ្រីស្តសាសនា ឥស្លាមសាសនា ឬព្រហ្មញ្ញសាសនាឡើយ សច្ច គឺមិនមែនជាសាសនារបស់បុគ្គលណាមួយឡើយ។ មេត្តាធម៌ ករុណាធម៌ គឺជាច្បាប់ធម្មជាតិដែលមនុស្សត្រូវតែប្រព្រឹត្ត ហើយវាមិនមែនជាកម្មសិទ្ធិ របស់សាសនាណាមួយឡើយ ហើយព្រះពុទ្ធសាសនាគឺជាវិថីនៃជីវិត។ ព្រះសម្ពុទ្ធជាម្ចាស់នៃយើងទ្រង់មានព្រះ-ទ័យទុកដាក់ក្រៃលែង ក្នុងការបង្រៀនប្រៀនប្រដៅ ដល់មុនស្សលោកទាំងឡាយ ដោយទ្រង់យល់ឃើញថា អ្នកទាំងនោះនឹងបានទទួលផលល្អជាច្រើន អំពីពាក្យប្រៀនប្រដៅរបស់ព្រះអង្គ។ បន្ទាប់ពីបានសម្រេចនូវសម្មាសម្ពោធិញ្ញាណភ្លាម ព្រះអង្គទ្រង់បានបញ្ជូនសាវ័ករបស់ព្រះអង្គ ចំនួន៦០ អង្គ ដែលសុទ្ធសឹងជាព្រះអរហន្ត ទៅគ្រប់ទិសទី ដើម្បីផ្សព្វផ្សាយនូវព្រះធម៌ដ៏ថ្លៃថ្លានេះ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់មនុស្សសត្វទូទៅ។ ព្រះធម៌ដ៏ថ្លៃថ្លានេះ បង្ហាញដល់មនុស្សឱ្យឃ្លាតចាកឆ្ងាយ ពីសេចក្តីទុក្ខវេទនាក្នុងជីវិត " **ចរថ ភិក្ខវេ ......ពហុជន ហិតាយ......**" (មហាវគ្គ)។

ព្រះពុទ្ធសាសនា បានផ្ដល់ដំបូន្មានដ៏ល្អៗជាច្រើន សម្រាប់ការអភិវឌ្ឍន៏សង្គម សម្រាប់ធ្វើឱ្យមនុស្ស ចេះយោគយល់ចំពោះគ្នានឹងគ្នា និងធ្វើឱ្យមានសហប្រតិបត្តិការល្អ រវាងមនុស្សទាំងឡាយក្នុងសង្គម ដើម្បីឆ្ពោះទៅកាន់ការរីកចំរើនរុងរឿង។ ព្រះពុទ្ធសាសនា បានទូន្មានដល់មនុស្សខ្វះការសាមគ្គី ឱ្យមានការសាមគ្គី អ្នកដែលមានគោលជំហរទន់ខ្សោយ ឱ្យមានគោលជំហររឹងមាំ បង្កើតឱ្យមានជំនឿទុកចិត្តលើខ្លួនឯង ចំពោះមនុស្សដែលគ្មានជំនឿទុកចិត្តលើខ្លួនឯង ជម្រុញ ដាស់តឿន ចំពោះអ្នកដែលមានភាពខ្ជិលច្រអូស ឱ្យមានភាពឧស្សាហ៏ ព្យាយាម ប្រឹងប្រែងឡើង។ល។ ទាំងអស់នេះគឺជាពាក្យទូន្មានល្អៗ ដែលព្រះអង្គទ្រង់ប្រទានដល់មនុស្សទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខ ក្នុងលោកនេះ និងលោកខាងនាយ។

ព្រះពុទ្ធសាសនា មានការយកចិត្តទុកដាក់ណាស់ ចំពោះជីវិតបច្ចុប្បន្ន និងអនាគត។ ក្នុងចំណុចនេះ ព្រះអង្គទ្រង់ចង្អុលបង្ហាញថា សេចក្ដីសុខក្នុងជាតិខាងមុខ គឺវាអាស្រ័យទៅលើជីវិតរស់នៅ របស់បុគ្គលនៅក្នុងបច្ចុប្បន្ននេះដែរ។ ប្រសិនបើបុគ្គលជាមុនស្សក្រីក្រ រស់នៅរងទុក្ខវេទនា គ្មានទ្រព្យសម្បត្តិ ដើម្បីធ្វើបុណ្យទាន សំរាប់ជាស្បៀង តើធ្វើយ៉ាងណានឹងបានទទួលនូវសេចក្ដីសុខ ក្នុងជាតិខាងមុខ?។ ព្រះពុទ្ធសាសនា បានផ្ដល់នូវដំបូន្មាន ខ្សែបន្ទាត់ដល់បុគ្គលទាំងឡាយ ដើម្បីដឹកនាំជីវិតរបស់ពួកគេ ឱ្យដើរលើវិថីត្រូវ ឆ្ពោះទៅកាន់ភាពស្ងប់ស្ងាត់ និងសេចក្ដីសុខ។ ធ្វើដូច្នេះបុគ្គលម្នាក់ៗ អាចរស់នៅបានសេចក្ដីសុខ ក្នុងពេលបច្ចុប្បន្ន និងធានាការនាំមកនូវសេចក្ដីសុខ ក្នុងអនាគតជាតិ។ ទោះបីជាព្រះពុទ្ធសាសនា មានអាយុកាលជិត

២៦០០ឆ្នាំ មែនពិត តែព្រះធម៌របស់ព្រះអង្គ នៅតែមានលក្ខណៈជាសាកល អាច អនុវត្តបាន គ្រប់កាលៈទេសៈ និងគ្រប់ក្នុងសង្គមមនុស្សទាំងអស់ក្នុងលោក។ ព្រះពុទ្ធ-សាសនា បានត្រួសត្រាយផ្លូវចង្អៀត និងឧបសគ្គ ដែលបែងចែកវណ្ណៈមនុស្សក្នុងសង្គម ហើយទ្រង់បានបង្ហាញនូវទស្សនៈថា មនុស្សលោកម្នាក់ៗ មានសណ្ឋានទ្រុងទ្រាយ លក្ខណៈ ដូចគ្នាតែម្យ៉ាងប៉ុណ្ណោះ។ ព្រះពុទ្ធសាសនា បានទទួលស្គាល់ថា មនុស្សគ្រប់ រូបក្នុងលោកនេះ ស្រឡាញ់ចូលចិត្តណាស់ ចង់បានណាស់ នូវសេចក្តីសុខ ហើយមិន ចង់ជួបទេសេចក្តីស្លាប់ និរាសព្រាត់ប្រាស់។

គោលបំណងព្រះពុទ្ធសាសនា គឺចង់ឱ្យមនុស្សបានសេចក្តីសុខ តាមរយៈការ គោរពប្រតិបត្តិ ព្រហ្មចរិយៈធម៌ លះបង់ទ្រព្យសម្បត្តិ ផ្ទះសំបែង ហើយចូលសាង ផ្នួស។ ប៉ុន្តែទ្រង់យល់ឃើញថា រឿងនេះគឺវាមិនអាចធ្វើទៅបាន ចំពោះមនុស្សភាគ ច្រើន។ ដូច្នេះហើយ បានជាព្រះពុទ្ធសាសនា ណែនាំបុគ្គលឱ្យដើរលើវិធីល្អ ត្រឹមត្រូវ ទាំងបព្វជិត ទាំងគ្រហស្ថ។ ការប្រតិបត្តិនេះ គឺវាមានសារៈប្រយោជន៍ណាស់ សម្រាប់ ជាជំនួយដល់សតិស្មារតី និងបញ្ញារបស់អ្នកដែលប្រាថ្នាស្វែងរក នូវសេចក្តីសុខ ។ ការ លះបង់ទ្រព្យសម្បត្តិ ហើយចូលសាងផ្នួស បុគ្គលមានឱកាសច្រើន ក្នុងការប្រតិ បត្តិព្រះធម៌ ហើយនឹងអាចសម្រេចគោលដៅ បានយ៉ាងឆាប់រហ័សទៀតផង។ គោល ដៅនេះ គឺព្រះនិព្វាន សូម្បីតែគ្រហស្ថក៏អាចសម្រេចបានដែរ ប៉ុន្តែមិនរហ័សដូចបព្វជិត ព្រោះគ្រហស្ថនៅជាប់ជំពាក់នឹងពលិពោធច្រើន។ ការប្រៀបធៀបនេះ បានចែងនៅ ក្នុង មុនិសូត្រ ថា " ដូចជាសត្វក្ងោកមានកខៀវ ហើរតាមអាកាស មិនដល់សន្ទុះរបស់

ហង្សយ៉ាងណា គ្រហស្ថក៏យ៉ាងនោះដែរ នឹងធ្វើតាមភិក្ខុជាមុនិ អ្នកស្ងប់ស្ងាត់ អ្នកចំរើនឈានក្នុងព្រៃមិនបាន" - មុនិសូត្រ សុត្តនិបាត (៩៨)៧២ ។

"Even as a crested peacock, blue neck that soars in the sky never will reach the speed of the swan, even so the householders cannot emulate to match the monk, the sage leading the life of seclusion, contemplating in the forest"-Muni Sutta (stanza 221) p.83, Suttanipata Text and Translation by N A Jayawickrama

ទោះបីជាឃើតផ្នែកខាងការវិវឌ្ឍន៍នៃផ្លូវចិត្ត និង បញ្ញា បើប្រៀបធៀបទៅនឹងបព្វជិត ប៉ុន្តែ សក្ដានុពលនៃការសម្រេចព្រះនិព្វាន របស់គ្រហស្ថគឺមានដូចជាបព្វជិតដែរ។ ដំណើរឆ្ពោះទៅកាន់ការសម្រេចព្រះនិព្វាន អាចប្រព្រឹត្តទៅបានលុះត្រាតែគ្រហស្ថ អាចជម្រះនូវឧបសគ្គ ដែលនៅរាំងស្ទះផ្លូវរបស់គេ។ នៅត្រង់ចំណុចនេះព្រះពុទ្ធសាសនា ក៏មិនបានបំភ្លេចចោលនូវសេចក្ដីសុខ ជាជីវិតឃរាវាសដែរ ដូច្នេះហើយបានជា ព្រះអង្គទ្រង់ដាក់ចុះនូវច្បាប់សម្រាប់គ្រហស្ថ គោរពប្រតិបត្តិ។ មានព្រះសូត្រជាច្រើនដែលព្រះអង្គទ្រង់សំដែង ក្នុងគោលបំណងនេះ ហើយក្នុងចំណោមព្រះសូត្រទាំងនោះ មានដូចជា **សិង្គាលកសូត្រ បរាភវសូត្រ វសលសូត្រ មង្គលសូត្រ**......។ ទ្រឹស្ដីដ៏មានសារៈប្រយោជន៍ ដែលមាននៅក្នុងព្រះសូត្រទាំងអស់នោះ គឺមិនសម្រាប់ចំពោះតែបុគ្គល អ្នកកាន់ព្រះពុទ្ធសាសនាប៉ុណ្ណោះទេ តែក៏សម្រាប់មនុស្សគ្រប់រូបក្នុងលោកនេះ ទោះបីជា ជាតិសាសន៍អ្វីក៏ដោយ។

## តើសេចក្តីសុខអាស្រ័យនៅលើចំនួននៃទ្រព្យសម្បត្តិឬ?

បុគ្គលមួយចំនួនគិតថា សេចក្តីសុខគឺអាស្រ័យនៅលើចំនួន នៃទ្រព្យសម្បត្តិដែលខ្លួនមាន។ ប្រសិនបើការគិតនោះត្រឹមត្រូវពិតប្រាកដមែន អ៊ីចឹង សេចក្តីសុខច្រើន គឺអ្នកមានទ្រព្យសម្បត្តិច្រើន។ ប៉ុន្តែនេះគឺមិនមែនជាទស្សនៈត្រឹមត្រូវឡើយ។ សេចក្តីសុខ គឺជាសភាវៈមួយដែលប្រព្រឹត្តទៅតាមផ្លូវចិត្តារម្មណ៍ ហើយគឺជាការសប្បាយរីករាយពិតមួយ ដែលកើតមកពីផលនៃការបណ្តុះផ្សាំ នូវសេចក្តីសុខនេះឯងតែម្តង។ ប្រសិនបើកិរិតនៃសេចក្តីសុខ ដែលបុគ្គលទទួលបាន អាស្រ័យនៅលើចំនួននៃទ្រព្យសម្បត្តិដែលខ្លួនមានពិតមែននោះ អ៊ីចឹង គឺបុគ្គលមិនអាចបញ្ចប់ នូវការបន្តប្រមូលផ្តុំនៃទ្រព្យសម្បត្តិនោះឡើយ។

ដូច្នេះហើយបានជាព្រះពុទ្ធសាសនា បញ្ជាក់នូវកត្ថាដ៏សំខាន់មួយថា **សន្តុដ្ឋី បរមំ ធនំ-Santuṭṭhī Paramam Dhanam** that means, *Contenment is the highest wealth* ប្រែថាៈ ការមានសេចក្តីសន្តោស គឺជាទ្រព្យដ៏ឧត្តម។ **សន្តុដ្ឋី** ឬការសន្តោសនេះ គឺបានន័យថា ការសប្បាយរីករាយចិត្ត ការពេញចិត្តជាមួយនឹងអ្វីដែលខ្លួនមាន។ ផ្អែកទៅលើទស្សនៈនេះ បុគ្គលម្នាក់ៗគប្បីអប់រំទូន្មានខ្លួនឯង ឱ្យទៅជាអ្នកគ្រប់គ្រាន់ សប្បាយពេញចិត្ត ជាមួយទ្រព្យសម្បត្តិរបស់ខ្លួន។ ដូច្នេះហើយបានជាព្រះពុទ្ធសាសនា សំដែងអំពី " **អត្ថិសុខ** " ដែលជាសុខមួយ ក្នុងចំណោមសុខទាំង ៤ របស់គ្រហស្ថ។ បុគ្គលអាចទទួលបាននូវសេចក្តីសុខប្រភេទនេះ នៅពេលណាដែលបុគ្គលដឹងថា ខ្លួនមានទ្រព្យសម្បត្តិគ្រប់គ្រាន់។ លក្ខណៈនេះ គឺធ្វើឱ្យបុគ្គលមាន

សេចក្ដីសុខ សេចក្ដីសប្បាយរីករាយល្មមគ្រប់គ្រាន់ ហើយធ្វើឱ្យបុគ្គលបញ្ឈប់ នូវការប្រណាំងប្រជែង រត់ប្រដេញតាមការវិវឌ្ឍន៍ ផ្លាស់ប្ដូរទៅនៃគោលបំណង ហើយអាចបង្រ្កាបនូវ តណ្ហាមិនចេះចប់នេះ។

ការត្រេកអរពេញចិត្តចំពោះតែវត្ថុ ឬទ្រព្យសម្បត្តិដែលខ្លួនមានឬការសន្ដោសនេះ អនុញ្ញាតឱ្យបុគ្គលឈប់ប្រណាំងប្រជែង ជាមួយនឹងតណ្ហា ហើយអាចបន្ធូរបន្ថយនូវអារម្មណ៍តានតឹង ដែលកើតអំពីចំណង់ ចំពោះកម្មវត្ថុទាំងឡាយ។ បុគ្គលមួយចំនួនគ្មានសេចក្ដីសុខ មានការតានតឹង អន្ទះអន្ទែង គឺមិនមែនដោយសារពួកគេ គ្មានទ្រព្យសម្បត្តិល្មមគ្រប់គ្រាន់នោះទេ ប៉ុន្ដែដោយសារពួកគេមិនសប្បាយ មិនឆ្អែតឆ្អន់ មិនស្កប់ស្កល់ ជាមួយនឹងអ្វីដែលគេមាន។ ដោយសារការរត់ប្រដេញតាមពីខាងក្រោយកម្មបទនៃចំណង់តណ្ហាបុគ្គលផ្លាស់ប្ដូរវាល់ " *ការចង់បាន* " ទៅជា " *សេចក្ដីត្រូវការ* " ហើយព្យាយាមខ្លាំងក្លា ដែលប្រកបទៅដោយគ្រោះថ្នាក់ ដើម្បីឱ្យបានសម្រេចតាមគោលបំណងរបស់ខ្លួន។ ប្រការនេះ នឹងមិនអាចឈានចូលទៅកាន់ទីបញ្ចប់ នៃចំណង់ឡើយ ពីព្រោះសម្រាប់ចំណង់ គឺមិនអាចបំពេញបានឡើយ។ ចំណង់ដែលមិនអាចបំពេញបាន គឺតែងតែជាឧបសគ្គ នៃសេចក្ដីសុខរបស់មនុស្សគ្រប់រូបក្នុងលោក។ ដូច្នេះ ការរស់នៅតាមមានតាមបាន ការគ្រប់គ្រាន់ ការសប្បាយរីករាយពេញចិត្ត ជាមួយវត្ថុដែលខ្លួនមាន គឺជាកត្តាសំខាន់ ដែលនាំមកនូវសេចក្ដីសុខបច្ចុប្បន្ន។ ដូច្នេះ សេចក្ដីសន្ដោស-(Contentment) គឺជាសេចក្ដីសុខដ៏ឧត្ដមមួយ របស់មនុស្សក្នុងលោក។ សេចក្ដីសន្ដោស ទោះបីជាយ៉ាងណាក៏ដោយ គឺមិនគួរត្រូវបានពិចារណា ក្នុងឥរិយាបថ

នៃគំនិតដែលពឹងផ្អែកទៅលើព្រេងវាសនា ឬព្រហ្មលិខិត ហើយមិនខិតខំប្រឹងប្រែងរកទ្រព្យសម្បត្តិនោះឡើយ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់មិនដែលបានជម្រុញ និងលើកទឹកចិត្តឱ្យបុគ្គលណាម្នាក់ ឱ្យពឹងផ្អែកទៅលើព្រេងវាសនា ឬព្រហ្មលិខិតឡើយ ។ តែផ្ទុយទៅវិញ ព្រះអង្គទ្រង់តែងតែលើកទឹកចិត្ត ដាស់តឿនក្រើនរំលឹកមនុស្សទាំងឡាយ ឱ្យមានវីរិយៈភាព ខិតខំប្រឹងប្រែង ធ្វើកិច្ចការ រកទ្រព្យសម្បត្តិ តាមសម្មាអាជីវៈ គឺការចិញ្ចឹមជីវិតត្រូវ តាមគន្លងធម៌ ហើយដឹកនាំជីវិតរបស់ខ្លួនប្រកបដោយសុភមង្គល។ ការចង្អុលបង្ហាញនេះ គឺយោងទៅលើទ្រឹស្តីមួយថា "**អប្បមាទោ**" ដែលមានអត្ថន័យថា ការមិនប្រមាទឬការយកចិត្តទុកដាក់។ ការប្រមាទ ការផ្អាក ឬការពន្យាពេលពីការងាររបស់ខ្លួន ស្វែងរកការអនុគ្រោះសូមទោស មិនយកចិត្តទុកដាក់ចំពោះកិច្ចការងារ គឺត្រូវបានជំទាស់ជាសាធារណៈ ក្នុងព្រះពុទ្ធសាសនា។ នៅក្នុង **បរាភវសូត្រ** មានគាថាមួយកន្លែងបានពោលថា " ការខ្ជិលច្រអូស" គឺជាហេតុមួយដែលនាំមកនូវសេចក្តីវិនាស។ ទាំងពីរផ្នែក គឺការរីកចំរើនផ្នែកខាងផ្លូវចិត្តសតិបញ្ញា និងផ្នែកខាងផ្លូវសម្ភារៈ គឺអាស្រ័យទៅលើធម៌មិនប្រមាទ ហើយខិតខំ ប្រឹងប្រែងព្យាយាមខ្ពស់ ព្រមជាមួយនឹងភាពវៃឆ្លាត របស់បុគ្គលខ្លួនឯង។ ត្រង់ចំណុចនេះមានគាថាមួយកន្លែងក្នុងធម្មបទបានចែងថា: **អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ អប្បមាទេ ន មីយន្តិ យេ បមត្តា យថា មតា**.......ប្រែថា: *សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ អ្នកដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ អ្នកដែលប្រមាទហើយ ប្រៀបដូចជាបុគ្គល*

*ដែលស្លាប់ទៅហើយ.........គាថាធម្មបទប្រែ. ៣៤*។

នៅក្នុងធម្មបទដដែលនេះ មានគាថាមួយកន្លែងទៀតពោលថា : **ឧដ្ឋានេន~ ប្បមាទេន សញ្ញមេន ទមេន ច ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ**។ ប្រែថា: *កិលេសប្រៀបបានដូចជាទឹកជំនន់លិចទីពឹងពុំបាន អ្នកប្រាជ្ញធ្វើខ្លួនឯងជាទីពឹងដោយសេចក្ដីព្យាយាម ប្រឹងប្រែងដោយការមិនប្រមាទ ដោយការសង្រួម និង ដោយការអប់រំទូន្មានខ្លួន*។

ដូច្នេះ បុគ្គលមិនគប្បីធ្វើឱ្យច្របូកច្របល់ យល់ច្រឡំ រវាងការសន្តោស-(Contentment)និង និទ្រានុភាព (Lythargy) ឡើយ។ ការប្រមាទ ភាពខ្ជិលច្រអូស ការមិនយកចិត្តទុកដាក់ ហើយគិតរំពឹង ទៅលើព្រេងវាសនា ឬព្រហ្មលិខិត បុគ្គលមិនអាចអភិវឌ្ឍ ស្ថាបនាសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ខ្លួនឱ្យប្រសើរ ឆ្ពោះទៅរកសេចក្ដីសុខ សុភមង្គល ក្នុងឆាកលោកនៃជីវិតដ៏សែនលំបាកនេះបានឡើយ។

## ឧបសគ្គនៃសេចក្តីសុខ

គ្មានបុគ្គលណាម្នាក់ចង់រស់នៅពឹងផ្អែកទៅលើ ការចិញ្ចឹមជីវិតខុសឡើយ "**មិច្ឆាអាជីវ**" ពីព្រោះគេដឹងថា ទង្វើទាំងអស់នេះគឺវា ប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរចំពោះគ្រួសារគេ។ ជីវិតគ្រួសារធ្វើដំណើរទៅបានស្រួល លុះត្រាតែមានអំពើល្អ បំណងល្អ ការយកយល់ចិត្តគ្នា និងសហប្រតិបត្តិការល្អ រវាងគ្នាទៅវិញទៅមក។ ប៉ុន្តែ រំពេចនោះ ក៏អាចមានឧបសគ្គ និងឧបទ្ទវហេតុអ្វីកើតឡើង ដោយមិនបានគិតទុកមុន។ ដូច្នេះបុគ្គលម្នាក់ៗ ត្រូវតែមានសតិសម្បជញ្ញ រលឹកជាប់ជានិច្ចគ្រប់ពេលវេលា សំឡឹងមើលរឿងអាស្រូវ ទោសកំហុសទាំងនោះ ដែលនឹងអាចមានឥទ្ធិពលអាក្រក់ដល់សេចក្តីសុខក្នុងគ្រួសារ។

មានលក្ខណៈច្រើនយ៉ាងណាស់ ដែលឥទ្ធិពលនេះអាចកើតឡើង ប្រសិនបើបុគ្គល មិនបានធ្វើការពិនិត្យ ស្រាវជ្រាវដោយយកចិត្តទុកដាក់ ហើយដាក់វិធានការដើម្បីទប់ស្កាត់ទេនោះ។ ដើម្បីចាប់ផ្តើមអនុវត្តនូវវិធានការនេះ វិធីល្អនោះគឺរាល់សមាជិកក្នុងសង្គមគ្រួសារគប្បីរក្សាសីល ដោយយកចិត្តទុកដាក់បំផុត។ ការរក្សាសីលនេះមិនមែនមានន័យថាគ្រាន់តែសូត្រទន្ទេញ ដោយចាំមាត់ៗគ្នានោះទេ ប៉ុន្តែ ត្រូវប្រតិបត្តិជារៀងរាល់ថ្ងៃ។ ការរក្សាសីល៥ គួរតែបានធ្វើឡើងទុកជាគ្រឹះដ៏រឹងមាំដើម្បីបង្កើតនូវសេចក្តីសុខ សន្តិភាព ក្នុងគ្រួសារ។ ការប្រព្រឹត្តប្រតិបត្តិដូច្នេះ គួរតែធ្វើឡើងជាមធ្យោបាយ ដើម្បីការពារប្រឆាំង ទៅនឹងបញ្ហាប្រេះឆាក្នុងគ្រួសារ។ ការរក្សាសីលនេះនឹងអាចដឹកនាំគ្រួសារដើរលើវិថីល្អសមរម្យ។ នៅពេលណា រាល់សមាជិកគ្រួសារ

ទាំងអស់ តម្កល់ខ្លួនបានល្អប្រពៃលើគុណធម៌ សីលធម៌ ហើយការធ្លាក់ចេញពីវិធីនៃសុភមង្គលរបស់គ្រួសារ នឹងមិនអាចកើតមានឡើងបានឡើយ។ ដូច្នេះឧបសគ្គ នៃសេចក្តីសុខ ដែលកើតពីការចិញ្ចឹមជីវិតខុស ក៏មិនអាចកើតមានឡើងបានដែរ។

# សារៈសំខាន់នៃសេដ្ឋកិច្ច

ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងសង្គមគ្រួសារគឺជាកត្តាដ៏ចាំបាច់និងមានសារៈសំខាន់ណាស់ ក្នុងការស្ថាបនា និងធានាឱ្យបាននូវសុវត្ថិភាពសុភមង្គលគ្រួសារ។ ដូច្នេះ រាល់សមាជិកគ្រួសារទាំងអស់ ត្រូវតែរកវិធី ឬមធ្យោបាយធ្វើយ៉ាងណា ក្នុងការស្វែងរកទ្រព្យសម្បត្តិឱ្យបាន។ ប៉ុន្តែត្រូវចងចាំថា រាល់វិធី និងមធ្យោបាយទាំងនោះ គឺប្រកបដោយសម្មាអាជីវៈ មានន័យថា ការរកស៊ីចិញ្ចឹមជីវិតត្រូវ ជាពិសេសគឺការវៀរចាកការធ្វើជំនួញ៥ ប្រការ ដូចជាការជួញអាវុធ គ្រឿងផ្ទុះ គ្រឿងញៀន គ្រឿងស្រវឹងជាដើម។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់បង្រៀនថា បុគ្គលគប្បីស្វែងរកទ្រព្យសម្បត្តិ ដោយសេចក្តីព្យាយាម និងដោយកំលាំងញើសឈាមរបស់ខ្លួន។ បុគ្គលអ្នកប្រកបមុខរបរខុស មិនត្រឹមត្រូវតាមច្បាប់ ប្រើមធ្យោបាយអាក្រក់ ដូចជាលួចប្លន់ឆបោក កេងប្រវ័ញ្ច ចាប់ជំរិត ។ល។ បុគ្គលជំពូកនេះ ទោះបីមានការរីកចំរើនផ្នែកខាងសេដ្ឋកិច្ច ក៏គ្មានសចក្តីសុខ សន្តិភាពខាងផ្លូវចិត្តឡើយ។ ពួកគេក្លាយទៅជាអ្នកមានការព្រួយបារម្ភ អន្ទះអន្ទែង ភ័យខ្លាច សង្ស័យថាពិភពលោកនឹងលាតត្រដាងនូវអំពើអាក្រក់របស់ពួកគេ នៅថ្ងៃណាមួយមិនខាន។ ដូច្នេះ នឹងធ្វើឱ្យពួកគេអាម៉ាស់មុខហើយជួនកាលនឹងត្រូវបានពិភពលោកដាក់ទណ្ឌកម្មទៀតផង។ យល់ច្បាស់ យ៉ាងនេះហើយ ទន្ទឹមនឹងការវិវឌ្ឍន៍ រីកចំរើនខាងសេដ្ឋកិច្ច ហើយដើម្បីជាប្រយោជន៍ ដល់សេចក្តីសុខក្នុង សង្គមគ្រួសារ រាល់សមាជិកទទួលខុសត្រូវទាំងអស់ គួរតែប្រកបមុខរបរណា ដែលត្រឹមត្រូវតាមច្បាប់រដ្ឋ និងសាសនា "**សម្មាអាជីវ**"។ អ្វីដែលបុគ្គល

ត្រូវតែពិចារណានោះ គឺមិនសំដៅទៅលើឋានៈនៃមុខរបរឡើយ ប៉ុន្តែលក្ខណៈដំបូងដែលគួរពិចារណានោះ គឺមុខរបរ ឬអំពើទាំងឡាយណាដែលត្រឹមត្រូវ។ បុគ្គលមិនអាចក្លាយទៅជា វេជ្ជបណ្ឌិត វិស្វករ ឬអ្នកជំនួញដ៏មានជ័យជំនះ គ្រប់ៗគ្នានោះទេ។ បុគ្គលខ្លះមានមុខរបរតូចតាច តែសមស្របទៅតាមសម្មាអាជីវៈ ប្រកបដោយគន្លងធម៌ត្រឹមត្រូវ ដូច្នេះ បុគ្គលជំពូកនេះ គង់នឹងមានសេចក្ដីសុខខាងផ្លូវចិត្ត ជាងបុគ្គលដែលមានមុខរបរធំដុំ ក្នុងផ្លូវខុសដែរ។ ទោះបីជាមានបញ្ហាលំបាកខ្លះៗផ្នែកខាងសេដ្ឋកិច្ចគ្រួសារ ប៉ុន្តែ គេក៏មានសេចក្ដីសុខខាងផ្លូវចិត្តច្រើនដែរ គឺគេគ្មានការព្រួយបារម្ភ ឬភ័យខ្លាចពីសកម្មភាព ឬ អំពើរបស់គេឡើយ។

នៅក្នុង **មហានិទានសូត្រ** ព្រះអង្គទ្រង់បានសំដែងផងដែរថា **ឧបាទាន** កើតមានព្រោះតណ្ហាជាបច្ច័យ ហើយប្រសិនបើ តណ្ហាមិនកើតឡើងទេ ឧបាទានក៏មិនមានដែរ។ ត្រង់ចំណុចនេះបញ្ជាក់ឱ្យឃើញថា តណ្ហាគឺជាហេតុនៃអកុសលធម៌ដ៏ មានឥទ្ធិពលនាំយើងឱ្យធ្លាក់ចុះក្នុងរណ្ដៅនៃគ្រោះមហន្តរាយ.......*មហានិទានសូត្រ (១៦) ១២៣*។

## តើយើងមានសេចក្ដីសុខទេ?

ឥឡូវនេះ យើងទាំងអស់គ្នាកំពុងតែរស់នៅ ក្នុងសតវត្សរ៍ទី២១។ នេះគឺជាសហស្សវត្សរ៍ថ្មី នៃប្រវត្តិសាស្ត្រមនុស្សជាតិ ដែលសន្យាថានឹងផ្ដល់ឱ្យប្រជាជននូវការអភិវឌ្ឍន៍រីកចំរើនផ្នែកខាងសម្ភារៈ ដែលគេមិនធ្លាប់បានយល់សុបិនពីមុនកម។ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដ៏ទំនើបទាន់សម័យនេះ កំពុងតែលោតផ្លោះបោះជំហានយ៉ាងលឿន នាំមកនូវភាពរុងរឿងក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ ការអភិវឌ្ឍន៍រីកចំរើនក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទាំងនេះ បានប្រែក្លាយពិភពលោកដ៏ធំមហិមាឱ្យក្លាយទៅជាកន្លែងមួយដ៏តូច ដែលងាយស្រួលក្នុងការឆ្លងកាត់។ សូម្បីតែឋានសួគ៌ដែលយើងទាំងអស់គ្នា ធ្លាប់បានដឹង បានឮតាមរយៈក្បួនច្បាប់ គម្ពីរដីកា ឥឡូវនេះ យើងរាប់គ្នាហាក់បីដូចជាបានស្គាល់ និងភ្លក់រសជាតិឋានសួគ៌ លើលោកនេះតែម្ដង ដែលបុគ្គលមួយចំនួនតែងពោលថា ឋានសួគ៌លោកីយ៍នោះ។ ទោះបីជាមានការរីកចំរើន ជឿនលឿនទៅមុខ ជាមួយនឹងសម្ភារៈទាំងនោះ តើយើងមានសេចក្ដីសុខឬទេ ?។ យើងម្នាក់ៗត្រូវតែសួរខ្លួនឯង ពិនិត្យសង្កេតមើលឱ្យបានជ្រៅ ទៅក្នុងសតិវិញ្ញាណរបស់ខ្លួនឱ្យពិតប្រាកដទៅនឹងបញ្ហានេះ។ និយាយតាមការណ៍ពិតទៅ យើងមិនអាចឆ្លើយទៅនឹងសំណួរទាំងនេះ ជាវិជ្ជមានបានឡើយ។ ការតានតឹង ការទុក្ខព្រួយ ក្ដីបារម្ភ ការមន្ទិលសង្ស័យ ការខកចិត្ត ការច្រណែនប្រច័ណ្ឌ និន្ទាឈ្នានីស ការគុំកួន ការចងពៀរ អំពើហិង្សា ការប្រណាំងប្រជែង ។ល។ និង ។ល។ បានដក់ជាប់នៅក្នុងដួងចិត្តរបស់យើងរាល់ថ្ងៃស្ទើរតែគ្រប់គ្នា។ ប្រសិនបើអកុសលធម៌ទាំងអស់នេះ បានកំពុងតែ

ធ្វើសកម្មភាពនៅក្នុងដួងចិត្ត ដឹកនាំជីវិតយើងគ្រប់គ្នារាល់ថ្ងៃឥតមានពេលល្ហែដូច្នោះ តើសេចក្តីសុខ សន្តិភាពផ្លូវកាយ និងផ្លូវចិត្តរបស់យើងអាចកើតឡើងបានទេ? ដូច្នេះ យើងក៏បានយល់ថា យើងគ្មានទេសេចក្តីសុខ។ អ្នកក្រប្រាថ្នាមាន រីឯអ្នកមានខំប្រឹង ប្រាថ្នាមានថែមទៀត មិនចេះចប់មិនចេះហើយ។ ការរីវឌ្ឍនីរីកចំរើនទៅក្នុងវិស័យ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដ៏ទំនើបទាន់សម័យ ក្នុងសហស្សវត្សថ្មីនេះ បានធ្វើឱ្យ មនុស្សគ្រប់រូប ប្រណាំងប្រជែងនឹងជីវិត ជាមួយនឹងសង្គ្រាមសេដ្ឋកិច្ច ដើម្បីបំពេញនូវ បំណងរបស់ខ្លួន ដែលដឹកនាំដោយតណ្ហា។ ដូច្នេះហើយបានជាមានទស្សនៈមួយថា *ដរាបណាគេមានទ្រព្យសម្បត្តិច្រើន ដរាបនោះគេក៏មានសេចក្តីសុខច្រើនដែរ*។

ក្នុងការស្វែងរកសេចក្តីសុខនេះ តើយើងប្រមូលបានអ្វីខ្លះ? ជូនកាលមានមតិ មួយចំនួនថា យើងប្រមូលបានទ្រព្យសម្បត្តិ លុយកាក់ និងវត្ថុដ៏មានតម្លៃផ្សេងៗ ទៀត។ ប៉ុន្តែតាមការណ៍ពិត យើងគ្មានលទ្ធភាពនឹងប្រមូលបាន នូវទ្រព្យសម្បត្តិទាំង នោះ ក្រៅពីការប្រមូលផ្តុំ នូវការច្រណែននិន្ទា ឈ្នានីស ការប្រណាំងប្រជែង ភាពភ័យ ខ្លាច ក្តីកង្វល់ ក្តីបារម្ភ ។ល។ ដែលជាឫសគល់នៃអកុសលធម៌ឡើយ។ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃផ្សេងៗ គ្រាន់តែជាអាការៈសម្ភារៈខាងក្រៅ ដែលជាប់ជំពាក់នៅក្នុង ដួងចិត្តរបស់យើង ដែលប្រកបទៅដោយការពេញចិត្ត និងការមិនពេញចិត្ត បណ្តាល មកពីលោភ ទោស និងមោហៈ តែប៉ុណ្ណោះ។

ដូច្នេះហើយ បានជាយើងគ្មានការសប្បាយរីករាយ និងគ្មានសេចក្តីសុខគ្រប់-គ្រាន់ ទោះបីជាយើងមានទ្រព្យសម្បត្តិច្រើនពិតមែន។ នៅពេលយើងរកទ្រព្យសម្បត្តិ

បានហើយ ជំនួសពីការសប្បាយរីករាយ ជាមួយនឹងទ្រព្យសម្បត្តិទាំងនោះ យើងបែរជាចង់បានហើយចង់បានទៀតមិនចេះចប់ មិនចេះហើយ ៗក្លាយខ្លួនទៅជាអ្នករងគ្រោះពីសុវត្ថិភាព នៃការបាត់បង់នូវទ្រព្យសម្បត្តិទាំងនោះទៅវិញ។ ដូច្នេះ ជំនួសពីការសប្បាយ និងសេចក្តីសុខ ដែលកើតពីការមានទ្រព្យ យើងក្លាយខ្លួនទៅជាអ្នករងគ្រោះ អំពីភាពភ័យខ្លាច និងការព្រួយបារម្ភទៅវិញ។ ដូចមានគាថាមួយកន្លែងក្នុងធម្មបទពោលថា **ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ អបិ ទិព្វេសុ**.......មានន័យថា សេចក្តីឆ្អែតឆ្អន់ក្នុងកាមទាំងឡាយ មិនមានព្រោះកហាបណ ធ្លាក់មកបីដូចជាទឹកភ្លៀង កាមទាំងឡាយមានរសជាតិតិចណាស់.......គាថាធម្មបទប្រែ-២៩៥។

យោងតាមទស្សនៈខាងលើនេះ តើបុគ្គលអាចមានសេចក្តីសុខយ៉ាងណា? មានវិធីងាយៗជាច្រើន ដែលបុគ្គលអាចសាកល្បងភ្លក់រសជាតិ នៃសេចក្តីសុខនេះ។ ឧទាហរណ៍ ចូរអ្នកពិនិត្យមើលស្ថានភាព នៅក្នុងជីវិតគ្រួសារមួយ ក្នុងសង្គមសម័យបច្ចុប្បន្ន តើរាល់សមាជិក នៃអ្នកមានទ្រព្យសម្បត្តិទាំងអស់នោះ មានសេចក្តីសុខសប្បាយរីករាយទេ? ហើយតើរាល់សមាជិក នៃអ្នកគ្មានទ្រព្យសម្បត្តិច្រើនមានសេចក្តីសុខទេ? ចំលើយថា"គ្មាន"។ ដូច្នេះ តើពេលណាទើបសេចក្តីសុខ កើតមានដល់គ្រួសារអ្នកទាំងនោះ? ម្តងទៀត ចំលើយថា"គ្មាន" សេចក្តីសុខនេះ គឺជាការពិសោធន៍មួយដ៏ពិបាកយល់។ វាគឺជាសភាវៈមួយ ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ដែលត្រូវបានបង្កើត និងអប់រំឡើង។ សេចក្តីសុខនេះ គឺមិនអាស្រ័យទៅលើចំនួន នៃទ្រព្យសម្បត្តិ

កិត្តិយស មុខងារ អំណាច ឬសញ្ញាប័ត្រ ដែលបុគ្គលមាននោះទេ។ តែវាអាស្រ័យទៅលើគំនិត មធ្យោបាយ ចំពោះជីវិតរបស់ខ្លួន និងអ្នកដទៃ ហើយត្រៀមជាស្រេចដើម្បីសម្របសម្រួលខ្លួន ទៅតាមសង្គម និងស្ថានភាពផ្សេងៗ។ ចំពោះគុណលក្ខណៈទាំងអស់នេះគឺមិនមែនកើតឡើងឯកឯងនោះឡើយ ។ដើម្បីឱ្យមានគុណលក្ខណៈនេះបុគ្គលចាំបាច់ត្រូវតែហ្វឹកហាត់ និងអប់រំខ្លួនឯង។ ត្រង់ចំណុចនេះត្រូវតែមានកន្លែង ចាប់ផ្ដើម ដូច្នេះ ចូរអ្នកសាកល្បងពិចារណាមើល អំពីគ្រួសាររបស់អ្នកថា តើអ្នកមានសភាពយ៉ាងណា ក្នុងនាមអ្នកជាសមាជិកគ្រួសារមួយ? តើអ្នកមានទំនាក់ទំនងល្អ និងការយោគយល់គ្នា រវាងសមាជិកគ្រួសាររបស់អ្នកឬទេ? តើអ្នកមានការសាមគ្គីជាធ្លុងមួយឬទេ? តើអ្នកមានសហប្រតិបត្តិការល្អ ជាមួយអ្នកដទៃឬទេ? តើអ្នកបានបំពេញតួនាទីរបស់អ្នកបានល្អឬទេ? តើអ្នកមានការឈឺចាប់ដោយសារអ្នកដទៃ ហើយអ្នកដទៃ មានការឈឺចាប់ដោយសារអ្នកឬទេ? ទាំងនេះគឺជាសំណួរ ដែលមនុស្សគ្រប់រូបត្រូវតែពិចារណា។ ប្រសិនបើអ្នកគិតថា ចំលើយទៅនឹងសំណួរទាំងនេះ ជាវិជ្ជមាន អ្នកមិនចាំបាច់ព្រួយបារម្ភឡើយ។ ប៉ុន្តែប្រសិនបើវា ជាអវិជ្ជមានវិញ អ្នកត្រូវសំលឹងមើលឱ្យជ្រៅ រកហេតុ បច្ច័យ និងដំណោះស្រាយជាចាំបាច់។ មានទំនាក់ទំនង និងសហប្រតិបត្តិការល្អ រវាងសមាជិកក្នុងសង្គមគ្រួសារ ពិតជាមធ្យោបាយ និងដំណោះស្រាយដ៏ត្រឹមត្រូវ ដែលនឹងនាំមកនូវសេចក្ដីសុខ សន្តិភាព ដល់គ្រួសាររបស់អ្នក។

## ភាពក្រីក្រជាឫសគល់នៃសេចក្ដីទុក្ខក្នុងលោក

ដំបូន្មាននៅក្នុង **សិង្គាលកសូត្រ** ក៏បានបង្ហាញផងដែរ នូវកត្តាសំខាន់១មួយចំនួន ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ចំពោះសេចក្ដីសុខក្នុងកាមទាំងឡាយរបស់គ្រហស្ថ **គិហិកាមភោគី**។ ដូច្នេះ ករណីនេះ សេដ្ឋកិច្ចគ្រួសាររឹងមាំ គឺជាកត្តាដ៏ចម្បង ។ (មានព្រះសូត្រជាច្រើនដែលបង្ហាញថា ភាពក្រីក្រជាហេតុនាំមកនូវសេចក្ដីទុក្ខ ចំពោះមនុស្សបុថុជ្ជនក្នុងលោកនេះ)។ **ចក្កវត្តិសីហនាទសូត្រ** បានបង្ហាញថា ភាពក្រីក្រគឺជាដើមហេតុដែលនាំមកនូវជម្លោះ សោកនាដកម្ម ។ល។ នៅក្នុងសង្គម។ **ឥណសូត្រ** នៃគម្ពីរអង្គុត្តរនិកាយបានបង្ហាញយ៉ាងច្បាស់ថា ដើមកំណើតនៃសេចក្ដីទុក្ខ និងភាពទុគិតរបស់បុគ្គល គឺជាភាពក្រីក្រនេះឯង។ ព្រះសូត្រនេះបានសំដែងបន្តទៅទៀតនូវហេតុដែលបុគ្គលជាយរាវាស ត្រូវបានជាន់ពន្លិច ដោយភាពក្រីក្រហើយ ធ្លាក់ខ្លួនជាអ្នកជំពាក់បំណុលគេ។ នៅពេលដែលបុគ្គលជំពាក់បំណុលគេ ប្រសិនបើមិនបានបង់ឱ្យគេគ្រប់ចំនួន និងទាន់ពេលកំណត់ទេនោះ នឹងបណ្ដាលឱ្យមានការស្ដីបន្ទោស ហើយទីបំផុតនឹងត្រូវបានគេប្ដឹងចាប់ដាក់ពន្ធនាគារ។

នៅត្រង់ចំណុចនេះ ការមានទ្រព្យសម្បត្តិ គឺជាលក្ខណៈដ៏ចម្បង សម្រាប់សេចក្ដីសុខរបស់ឃរាវាស នាពេលបច្ចុប្បន្នលោកីយ៍នេះ។ ដូច្នេះហើយបានជា **សិង្គាលកសូត្រ** តែងតែដាស់តឿនក្រើនរំលឹក ដល់មនុស្សឱ្យជៀសវាង នូវអំពើអបាយមុខទាំងឡាយ ដែលជាហេតុនាំមកនូវការសូន្យទ្រព្យ ហើយក៏បានដាក់ចុះនូវទំរង់បែបបទ នៃការអភិវឌ្ឍន៍ និងការគ្រប់គ្រងសេដ្ឋកិច្ចរបស់ខ្លួនឱ្យបានល្អ ដោយបែងចែក

ទ្រព្យសម្បត្តិ ដែលរកបានមកជាបួនចំណែក។

នេះគឺជាវិធីដ៏ល្អ ដែលគួរតែត្រូវបានអនុវត្ត ដោយវានឹងផ្តល់ឱ្យនូវប្រយោជន៍គួរជាទីពេញចិត្ត និងធានានូវសុវត្ថិភាពសេដ្ឋកិច្ចគ្រួសារឱ្យបានរឹងមាំ។ ប៉ុន្តែដើម្បីគ្រប់គ្រងសេដ្ឋកិច្ច បុគ្គលត្រូវតែមានទ្រព្យសម្បត្តិ។ នៅក្នុងចំណុចនេះ យើងឃើញថា **បត្តកម្មសូត្រ** នៃគម្ពីរអង្គុត្តរនិកាយ ព្រះអង្គសំដែងអំពីលក្ខណៈ នៃការស្វែងរកទ្រព្យសម្បត្តិ ត្រឹមត្រូវតាមច្បាប់។ បុគ្គលត្រូវតែរកទ្រព្យសម្បត្តិ ដោយសេចក្តីព្យាយាមតាមកំលាំងញើសឈាមរបស់ខ្លួន ហើយប្រកបរបរណា ដែលសមស្របតាមធម៌សម្មាអាជីវ។ មានកត្តាពីរយ៉ាង ដែលយើងគួរយល់ដឹងក្នុងទីនេះ ដើម្បីទុកជាពន្លឺ គឺៈ

១-ព្យាយាមរក

២-ប្រព្រឹត្តតែក្នុងផ្លូវល្អជាមធ្យោបាយក្នុងការប្រកបមុខរបរ។

ទាំងនេះជាកត្តាដ៏សំខាន់ ពីព្រោះព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ក៏ទ្រង់បានសំដែងនៅក្នុង **ព្យគ្ឃបជ្ជសូត្រ** ផងដែរអំពីការព្យាយាមដោយយកចិត្តទុកដាក់ប្រភេទនេះសម្រាប់ជីវិតជ័យជំនះ និងសេចក្តីសុខនៅក្នុងលោកនាពេលបច្ចុប្បន្នជាតិនេះ។ នៅក្នុងព្រះសូត្រដដែលនេះ ព្រះអង្គទ្រង់សំដែងអំពី **ទិដ្ឋធម្មិកត្ថ** ប្រយោជន៍គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ៤ យ៉ាងៈ

១-**ឧដ្ឋានសម្បទា** ការដល់ព្រមដោយសេចក្តីមុតមាំខ្លាំងក្លា គឺសេចក្តីព្យាយាមដោយល្អប្រពៃ ប្រព្រឹត្តតាមផ្លូវសុចរិតយុត្តិធម៌ ព្រោះសេចក្តីព្យាយាមនេះជាគុណប្រយោជន៍អាចហុចផលប្រយោជន៍ផ្សេងៗ នាំឱ្យមានកំលាំងពលំ និងការចិញ្ចឹមជីវិតបានធូរ

ស្បើយ។ ទាំងនេះគឺជាលក្ខណៈដ៏ចម្បង សម្រាប់ជីវិតសុភមង្គលក្នុងពេលបច្ចុប្បន្នកាលនេះ។ កត្តានេះមានលក្ខណៈសំខាន់ណាស់ សម្រាប់យើងទាំងអស់គ្នា ពីព្រោះមានបុគ្គលមួយចំនួនមានទស្សនៈថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា គឺជាពាក្យប្រៀនប្រដៅ ដែលប្រកបទៅដោយទុទិដ្ឋិនិយម ដោយមានជំនឿខុសថា ព្រះពុទ្ធសាសនាបានធ្វើឱ្យអ្នកគោរពតាម មើលជីវិតរបស់ខ្លួនសុទ្ធតែជាទុក្ខគ្រប់ពេលវេលា ហើយធ្វើឱ្យអ្នកទាំងនោះ ពឹងផ្អែកទៅលើព្រេងវាសនា ឬព្រហ្មលិខិត។ បុគ្គលមួយចំនួននោះបានព្យាយាមបង្ហាញ នូវទស្សនៈរបស់គេថា ព្រះពុទ្ធសាសនាមិនបានដាស់តឿនក្រើនរំលឹក ដល់ប្រជាពុទ្ធបរិស័ទ ឱ្យព្យាយាមយ៉ាងខ្លាំង ដើម្បីលើកតំកើងជីវភាពប្រចាំថ្ងៃរបស់ពួកគេ ឱ្យមានសេចក្ដីចំរើននោះទេ។ មានពាក្យប្រៀនប្រដៅជាច្រើន ដែលយើងបានឃើញគឺថា ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់នៃយើង ទ្រង់តែងតែដាស់តឿនក្រើនរំលឹកដល់ពុទ្ធបរិស័ទ ឱ្យមានសេចក្ដីព្យាយាមមុតមាំ ដើម្បីធ្វើជីវិតរបស់គេឱ្យកាន់តែប្រសើរឡើង ទាំងផ្លូវសតិបញ្ញា និង ផ្លូវសម្ភារៈ។ ត្រង់ចំណុចនេះ បានបង្ហាញបញ្ជាក់យ៉ាងច្បាស់ថែមទៀត នូវកត្តាដែលថា ភាពខ្ជិលច្រអូសគឺជាផ្លូវដឹកនាំឆ្ពោះទៅកាន់ការសូន្យទ្រព្យ។

២- **អារក្ខសម្បទា** នេះគឺជាលក្ខណៈ ដែលដល់ព្រមដោយការរក្សាទ្រព្យសម្បត្តិ និងការការពារជាតិ ទឹកដី ព្រៃព្រឹក្សា មច្ឆាជាតិ ព្រំដែន ខេត្តខណ្ឌសីមា ដែលខ្លួនមានស្រាប់ហើយ និងរកបានថ្មី ដោយសុចរិតត្រឹមត្រូវតាមគន្លងធម៌ និងតាមច្បាប់រដ្ឋ។ បើមានសេចក្ដីព្យាយាមល្អ ហើយរកទ្រព្យសម្បត្តិល្មមចិញ្ចឹមជីវិត ដោយសុខស្រួល

ពេខ្វះការរក្សាការពារប្រុងប្រយ័ត្ន ក៏ទ្រព្យសម្បត្តិទាំងនោះ មិនអាចគង់វង្សបានដែរ ។

ដូច្នេះ ត្រូវតែមានការថែរក្សាហ្មត់ចត់មាំទាំថែមទៀត ព្រោះថា ការរក្សានេះជាហេតុយ៉ាងសំខាន់ដែលធ្វើឱ្យមានការវិវឌ្ឍន៍រីកចំរើនផ្នែកសម្ភារៈ ។ជាការណ៍ពិតការរក្សាទ្រព្យ គឺបុគ្គលមានបំណងចង់ធានាសុវត្ថិភាព ជីវភាព សេចក្តីសុខរបស់ខ្លួននិងសុវត្ថិភាពក្នុងសង្គមជាតិផងដែរ ។ដូច្នេះបុគ្គលត្រូវតែមានសតិសម្បជញ្ញ រលឹកជាប់ជានិច្ច នូវឧបទ្ទវហេតុទាំងឡាយ ដែលអាចកើតឡើង ដូចជា ភ្លើងឆេះ ទឹកជំនន់ជន់លិច ចោរលួច ឬប្លន់ ។ល។ ចំណុចនេះ គួរតែត្រូវបានពិនិត្យ ជាមួយនឹងកត្តាដែលបានចែងនៅក្នុង **អោគរមោយមុខ** ។ ទម្លាប់អាក្រក់ទាំងឡាយ រាប់បញ្ចូលទាំងការប្រព្រឹត្តល្បែងស៊ីសង សេពនូវទឹកស្រវឹង និងគ្រឿងញៀនជាដើម ។ល។ គឺជាហេតុនាំមកនូវការសូន្យទ្រព្យ និងមិនអាចរក្សាទ្រព្យបានគង់វង្ស ។

**៣-កល្យាណមិត្តតា** គឺការសេពគប់មិត្តល្អឱ្យបានច្រើន ពីព្រោះមិត្តជាទីផ្សាររបស់អ្នក ។ ជាការណ៍ពិតណាស់ បុគ្គលម្នាក់ៗដែលរស់នៅលើលោកយើងនេះ មិនអាចមាននរណាម្នាក់ រស់នៅតែឯកឯងដោយគ្មានទំនាក់ទំនង ជាមួយមិត្តភក្តិបានឡើយ ។ ដូច្នេះ នៅពេលដែលធ្វើការសេពគប់មិត្ត បុគ្គលត្រូវតែប្រុងប្រយ័ត្នជានិច្ច ។ ជាសំណាងល្អ បើសិនជាបុគ្គលបានសេពគប់មិត្ត ដែលជាកល្យាណមិត្ត ដែលជាអ្នកស្គាល់ខុសត្រូវប្រព្រឹត្តសុចរិតត្រឹមត្រូវ ដោយកាយ វាចា និងចិត្ត ជួយជំរុញយើងឱ្យទៅកាន់សេចក្តីចំរើន ការមានទ្រព្យសម្បត្តិ និងធ្វើឱ្យជាទីស្រឡាញ់រាប់អានពីអ្នកផង ។ ផ្ទុយទៅវិញបើសិនជាបុគ្គលមិនសេពគប់មិត្ត ដែលជាកល្យាណមិត្ត ហើយទៅសេពគប់បុគ្គលពាល

គឺពិតជាគ្រោះថ្នាក់ដ៏ធំហើយ ពីព្រោះបុគ្គលពាលនោះនឹងដឹកនាំយើងឱ្យប្រព្រឹត្តនូវអំពើបាបផ្សេងៗ។ ការសេពគប់បុគ្គលពាលនេះ គឺជាកត្តាមួយដែលនាំទៅកាន់ការវិនាសបាត់បង់ទ្រព្យសម្បត្តិ កិត្តិយស កេរ្តិ៍ឈ្មោះ សុខភាព សុភមង្គល ភាពថ្លៃថ្នូរ ហើយទីបំផុតធ្លាក់ខ្លួនទៅជាអ្នកក្រីក្រ តោកយ៉ាកយ៉ាងលំបាកនៅក្នុងជីវិត។

ចំណុចដែលមានសារៈសំខាន់មួយផ្សេងទៀត ដែលអាចធានាឱ្យមានសុភមង្គលល្អ តាមរយៈការវិវឌ្ឍន៍ រីកចំរើនទៅនៃសេដ្ឋកិច្ច គឺការអនុវត្តន៍នូវទ្រឹស្តីទី៤ គឺ **សមជីវិតា**។

**៤-សមជីវិតា** គឺការចញ្ចឹមជីវិតតាមសមគួរ។ ការចញ្ចឹមជីវិតតាមសមគួរនេះ គឺសំដៅយកការចញ្ចឹមជីវិតសមសួន ទៅតាមសមត្ថភាពរបស់ខ្លួន មិនលួចប្លន់អ្នកដទៃមិនបៀតបៀនអ្នកដទៃ ហើយក្នុងការចាយវាយក្តី គឺមិនត្បិតត្បៀតពេក មិនខ្ជះខ្ជាយពេកគប្បីចាយវាយឱ្យដឹងចំណាយចំណូល និងការចេះសន្សំទុកឱ្យសមតាមធនធានដែលខ្លួនមាន។ លក្ខណៈសមញ្ញដែលនាំមកនូវភាពក្រីក្រចំពោះបុគ្គលមួយចំនួន នាពេលបច្ចុប្បន្ននេះ គឺការមិនយកចិត្តទុកដាក់អនុវត្តតាមទ្រឹស្តី **សមជីវិតា** នេះ ហើយបែរជាទៅអនុវត្តតាមបែបជីវិតខ្ជះខ្ជាយ នៃសង្គមសម័យថ្មី។ សូម្បីតែបុគ្គលមានទ្រព្យសម្បត្តិច្រើន បើការរស់នៅតាមបែបជីវិតខ្ជះខ្ជាយ នោះគឺវាបណ្តាលឱ្យខូចបង់ទ្រព្យសម្បត្តិហើយ ធ្លាក់ខ្លួនជាអ្នកទុគ៌ត ក្រីក្រលំបាក តោកយ៉ាក រងទុក្ខធ្ងន់ធ្ងរ។

មានបុគ្គលមួយចំនួន នៅពេលមានទ្រព្យសម្បត្តិស្តុកស្តម្ភបន្តិចទៅ ក៏មានមោទនៈភាពភ្លេចខ្លួន ព្យាយាមចង់ចាប់យកសេដ្ឋកិច្ចថ្នាក់ខ្ពស់ ហើយក៏បណ្តាលឱ្យ

ធ្លាក់ខ្លួន ខាតបង់ទ្រព្យអស់។ ដូច្នេះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់ទ្រឹស្ដីនៃសមជីវិតា ថាជាកត្តាដ៏សំខាន់សម្រាប់សេចក្ដីសុខ សុភមង្គល របស់បុគ្គលនាពេលបច្ចុប្បន្ននេះ។ ជាមួយនឹងគ្នានេះដែរ ព្រះអង្គទ្រង់ក៏បានផ្ដល់នូវដំបូន្មានដល់មនុស្សទាំងឡាយ មិនឱ្យចាយវាយហួសហេតុ ហើយក៏មិនឱ្យស្វិតកំណាញ់ក្រៅតម្រាពេកដែរ។ ដូច្នេះ **សមជីវិតា** គឺមិនមែនមានន័យថា ជីវិតស្វិតកំណាញ់ឡើយ។

# ការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ

នៅក្នុង **សិង្គាលកសូត្រ** ព្រះសម្មាសម្ពុទ្ធទ្រង់បានដាក់ចុះនូវវិធីមួយចំនួន ដែលអាចជួយបំភ្លឺនូវការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ និងរបៀបប្រើប្រាស់ទ្រព្យ ដែលរកបានមកឱ្យបានសមរម្យត្រឹមត្រូវ។

ដូច្នេះ បុគ្គលត្រូវបែងចែកទ្រព្យសម្បត្តិរបស់ខ្លួន ដែលរកបានមកទៅជា ៤ ចំណែកដូចតទៅៈ

**១-ឯកេន ភោគេន ភុញ្ជេយ្យ** មួយចំណែកសម្រាប់ប្រើប្រាស់ ចាយវាយចិញ្ចឹមជីវិតប្រចាំថ្ងៃ។

**២-ទ្វីហិ កម្មំ បយោជយេ** ទុកពីរចំណែកធ្វើវិនិយោគទុន ឬប្រកបមុខរបរផ្សេងៗ និងបង់ពន្ធជូនរដ្ឋជាដើម។

**៣- ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតិ** ទុកមួយចំណែកសម្រាប់ការពារ ក្នុងវេលាមានគ្រោះថ្នាក់ អន្តរាយ មានការឈឺថ្កាត់ជាដើម។

**៤-ឯកេន កុសលំ បយោជយេ** មួយចំណែកសម្រាប់បំពេញកុសលផ្សេងៗ មានធ្វើបុណ្យ សុន្ទរទាន ទំនុកបំរុងមាតាបិតា គ្រូឧបជ្ឈាយាចារ្យជាដើម។

ចំពោះបុគ្គលមួយចំនួន វិធីនេះមើលទៅដូចជាសាមញ្ញពេក ដូច្នេះហើយ មិនសូវជាយកចិត្តទុកដាក់ប៉ុន្មានទេ។ តែចំពោះអ្នកខ្លះវិញ វិធីនេះប្រហែលជាមិនអាចអនុវត្តបានទេ ជាពិសេសគឺនៅក្នុងសង្គមសាធារណៈ ដែលជាទូទៅចំណាយច្រើនជាងចំណូល។ ជាការណ៍ពិត លក្ខណៈនេះគឺមិនមែនជាការងាយស្រួល ដូចជាយើងឃើញ

នោះទេ។ យើងអាចអនុវត្តបាន ប្រសិនបើយើងយល់វាឱ្យបានប្រាកដនោះ។ មានសំណួរដែលនឹងអាចចោទឡើងថា តើចាត់ចែងដោយរបៀបណា សម្រាប់ការចំណាយប្រចាំថ្ងៃរបស់យើង ជាមួយនឹងចំនួនប្រាក់ចំណូលដែលយើងរកបានមក សម្រាប់តែទម្រប់នូវសេចក្ដីត្រូវការមួយថ្ងៃនោះ? ជាទូទៅក្នុងករណីនេះ ចំពោះគ្រួសារដែលមានប្រាក់ចំណូលមធ្យម និងគ្រួសារដែលមានប្រាក់ចំណូលទាប ប្រាក់ចំណូលប្រចាំខែរបស់គេគឺ មិនគ្រប់គ្រាន់សម្រាប់ចំណាយទៅលើសេចក្ដីត្រូវការចាំបាច់ ប្រចាំខែរបស់ពួកគេឡើយ ហើយជាញឹកញាប់ គឺត្រូវតែខ្ចីបុលអ្នកដទៃ មិនតែប៉ុណ្ណោះ មានបុគ្គលមួយ ចំនួនរស់នៅអាស្រ័យទៅលើ កាតក្រេឌិត (Credit Card)។ ឈ្មោះថាកាតក្រេឌិតនេះ ស្ដាប់ឮទៅគួរឱ្យចូលចិត្ត គួរឱ្យគោរព ប៉ុន្ដែវាមានន័យថា រស់នៅអាស្រ័យលើបំណុល។ ក្នុងកាលៈទេសៈបែបនេះ តើធ្វើយ៉ាងណា ដើម្បីឱ្យបុគ្គលអាចអនុវត្តតាមបាននូវវិធីដែលបានផ្ដល់ឱ្យនៅក្នុងសិង្គាលកសូត្រ?។

មានបញ្ហាខ្លះៗកើតឡើងនៅត្រង់ចំណុចនេះ ពីព្រោះជាទូទៅបុគ្គលយល់ថាបុគ្គលត្រូវតែបែងចែកប្រាក់ចំណូលរបស់ខ្លួនជា ៤ ចំណែកស្មើៗគ្នា។ ប៉ុន្ដែតាមពិតទំហំ នៃ ចំណែកនីមួយៗនោះគឺមិនកំណត់ឡើយ ដោយអាស្រ័យទៅលើកត្តាផ្សេងៗដូចជាទំហំនៃគ្រួសារ និងចំនួននៃប្រាក់ចំណូល ជាដើម... ឧទាហរណ៍ បុគ្គលរកបាន ៧០០០៛ ក្នុងមួយថ្ងៃ ហើយមានគ្រួសារតូចដែលមានតែសមាជិកពីរនាក់ មិនចាំបាច់ទុកប្រាក់ ចំណូលមួយចំនួនធំ ដើម្បីប្រើសម្រាប់ប្រើប្រចាំខែឡើយ។ ប៉ុន្ដែ ជាមួយបុគ្គលដែល ជាអ្នករកបានប្រាក់ចំណូលស្មើនឹងចំនួន ៧០០០៛ ដែរប៉ុន្ដែមានគ្រួសារធំ

ហើយទទួល ខុសត្រូវគ្រប់គ្រងចិញ្ចឹម ឪពុកម្តាយ បងប្អូនប្រុស ស្រីនៅលីវ និងកូនៗមួយចំនួនទៀត ជាដើម អីចឹងគេត្រូវតែទុកមួយចំនួនធំនៃប្រាក់ចំណូលរបស់គេជាចាំបាច់។ ដូច្នេះ វិធីនៅក្នុង **សិង្គាលកសូត្រ** នោះគប្បីត្រូវបានអនុវត្តដោយល្អ អាស្រ័យទៅតាម កាលៈទេសៈនិងស្ថានភាពជាក់ស្តែង។

គោលគំនិតសំខាន់ក្នុងវិធីនេះ គឺចង់ចង្អុលបង្ហាញថា បុគ្គលមិនគប្បីចំណាយទាំងអស់នូវប្រាក់ចំណូល ដែលរកបានមកនោះឡើយ។ បុគ្គលគប្បីធ្វើឱ្យទៅជាទម្លាប់រក្សាទុកមួយចំនួន ដើម្បីប្រកបមុខរបរផ្សេងៗ រក្សាទុកដើម្បីសម្រាប់តម្រូវការផ្សេងៗ ដែលកើតមានឡើងជាយថាហេតុ ហើយចំនួនដែលរក្សាទុកនោះ គឺវាមិនអាចកំណត់បានឡើយ វាអាចផ្លាស់ប្តូរទៅតាមខែនីមួយៗ គឺអាស្រ័យលើប្រាក់ចំណូលរបស់បុគ្គល។ អ្វីដែលសំខាន់នោះ គឺត្រូវថ្លឹងថ្លែងថវិកាប្រចាំគ្រួសារ ក្នុងផ្លូវដែលមិនបណ្តោយឱ្យខ្លួនក្លាយទៅជាអ្នករងគ្រោះ នៃសង្គមសាធារណៈ ហើយរស់នៅជាប់បំណុលគេ។ ជីវិតរស់នៅហួសពីលទ្ធភាពរបស់ខ្លួន គឺពិតជាប្រភពនាំមកនូវបញ្ហាដែលធ្វើឱ្យសេចក្តីសុខសាបសូន្យ។

ដូច្នេះបុគ្គលត្រូវតែមានសតិរឭកជាប់ជានិច្ចនូវប្រភេទនៃជីវិតដែលខ្លួនរស់នៅកុំព្យាយាមធ្វើត្រាប់តាមអ្នកដទៃ ដូចមានសុភាសិតខ្មែរបុរាណមួយ បានពោលថា **កុំឃើញចរឹផុះៗតាមចរឹ** ចូរដឹកនាំជីវិតសមរម្យដោយខ្លួនឯងផ្ទាល់ រស់នៅជាជីវិតសាមញ្ញធម្មតា ប្រាថ្នាតិច " **អប្បិច្ឆតា** " រស់នៅតាមជីវិតបែបនេះ គឺមិនមែនជារឿងអ្វីដែលគួរឱ្យអាម៉ាស់ ឬខ្មាស់អៀននោះឡើយ។ រឿងដែលគួរឱ្យអាម៉ាស់នោះ គឺជីវិតក្លែងបន្លំ

ធ្វើពុតហួសវិស័យដែលខ្លួនរស់នៅ។ រស់នៅជាជីវិតសាមញ្ញធម្មតា គឺត្រូវបានលើកទឹកចិត្ត និងសរសើរនៅក្នុងព្រះពុទ្ធសាសនា ប៉ុន្តែសាមញ្ញក្នុងទីនេះ គឺមិនមែនមានន័យថាស្វិតកំណាញ់នោះឡើយ។

បុគ្គលមួយចំនួន ទោះបីខ្លួនមានទ្រព្យសម្បត្តិច្រើន គ្រប់គ្រាន់មែនពិត តែដឹកនាំជីវិតរស់នៅ ជាសភាពអ្នកក្រីក្រទៅវិញ គឺមិនស្លៀកពាក់សមរម្យ មិនហូបចុកសមរម្យ មិនហ៊ានទៅដើរលេងកំសាន្តទីកន្លែងណា ឬក្នុងពិធីផ្សេងៗ មិនដែលចូលរួមការសប្បាយជាមួយមិត្រ មិនទៅលេង ឬសួរសុខទុក្ខមិត្រ និង ញាតិសន្តាន រស់នៅផ្ទះមិនសមរម្យ ។ល។ លក្ខណៈទាំងនេះ មិនមែនជាជីវិតសាមញ្ញឡើយ ប៉ុន្តែវាគឺជាជីវិតស្វិតកំណាញ់។ ទាំងនេះ គឺជាជីវិតហួសវិស័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានដល់សាវ័ករបស់ព្រះអង្គ ឱ្យជៀសវាង កុំអនុវត្ត។

លក្ខណៈហួសវិស័យមួយផ្សេងទៀត គឺជីវិតខ្ជះខ្ជាយ ចាយវាយហួសប្រមាណ ធ្វើអ្វីគឺគ្រាន់តែយកមុខ ចង់បង្ហាញដល់អ្នកដទៃ ឬក៏សូម្បីគ្មានហេតុផល។ កត្តានេះ គឺគ្មានបញ្ហាអ្វីធំដុំទេ ចំពោះអ្នកមានទ្រព្យសម្បត្តិ ប្រសិនបើគេទទួលទានអាហារថ្លៃត្រង់របស់គេរៀងរាល់ថ្ងៃ នៅឯសណ្ឋាគារផ្កាយប្រាំ ប៉ុន្តែបើមនុស្សសាមញ្ញធម្មតា ធ្វើត្រាប់តាមគេដូច្នោះវិញ វានឹងប្រាកដជាដល់នូវសេចក្ដីវិនាសជាក់ជាមិនខានឡើយ។

លះបង់ចោលនូវលក្ខណៈហួសវិស័យទាំងនេះ បុគ្គលគប្បីរស់នៅជាជីវិតដែលមានសេចក្ដីសន្តោស "**សន្តុដ្ឋី**" ជាការចិញ្ចឹមជីវិតស្មើ "**សមជីវិតា**"។ **សមជីវិតា** នេះគឺត្រូវបានពន្យល់យ៉ាងច្បាស់នៅក្នុងព្រះពុទ្ធសាសនា។ វាគឺជាជីវិតរស់នៅ អាស្រ័យ

ទៅលើឋានៈ ឬកំរិត នៃសេដ្ឋកិច្ចគ្រួសារ ដែលបានកំណត់ត្រឹមត្រូវសមរម្យ ទៅតាមចំណូល និង ចំណាយរបស់ខ្លួន។ លក្ខណៈនេះ បុគ្គលគប្បីថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ និងប្រុងប្រយ័ត្ន គឺប្រៀបទៅនឹងបុគ្គលថ្លឹងមាសអ៊ីចឹង ដោយមិនឱ្យម្ខាងធ្ងន់ជាងម្ខាង។

ចំណុចនេះសបញ្ជាក់ឱ្យឃើញថា កម្មវិធីខាងលើ ចំពោះការចាត់ចែងគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ ក្លាយទៅជាកត្តាដ៏សំខាន់ និងមានសារៈប្រយោជន៍ ដើម្បីដឹកនាំនាវាជីវិតគ្រួសារឱ្យមានសុភមង្គល។ ដូច្នេះ បុគ្គលត្រូវតែអនុវត្ត នូវវិធីមួយដែល ហៅថា **សមជីវិតា** គឺការចិញ្ចឹមជីវិតស្មើ សមរម្យ។ បុគ្គលគប្បីដឹងប្រមាណក្នុងការចាយវាយរបស់ខ្លួន។ យោងតាមទ្រឹស្តីព្រះពុទ្ធសាសនា មានកាតព្វកិច្ចយ៉ាងហោចណាស់ ក៏ប្រាំដែរ ដែលបុគ្គលត្រូវតែបំពេញ ជាមួយនឹងទ្រព្យសម្បត្តិដែលខ្លួនមាន ក្នុងនាមខ្លួនជាសមាជិកនៃសង្គម។

## ហេតុដែលនាំមកនូវសេចក្តីវិនាស (អបាយមុខ)

ព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែងនៅក្នុង **សិង្គាលកសូត្រ** នៃគម្ពីរទីឃនិកាយថា ហេតុដែលនាំមកនូវសេចក្តីវិនាស និងការសូន្យទៅនៃទ្រព្យមាន ៦ យ៉ាង។ ការវៀរចាកនូវអបាយមុខទាំង ៦ យ៉ាងនេះ បុគ្គលអាចដឹកនាំជីវិតរបស់ខ្លួន ឱ្យដើរលើវិថីល្អ បរិសុទ្ធត្រឹមត្រូវ ឆ្ពោះទៅកាន់ភាពរីកចំរើនជឿនលឿន។

ការសេពនូវទឹកស្រវឹង និងគ្រឿងញៀនផ្សេងៗ គឺជាហេតុដែលនាំមកនូវសេចក្តីវិនាស និងការសូន្យទ្រព្យ។ ជាធម្មតា នៅពេលដែលបុគ្គលសេពនូវទឹកស្រវឹង និងគ្រឿងញៀន ទាំងអស់នេះហើយ គឺវាធ្វើឱ្យ បុគ្គលញៀន នឹកគិតទៅរកវាជានិច្ច។ ប្រសិនបើបុគ្គលប្រព្រឹត្ត នូវអបាយមុខនេះ គឺវាធ្វើឱ្យបុគ្គលខាតបង់ទ្រព្យសម្បត្តិ បង្កនូវជម្លោះរវាងមនុស្សផងគ្នា ធ្វើឱ្យមានរោគ បាត់បង់សុខភាព កិត្តិយស កេរ្តិ៍ឈ្មោះ អ្នកដទៃនិន្ទា មិនមានសេចក្តីខ្មាស់អៀនចំពោះអ្នកផង ហើយនៅទីបំផុតបាត់បង់នូវគតិបញ្ញាស្មារតី។

ការដើរលេងយប់ខុសកាលគួរ គឺជាហេតុនាំមកនូវសេចក្តីវិនាស និងការសូន្យនូវទ្រព្យដែរ។ វាអាចធ្វើឱ្យបុគ្គលមានការពាក់ពន្ធ័នឹងអ្នកដទៃ។ ចំពោះរឿងនេះ វាបានក្លាយទៅជាទំលាប់មួយដ៏សាមញ្ញទៅហើយ នៅក្នុងស្រទាប់ យុវវ័យនាពេលបច្ចុប្បន្ន ដែលធ្វើត្រាប់តាមវប្បធម៌បរទេស។ បុគ្គលដើរលេងតាមផ្លូវ ខុសកាលគួរតែម្នាក់ឯង ឬជាមួយមិត្រអាក្រក់ទាំងឡាយ គឺគ្មានសុវត្ថិភាពឡើយ ហើយនឹងអាចមានគ្រោះថ្នាក់ផ្សេងៗជាមិនខាន។ ម្យ៉ាងវិញទៀត ប្រសិនបើខ្លួនមាន គ្រួសារ ប្រពន្ធកូន

ទ្រព្យសម្បត្តិនៅឯផ្ទះ មនុស្ស និង ទ្រព្យសម្បត្តិទាំងនោះ គឺគ្មានការគ្រប់គ្រងថែរក្សាឡើយ។ មិនតែប៉ុណ្ណោះ បុគ្គលនោះនឹងក្លាយទៅជាអ្នក ដែលមនុស្សទាំងឡាយមានការចង្អៀតចង្អល់ ធុញទ្រាន់ មិនចង់រាប់រក។ លើសពីនេះទៅទៀត អាចនឹងត្រូវបានគេសង្ស័យថាជាចោរ ហើយពាក្យចចាមអារាមនេះ អាចផ្សព្វផ្សាយទៅទីដទៃ ហើយនៅទីបំផុតកិត្តិយសរបស់បុគ្គលនោះ នឹងត្រូវបាត់បង់។ បុគ្គលជំពូកនេះ ពិតជានឹងមិនអាចគេចផុតពីសេចក្ដីទុក្ខវេទនា ក្នុងពេលបច្ចុប្បន្ន និងក្នុង ពេលអនាគតបានឡើយ។

ការមើលល្បែងមហោស្រពជាប្រចាំ គឺជាហេតុនាំមកនូវសេចក្ដីវិនាស និងការសូន្យនូវទ្រព្យ។ មិនគ្រាន់តែការដើរលេង យប់ខុសកាលគួរប៉ុណ្ណោះទេ ប៉ុន្ដែការមើលកុនល្ខោន ដូរ្យតន្ត្រី ច្រៀងរាំ គឺជាលក្ខណៈ សាមញ្ញមួយដែរនៅក្នុងសម័យកាលនេះ ហើយនេះក៏ជាផ្លូវមួយដែរ ដែលអាចនាំមក នូវការខ្វះខាត បាត់បង់ទៅនៃទ្រព្យសម្បត្តិ។ ការជាប់ចិត្តញៀនទៅនឹងទំលាប់ទាំងនោះ គឺបានក្លាយទៅជាចំណែកមួយនៃជីវិតប្រចាំថ្ងៃរបស់បុគ្គលមួយចំនួនទៅហើយ ក្នុងសម័យកាលនេះ។ បុគ្គលប្រភេទនេះ ប្រសិនបើឮគេថាមានល្បែង ច្រៀងរាំ ប្រគំតន្ត្រី លេងសើច នៅទីកន្លែងណា ក៏នឹងស្ទាត់ទៅទីកន្លែងនោះ។ នៅទីកន្លែង និង ល្បែងកំសាន្តទាំងនោះ គឺមាននូវគ្រឿងបញ្ឆោតចិត្តគ្រប់ប្រភេទ ហើយនៅពេលណា បុគ្គលជាប់ចិត្តជិតអារម្មណ៍ទៅនឹងអ្វីមួយនោះ បុគ្គលក៏ចេះតែចំណាយទៅ ដោយមិនបានចាប់ភ្លឹក ថាលុយរបស់ខ្លួនហួសពីហោប៉ៅ ឬកាបូបឡើយ។ យើងដឹងហើយថា អ្នកងប់ទៅនឹងអបាយមុខទាំងនេះ គឺធ្វើឱ្យគេខាតបង់ពេលវេលា បំភ្លេចចោលអស់នូវតួនាទី និងភារកិច្ចសំខាន់ៗរបស់

ខ្លួន។ ប្រសិនបើរៀមច្បង ប្រព្រឹត្តនូវ អំពើបែបនេះ មនុស្សតូចទាបជាងខ្លួន នឹងព្យាយាមធ្វើត្រាប់តាម។ ប្រសិនបើប្រពន្ធប្តី ទាំពីរនាក់ប្រព្រឹត្តនូវអំពើអបាយមុខបែបនេះ ជាការណ៍ពិត ល្បឿននៃការខ្ជះខ្ជាយ ទ្រព្យសម្បត្តិ នឹងទ្វេឡើងមួយជាពីរ។ ប្រសិនបើប្តីតែម្នាក់ ប្រព្រឹត្តនូវអំពើនេះជាប្រចាំវិញនោះ នឹងមានការរអ៊ូរទាំង ពីប្រពន្ធ និងកូនជាប្រាកដ។ ការដើរមើលល្បែង មហោស្រព គឺមានជាប់ទាក់ទងជាមួយនឹង ការលេងល្បែងភ្នាល់គ្រប់ប្រភេទ។ ចំណង់តណ្ហា សេចក្តីស្រេកឃ្លាន ចង់ក្លាយខ្លួនទៅជាអ្នកមានក្នុងមួយរាត្រី បុគ្គលពាល តែងតែគិតថា សំណាងល្អនឹងសណ្តោសពួកគេក្នុងការលេងល្បែងស៊ីសង និងល្បែងភ្នាល់ទាំងឡាយ។ ល្បែងស៊ីសង និង ល្បែងភ្នាល់ អនុគ្រោះ សន្តោសចំពោះតែបុគ្គល អ្នកឈ្នះប៉ុណ្ណោះ។ ប្រសិនបើ បុគ្គលណាឈ្នះ បុគ្គលនោះរមែងបង្កឱ្យកើតពៀរ មានសត្រូវ តែប្រសិនបើចាញ់ រមែងពិតជាមានវិប្បដិសារី ស្តាយទ្រព្យសម្បត្តិដែលបាត់បង់ទៅ។ អ្នកញៀននឹងល្បែង បាត់បង់នូវការគោរពកោតខ្លាច បាត់បង់ភាពថ្លៃថ្នូរ គ្មាននរណាម្នាក់ជឿពាក្យរបស់ខ្លួន មានការមើលងាយមើលថោកពីមិត្តភក្តិ និងគ្មាននរណាម្នាក់ចង់ចងសម្ពន្ធមេត្រីជាមួយឡើយ។ ការខ្ជះខ្ជាយទ្រព្យសម្បត្តិ បុគ្គលមិនអាចធានាបាននូវសុវត្ថិភាពខាងសេដ្ឋកិច្ចគ្រួសារ ហើយជាការណ៍ពិត មិនអាចពង្រឹង នូវស្ថានភាពល្អនៃគ្រួសារបានឡើយ។

មិត្តភាព គឺជាប្រពភដែលអាចនាំមកនូវផលទាំងពីរយ៉ាង គឺសេចក្តីសុខ និងសេចក្តីទុក្ខ។ មិត្ត គឺជាអ្នកដឹកនាំមិត្រឱ្យជាមនុស្សល្អ ហើយក៏ជាអ្នករុញច្រានមិត្តឱ្យធ្លាក់ចុះក្នុងរណ្តៅ នៃគ្រោះមហន្តរាយដែរ។ ដូច្នេះ ប្រសិនបើបុគ្គលប្រាថ្នាសេចក្តី

សុខ បុគ្គលត្រូវតែមានសតិសម្បជញ្ញៈរលឹកជាប់ជានិច្ច ចំពោះមិត្តរបស់ខ្លួន។ អ្នក លេងល្បែងស៊ីសង ល្បែងភ្នាល់ អ្នកលេងស្រី អ្នកសេពសុរា និងគ្រឿងញៀន អ្នកបោក ប្រាស់ ឆក់ប្លន់ លួចទ្រព្យសម្បត្តិគេ ។ល។ គឺបុគ្គលមិនគួរសេពគប់ធ្វើជាមិត្តឡើយ។

នៅក្នុង **សិង្គាលកសូត្រ** ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសំដែងអំពីលក្ខណៈមិត្ត ដែលគួរសេពគប់ និងមិត្តដែលមិនគួរសេពគប់ច្រើនប្រភេទ។ ប៉ុន្តែក្នុងទីនេះ ខ្ញុំសូម លើកយកលក្ខណៈមិត្ត ដែលមិនគួរសេពគប់មកជំរាបជូនប៉ុណ្ណោះ ដើម្បីទុកគ្រាន់ជា ពន្លឺទៅថ្ងៃក្រោយ។

**លក្ខណៈមិត្រអាក្រក់មាន៤ ប្រភេទ គឺ :**

*ប្រភេទទី ១*

- ជាមនុស្សលោភលន់ចង់បាន
- ឱ្យតិចចង់បានមកវិញច្រើន
- បំពេញកិច្ចការរបស់ខ្លួនដោយសារការភ័យខ្លាច
- ព្រោះសំឡឹងឃើញប្រយោជន៍

*ប្រភេទទី២*

- ជាមនុស្សបានតែមាត់ ប៉ុន្តែមិនដែលអនុវត្ត
- បង្កើតមិត្តភាពជាមួយអ្នកគ្រាន់តែជាមុខរបរ រំលឹកអំពីគុណសម្បត្តិ និង រឿងខ្លះៗពីអតីតកាល
- បង្កើតមិត្តភាពគ្រាន់តែជាមុខរបរដើម្បីអនាគត

- ព្យាយាមថាជួយតែមាត់
- នៅពេលអ្នកមានធុរៈ និយាយរកលេសថា ធ្វើមិនកើតព្រោះមានរវល់

*ប្រភេទទី ៣*

- ជាមនុស្សពូកែតែខាងបញ្ឆោរ
- នៅពេលមិត្តធ្វើអាក្រក់ក៏ស្រុបតាម
- នៅពេលមិត្តធ្វើល្អក៏ស្រុបតាមតែមិនសប្បាយចិត្ត
- និយាយសរសើរមិត្តតែចំពោះមុខ
- នៅកំបាំងមុខនិយាយដើមមិត្តប្រាប់អ្នកដទៃ

*ប្រភេទទី ៤*

- ជាមនុស្សដឹកនាំឱ្យទៅតែខាងសេចក្ដីវិនាស
- គេជាមិត្តរបស់អ្នកនៅពេលដែលអ្នកសេពនូវទឹកស្រវឹង និងគ្រឿងញៀន
- គេជាមិត្តរបស់អ្នកនៅពេលណាអ្នកដើរលេងយប់ជានិច្ច
- គេជាមិត្តរបស់អ្នកនៅពេលណាអ្នកដើរមើលកុន ល្ខោន ច្រៀងរាំផ្សេងៗ
- គេជាមិត្តរបស់អ្នកនៅពេលណាអ្នកប្រព្រឹត្តល្បែងស៊ីសងនិងល្បែងភ្នាល់។

ព្រះសម្មាសម្ពុទ្ធ ទ្រង់តែងតែទូន្មាន ដល់មនុស្សគ្រប់រូបឱ្យប្រឹងប្រែងធ្វើការដើម្បីរកទ្រព្យសម្បត្តិឱ្យបានច្រើន ប៉ុន្តែជាទូទៅ បុគ្គលមួយចំនួនមិនសូវយកចិត្តទុកដាក់អនុវត្ត ទ្រឹស្ដីរបស់ព្រះអង្គប៉ុន្មានទេ។ ពួកគេតែងតែស្វែងរកលេស ដើម្បីគេចវេសអំពីកិច្ចការដោយពោលថា ពេលនេះក្ដៅពេក ត្រជាក់ពេក ល្ងាចពេក ព្រឹកពេក

ឃ្លានពេក ស្រេកពេក ឆ្អែតពេក ធ្វើមិនកើតទេ ចាំពេលក្រោយចុះ។ តើបុគ្គលជំពូកនេះ អាចធ្វើការបានសម្រេចល្អតាមគន្លងធម៌ រកទ្រព្យសម្បត្តិ ដើម្បីសុភមង្គលគ្រួសាររបស់ខ្លួនបានទេ?។ ដូច្នេះ ការលះបង់ពេលវេលាមានតម្លៃនិងភាពខ្ជិលច្រអូស មិនខំប្រឹងធ្វើការ មិនមានសេចក្តីតស៊ូព្យាយាម ជាឧបសគ្គរបស់សេចក្តីសុខនិងទ្រព្យសម្បត្តិ។ មិនតែប៉ុណ្ណោះ មានឧបសគ្គជាច្រើនទៀត ដែលបុគ្គលគប្បីដឹងដើម្បីទុកគ្រាន់ជាពន្លឺ សម្រាប់ខ្លួន ដែលកំពុងដើរលើវិថីនៃជីវិត ដ៏សែនលំបាកនេះ។ មនុស្សយើងគ្រប់រូប គឺមានវត្ថុបំណងជាច្រើននៅក្នុងជីវិតរបស់ខ្លួន។ រីឯវត្ថុបំណងទាំងនោះគឺ ទ្រព្យសម្បត្តិ រូបសម្បត្តិល្អ សុខភាព គុណធម៌ ជីវិតព្រហ្មចារីយ៍ មិត្តភាពល្អ ការសិក្សា បញ្ញា ព្រះធម៌ និង ឋានសួគ៌។ យើងដឹងថាទាំងនេះគឺជាវត្ថុបំណងរបស់មនុស្សគ្រប់រូប តែយើងដឹងទេថា មានមនុស្សប៉ុន្មាននាក់ដែលអាចសម្រេចបាន នូវវត្ថុបំណងទាំងអស់នេះ។ ជាការណ៍ពិតកម្រមានបុគ្គលណាអាចសម្រេចបានណាស់ព្រោះហេតុអ្វី?ពីព្រោះវាមានឧបសគ្គរាំង។ ដើម្បីឱ្យអ្នកអានបានជ្រាប ខ្ញុំសូមលើកយកឧបសគ្គទាំង នោះ មកជំរាបជូនដូចតទៅ:

- ខ្វះការតុបតែងរាងកាយ ជាឧបសគ្គរបស់ រូបសម្ផស្សល្អ" សោភ័ណភាព"
- ការប្រព្រឹត្តមិនត្រឹមត្រូវ ប្រាសចាកសីលធម៌ ជាឧបសគ្គរបស់ សុខភាព
- ការសេពគប់មិត្តអប្បល័ក្ខណ៍ ជាឧបសគ្គរបស់ គុណធម៌
- ការមិនសង្រួមនូវឥន្ទ្រីយ៍ទាំងឡាយ ជាឧបសគ្គរបស់ ជីវិតព្រហ្មចារីយ៍
- អំពើបោកប្រាស កេងប្រវ័ញ្ច ដើរខ្សែលើ ស្វិតកំណាញ់ ជាឧបសគ្គរបស់ មិត្តភាព

- មិនឧស្សាហ៍ព្យាយាម ជាឧបសគ្គរបស់ ការសិក្សា
- គ្មានការស្តាប់ គិត ពិចារណា សាកសួរ ចោទឆ្លើយ ជាឧបសគ្គរបស់បញ្ញា
- ការប្រកាន់តាមផ្លូវខុស ជាឧបសគ្គរបស់ ឋានសួគ៌ និងព្រះនិព្វាន ។

ចំណុច ឬ ឧបសគ្គ ទាំងប៉ុន្មានខាងលើនេះ ខ្ញុំសូមទុកឱ្យលោកអ្នកអានត្រិះរិះគិតពិចារណាដោយខ្លួនឯងទៀតចុះ ។

# ការបណ្តុះបណ្តាលផ្នែកខាងទំនាក់ទំនងសង្គម

ការទំនាក់ទំនង រវាងមនុស្សនៅក្នុងសង្គម ជាកត្តាមួយអាចផ្តល់ឱ្យនូវការអភិវឌ្ឍន៍ ក្នុងសង្គម។ នៅក្នុងចំណុចនេះ **សិង្គាលកសូត្រ** បានផ្តល់ឱ្យនូវដំបូន្មានដ៏ល្អៗជាច្រើន ដែលអាចនាំមកនូវការអភិវឌ្ឍន៍នេះ។ ដូច្នេះរាល់សមាជិកគ្រួសារ ឬសមាជិកនៃសង្គមនីមួយៗ គប្បីសិក្សាឱ្យបានចេះចាំ និងស្វែងយល់ឱ្យបានច្បាស់លាស់នូវទ្រឹស្តីដែលបានផ្តល់ឱ្យ នៅក្នុងព្រះសូត្រនេះ។ គ្រួសារនៅក្នុងជំនាន់ពុទ្ធសម័យ ភាគច្រើនជាគ្រួសារ ដែលមានសមាជិកច្រើន គឺប្តីប្រពន្ធ ឪពុកម្តាយខាងប្តី កូនប្រុស-ស្រី ប្អូនប្រុស-ស្រី ឬបងប្រុស-ស្រី ខាងប្តី ហើយជួនកាលមានទាំងអ្នកបំរើប្រុសស្រីទៀតផង។ លុះពេលក្រោយមក ចំនួនសមាជិកគ្រួសារបានថយចុះ ដោយមានតែកូនប្រុស-ស្រី ប៉ុណ្ណោះ។ ដូច្នេះ ពាក្យប្រៀនប្រដៅជាច្រើននៅក្នុង **សិង្គាលកសូត្រ** ដែលព្រះអង្គទ្រង់សំដែងនោះ គឺក្នុងគោលបំណង ដើម្បីចង់ឱ្យសមាជិក ក្នុងសង្គមគ្រួសារនីមួយៗ ក៏ដូចជាសមាជិកក្នុងសង្គមធំទាំងមូល ទទួលបាននូវការទំនាក់ទំនងល្អក្នុងការអភិវឌ្ឍន៍នូវវប្បធម៌សន្តិភាពនេះ។

សង្គមមានន័យថា ការរួមផ្តុំមនុស្សម្នាទាំងឡាយ។ សង្គមគ្រួសារ គឺជាការរួមផ្តុំគ្នានៃសមាជិកក្នុងគ្រួសារ ហើយរីឯសង្គមធំ គឺជាការរួមផ្តុំនូវរាល់សមាជិកគ្រួសារ និងស្ថាប័ននានា។ ដូច្នេះ រាល់សមាជិកទាំងអស់ក្នុងសង្គមនីមួយៗ មានភារកិច្ច និងតួនាទីផ្សេងៗគ្នា ដែលត្រូវតែបំពេញ។ ពេលមួយបុរសម្នាក់ដើរតួ ជាកូនប្រុសហើយកូនប្រុសដដែលនេះ អាចក្លាយទៅជា បងប្រុស ឬប្អូនប្រុស ហើយថ្ងៃក្រោយក៏អាច

ក្លាយទៅជាឪពុកគេដែរ។ បន្ទាប់មក បុរសដែលបានក្លាយទៅជាឪពុកគេនោះ ក៏អាចក្លាយទៅជា កម្មករ ឬចៅហ្វាយនាយរបស់គេផងដែរ។ ដូច្នេះ យើងឃើញថា បុរសម្នាក់មានតួនាទីច្រើនយ៉ាងណាស់។ ធម្មតាមនុស្សយើងរាល់រូបកាយ ដែលកើតមកក្នុងលោកនេះ មានភារកិច្ច និងកាតព្វកិច្ច រៀង១ខ្លួន ដែលត្រូវបំពេញ ក្នុងឆាកល្ខោននៃជីវិតនេះ។ ទ្រឹស្ដីនៅក្នុង **សិង្គាលកសូត្រ** បានចង្អុលបង្ហាញនូវរបៀប និងទិសដៅក្នុងការបង្កើត នូវប្រព័ន្ធបណ្ដុះបណ្ដាលទំនាក់ទំនង និងសេចក្ដីសុខសន្តិភាពសង្គម។

ផ្ដល់ឱ្យទ្រឹស្ដី និងគោលបដិបត្តិថ្មី ទៅលើលទ្ធិព្រហ្មញ្ញសាសនា នៃការថ្វាយបង្គំទិសទាំង ៦ ព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែងនៅក្នុង **សិង្គាលកសូត្រ** ថា បុគ្គលគប្បីគោរពបូជា នូវទិសទាំង ៦ នេះដោយគោរពដែលមានដូចខាងក្រោមៈ

១- **បុរត្ថិមទិស**-*ទិសបូព៌* គឺទិសខាងកើត តំណាងឱ្យ មាតាបិតា និងបុត្តធីតា

២- **ទក្ខិណទិស**-*ទិសទក្សិណ* គឺទិសខាងត្បូង តំណាងឱ្យ គ្រូបាចារ្យ និងសិស្ស

៣- **បច្ឆិមទិស**-*ទិសបច្ចឹម* គឺទិសខាងលិច តំណាងឱ្យ ស្វាមី និងភរិយា

៤- **ឧត្តរទិស**-*ទិសឧត្តរ* គឺទិសខាងជើង តំណាងឱ្យ មិត្ត និងសហសេវិក

៥- **ហេដ្ឋិមទិស**-គឺទិសខាងក្រោម តំណាងឱ្យ ចៅហ្វាយនាយ និងអ្នកបំរើ

៦- **ឧបរិមទិស**-គឺទិសខាងលើ តំណាងឱ្យ ព្រះសង្ឃ និងគ្រហស្ថ។

បន្ទាប់មកព្រះសូត្រនេះ ក៏បានពន្យល់នូវរបៀបនៃការទំនាក់ទំនង របស់ក្រុមនៃសង្គមនីមួយ១ ដែលត្រូវបដិបត្តិផងដែរ។ តួនាទី និងកាតព្វកិច្ចទាំងអស់នោះមានដូចតទៅៈ

១-**បុរត្ថិមទិស**-*ទិសបូព៌* គឺទិសខាងកើត តំណាងឱ្យ មាតាបិតា និងបុត្តធីតា

**មាតាបិតា** *គប្បីសង្គ្រោះ* **បុត្រធីតា** *ដោយស្ថាន ៥ យ៉ាង:*

ក. **បាបា និវារេន្តិ** ហាមប្រាមកូនមិនឱ្យធ្វើនូវអំពើបាបទាំងពួង

ខ. **កល្យាណេ និវេសេន្តិ** ឱ្យកូនតាំងនៅក្នុងសេចក្ដីល្អ

គ. **សិប្បំ សិក្ខាបេន្តិ** ឱ្យកូនសិក្សាសិល្បវិជ្ជា

ឃ. **បដិរូបេន ទារេន សំយោជេន្តិ** រៀបចំកូនឱ្យមានគូស្រករផ្ទះសំបែងសមរម្យ

ង. **សមយេ ទាយជ្ជំ និយ្យាទេន្តិ** ចែកទ្រព្យឱ្យកូនតាមលទ្ធភាពក្នុងកាលគួរ។

**បុត្រធីតា** *គប្បីសង្គ្រោះ* **មាតាបិតា** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **ភតោ នេសំ ភរិស្សាមិ** ចិញ្ចឹមបីបាច់ថែរក្សាលោកដូចដែលលោកចិញ្ចឹមបីបាច់ ថែរក្សាយើង

ខ. **កិច្ចំ នេសំ ករិស្សាមិ** ជួយធ្វើកិច្ចការលោក

គ. **កុលវំសំ ឋបេស្សាមិ** ទំនុកបំរុង និងបន្តវង្សត្រកូលមិនឱ្យសាបសូន្យ

ឃ. **ទាយជ្ជំ បដិបជ្ជាមិ** ធ្វើខ្លួនឱ្យសក្តិសមជាអ្នកទទួលមរតក

ង. **ទក្ខិណំ អនុប្បទស្សាមិ** ពេលលោកធ្វើកាលកិរិយាទៅ ត្រូវធ្វើបុណ្យឧទ្ទិសជូនទៅលោក។

២-**ទក្ខិណទិស**-*ទិសទក្សិណ* គឺទិសខាងត្បូង តំណាងឱ្យ គ្រូបាចារ្យ និងសិស្ស

**គ្រូបាចារ្យ** *គប្បីសង្គ្រោះ* **សិស្ស** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **សុវិនីតំ វិនេន្តិ** ណែនាំសិស្សឱ្យក្លាយខ្លួនទៅជាមនុស្សល្អ

ខ. **សុគ្គហិតំ គាហាបេន្តិ** ពន្យល់សិស្សឱ្យយល់ត្រឹមត្រូវ ច្បាស់លាស់នូវអ្វីដែលខ្លួនបង្រៀន

គ. **សព្វសិប្បស្សុតំ សមក្ខាយិនោ** បង្ហាត់បង្រៀនសិល្បវិជ្ជាសិស្សឱ្យអស់ មិនលាក់ទុក

ឃ. **មិត្តាមច្ចេសុ បដិវេទេន្តិ** លើកតំកើងសិស្ស ក្នុងទីចំពោះមុខមិត្តភក្តិ និងក្នុងទីប្រជុំផ្សេងៗ

ង. **ទិសាសុ បរិត្តាណំ ករោន្តិ** ធ្វើនូវសេចក្តីការពារដល់សិស្សក្នុងទិសទាំងឡាយ ។

**សិស្ស** *គប្បីប្រតិបត្តិ* **គ្រូបាចារ្យ** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **ឧដ្ឋានេន** ក្រោកឈរទទួលក្នុងវេលាដែលគ្រូដើរចូលមក

ខ. **ឧបដ្ឋានេន** ចូលទៅចាំបំរើលោក

គ. **សុស្សូសាយ** គោរពស្តាប់តាមឱវាទដែលលោកទូន្មាន

ឃ. **បារិចរិយាយ** ឧបដ្ឋាកបំរើលោក

ង. **សក្កច្ចំ សិប្បបដិគ្គហណេន** រៀនសូត្រសិល្បវិជ្ជាដោយគោរព និងយកចិត្តទុកដាក់ ។

៣-**បច្ឆិមទិស**-*ទិសបច្ចិម* គឺទិសខាងលិច តំណាងឱ្យ ស្វាមី និងភរិយា

**ស្វាមី** *គប្បីសង្គ្រោះ* **ភរិយា** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **សម្មាននាយ** ស្រឡាញ់រាប់អានលើកមុខថាជាភរិយារបស់ខ្លួន

ខ. **អវិមាននាយ** មិនប្រមាថមើលងាយភរិយារបស់ខ្លួនដូចជាខ្ញុំកំដរ

គ. **អនតិចរិយាយ** មិនប្រព្រឹត្តកន្លងចិត្ត គឺក្បត់ចិត្តភរិយារបស់ខ្លួន

ឃ. **ឥស្សរិយវោស្សគ្គេន** ប្រគល់ភារៈជាធំនៅក្នុងផ្ទះ គឺជាស្ត្រីមេផ្ទះ

ង. **អលង្ការានុប្បទានេន** ផ្តល់ឱ្យភរិយានូវគ្រឿងតុបតែងខ្លួន ជារង្វាន់លើកទឹកចិត្ត

**ភរិយា** *គប្បីសង្គ្រោះ* **ស្វាមី** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **សុសំវិហិតកម្មន្តា** ចាត់ចែងការងារនៅក្នុងផ្ទះឱ្យមានរបៀបរៀបរយល្អ

ខ. **សុសង្គហិតបរិជនា** សង្គ្រោះញាតិមិត្តខាងស្វាមីឱ្យបានល្អសមរម្យ

គ. **អនតិចារិនី** មិនប្រព្រឹត្តកន្លង ឬក្បត់ចិត្តស្វាមីរបស់ខ្លួន

ឃ.**សម្ភតំ អនុរក្ខតិ** ថែរក្សាទ្រព្យសម្បត្តិដែលស្វាមីរកបានមកមិនឱ្យបាត់បង់

ង. **ទក្ខា អនលសា** ឧស្សាហ៍ព្យាយាម មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង

៤-**ឧត្តរទិស**-*ទិសឧត្តរ* គឺទិសខាងជើង តំណាងឱ្យ មិត្ត និងសហសេវិក

**មិត្ត** *គប្បីសង្គ្រោះ* **សហសេវិក** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **បមត្តំ រក្ខន្តិ** រក្សាមិត្តរបស់ខ្លួនដែលមានការធ្វេសប្រហែស

ខ. **បមត្តស្ស សាបតេយ្យំ រក្ខន្តិ** ជួយថែរក្សាទ្រព្យសម្បត្តិមិត្តរបស់ខ្លួនដែលធ្វេសប្រហែស

គ. **ភីតស្ស សរណំ** កាលមានភ័យអន្តរាយអ្វីកើតឡើងបានជាទីពឹងពុំនាក់

ឃ. **អាបទាសុ ន វិជហន្តិ** មិនលះបង់គ្នាចោលក្នុងពេលមានទុក្ខ

**សហសេវិក** *គប្បីសង្គ្រោះ* **មិត្ត** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **ទានេន** ចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួនឱ្យមិត្តតាមសមគួរ

ខ. **បិយវជ្ជេន** ពោលពាក្យផ្អែមល្ហែមទៅរកមិត្ត

គ. **អត្ថចរិយាយ** ប្រព្រឹត្តប្រយោជន៍ឱ្យ ឬជួយសង្គ្រោះមិត្ត

ឃ. **សមានត្តតាយ** ជាអ្នកមានខ្លួនស្មើ គឺមិនប្រកាន់ខ្លួន រួមសុខ-ទុក្ខជាមួយមិត្ត

ង. **អវិសំវាទនតាយ** មិនក្លែងពោលពាក្យខុសពីការពិត

៥-**ហេដ្ឋិមទិស**-គឺទិសខាងក្រោម តំណាងឱ្យ ចៅហ្វាយនាយ និងអ្នកបំរើ

**ចៅហ្វាយនាយ** *គប្បីសង្គ្រោះ* **អ្នកបំរើ** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **យថាពលំ កម្មន្តំ សំវិធានេន** ចាត់ចែងការងារឱ្យតាមសមគួរដល់កម្លាំង និងសមត្ថភាព

ខ. **ភត្តវេត្តនានុប្បទានេន** ឱ្យអាហាររង្វាន់ និងប្រាក់ឈ្នួលតាមសមគួរទៅនឹង ការងារដែលធ្វើ

គ. **គិលានុបដ្ឋានេន** ថែរក្សាព្យាបាលក្នុងវេលាមានជម្ងឺតម្កាត់ផ្សេងៗ

ឃ. **អច្ឆរិយ រសំ សំវិភាគេន** បែងចែកភោជនាហារដែលមានឱជារសប្លែកៗ ឱ្យបរិភោគ

ង. **សមយេ វោសគ្គេន** បើកឱ្យមានថ្ងៃឈប់សំរាកកំសាន្តតាមកាលគួរ

**អ្នកបំរើ** *គប្បីសង្គ្រោះ* **ចៅហ្វាយនាយ** *របស់ខ្លួនដោយស្ថាន ៥ យ៉ាង:*

ក. **បុព្វុដ្ឋាយិនោ** ក្រោកឡើងពីព្រលឹមធ្វើការងារមុនចៅហ្វាយនាយ

ខ. **បច្ឆានិបាតិនោ** ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ

គ. **ទិន្នាទាយិនោ** កាន់យកតែវត្ថុណាដែលចៅហ្វាយនាយឱ្យ

ឃ. **សុកត កម្មការោ** ធ្វើការងារទាំងឡាយដោយយកចិត្តទុកដាក់

ង. **កិត្តិវណ្ណហរា** ផ្សព្វផ្សាយកេរ្តិ៍ឈ្មោះ កិត្តិយស និងគុណសម្បត្តិរបស់ចៅហ្វាយ-

នាយក្នុងទីដទៃ។

៦-**ឧបរិមទិស**-គឺទិសខាងលើ តំណាងឱ្យ ព្រះសង្ឃ និងគ្រហស្ថ

**ព្រះសង្ឃ** *គប្បីសង្គ្រោះ* **គ្រហស្ថ** *ដោយស្ថាន ៦ យ៉ាង:*

ក. **បាបា និវារេន្តិ** ណែនាំមិនឱ្យធ្វើនូវអំពើបាបផ្សេងៗ

ខ. **កល្យាណេ និវេសេន្តិ** ណែនាំឱ្យតាំងនៅក្នុងអំពើល្អ

គ. **កល្យាណេន មនសា** អនុគ្រោះដោយទឹកចិត្តល្អបរិសុទ្ធ

ឃ. **អស្សុតំ សាវេន្តិ** ញ៉ាំងឱ្យស្ដាប់ធម៌ណាដែលមិនធ្លាប់បានស្ដាប់

ង. **សុតំ បរិយោទបេន្តិ** ពន្យល់ធម៌ណាដែលធ្លាប់បានស្ដាប់ឱ្យរឹងរឹតតែយល់ច្បាស់ថែមទៀត

ច. **សគ្គមគ្គំ អាចិក្ខន្តិ** បង្ហាញផ្លូវទៅកាន់ឋានសួគ៌។

មិនចាំបាច់និយាយអំពីសិទ្ធិឡើយ ប្រសិនបើប្រពន្ធ័ទំនាក់ទំនងត្រូវបានអនុវត្តឱ្យបានពេញលេញ ហើយបុគ្គលម្នាក់ៗ បំពេញតួនាទីរបស់ខ្លួនឱ្យបានល្អនោះ។ ឧទាហរណ៍ នៅពេលដែលបុត្រធីតា បំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានល្អ ចំពោះមាតាបិតារបស់ខ្លួននោះ អ៊ីចឹងពេលនោះ គឺមាតាបិតាបានទទួលនូវសិទ្ធិរបស់ខ្លួន ហើយក្នុងករណី របស់បុត្រធីតាក៏ដូចគ្នាដែរ នៅពេលដែលមាតាបិតាបំពេញតួនាទីរបស់ខ្លួនបានល្អនោះ បុត្រធីតាទាំងឡាយនឹងបានទទួលនូវសិទ្ធិរបស់ខ្លួន ហើយចំពោះសមាជិកក្នុង សង្គម ឬក្នុងស្ថាប័នផ្សេងៗក៏ដូចគ្នាដែរ។ ដូច្នេះ គ្រប់គ្នាមិនចាំបាច់វាយដណ្ដើមគ្នា ដើម្បីសិទ្ធិឡើយ។ ធ្វើដូច្នេះ ការទំនាក់ទំនងគ្នារវាងសមាជិកទាំង

ឞ្បាយនៃសង្គម នឹងប្រព្រឹត្តទៅបានល្អគ្មានសល់ចន្លោះ ទោះបីជានៅក្នុងនិន្នាការអ្វីក៏ដោយ។ កត្តាទាំងនេះ គឺបង្កើតនូវបរិយាកាស ដែលអាចបន្ធូរបន្ថយនូវការតានតឹងខាងផ្លូវចិត្ត ហើយនាំមកនូវសេចក្តីសប្បាយរីករាយក្នុងជីវិត។

នៅពេលដែលជីវិតក្នុងសង្គមគ្រួសារ មានសេចក្តីសុខ ជាធម្មតា គ្រប់សមាជិកទាំងអស់ក្នុងគ្រួសារ នឹងបង្កើតនូវមនោសញ្ចេតនា អាណិតស្រឡាញ់គ្នា ទៅវិញទៅមក និងមានការយោគយល់ ជឿទុកចិត្តគ្នាទៅវិញទៅមក។ ស្ថិតក្នុងស្ថានភាពបែបនេះ រាល់សមាជិកទាំងអស់ក្នុងគ្រួសារនោះ ចាប់ផ្តើមបណ្តុះគំនិតធ្វើការ ឱ្យអស់ពីកម្លាំងកាយចិត្តរបស់ពួកគេ ដើម្បីជំរុញជីវភាពគ្រួសារ ឱ្យមានការរីកចំរើនទ្បើង។ បុត្រធីតាទាំងឡាយ នឹងមានសេចក្តីស្ងប់ខាងផ្លូវចិត្ត ខិតខំសិក្សារៀនសូត្រថែមទៀត ពីព្រោះគេដឹងថា មាតាបិតារបស់គេ ធ្វើអ្វីៗគ្រប់យ៉ាងគឺដើម្បីឱ្យពួកគេមានសុភមង្គលល្អក្នុងជីវិត។ មាតាបិតាទាំងឡាយក្នុងលោកនេះ មានមោទនភាពណាស់ នៅពេលដែលឃើញបុត្រធីតាទាំងឡាយ របស់ខ្លួនមានសុភមង្គលល្អ។ ជាធម្មតា មាតាបិតាមិនចង់ឃើញបុត្រធីតារបស់ខ្លួន មានសេចក្តីទុក្ខលំបាក និងអស់សង្ឃឹមក្នុងជីវិតឡើយ។

ក្នុងករណីរវាងស្វាមី និងភរិយា ក៏ដូចគ្នាដែរ នៅពេលណាដែលស្វាមី និងភរិយា មានធមិសង្គ្រោះគ្នាទៅវិញទៅមក ពួកគេអាចបង្កើតនូវមនោសញ្ចេតនា និងធ្វើឱ្យមានការស្រឡាញ់ យោគយល់ចិត្តថ្លើមគ្នាទៅវិញទៅមកទ្បើង។ សូម្បីតែមានបញ្ហាសេដ្ឋកិច្ច និងបញ្ហាដទៃខ្លះៗ ដែលកើតមានឡើងជាយថាហេតុនោះ ពួកគេនឹងដោះស្រាយបានស្រួល ដោយគ្មានការលំបាកច្រើន។ ក្នុងសង្គមគ្រួសារបែបនោះ

គ្មានស្វាមី និងភរិយាណាមួយ មានបំណងប៉ងប្រាថ្នា ស្វែងរកកំហុសគ្នាឡើយ។ សូម្បី តែមានកំហុសបន្ដិចបន្តួចកើតឡើង ក៏ពួកគេមិនបើកកកាយរករឿងឈ្លោះដែរ តែ ផ្ទុយទៅវិញ ពួកគេនឹងស្វែងរកដំណោះស្រាយ ដោយសន្ដិវិធីជាចាំបាច់ ពីព្រោះពួក គេដឹងថា បញ្ហានេះនឹងអាចបណ្ដាលឱ្យមានសេចក្ដីវិនាស អន្តរាយ ដល់សេចក្ដីសុខ សុភមង្គលគ្រួសារ។

នៅពេលដែលមានសេចក្ដីសុខសុភមង្គល ក្នុងសង្គមគ្រួសារបែបនេះ ទាំងពីរ នាក់ប្ដីប្រពន្ធ នឹងជម្រុញទឹកចិត្ត និងបណ្ដុះគំនិតរបស់ខ្លួន ខំធ្វើការទ្វេឡើង តាមតួនា ទីរៀង១ខ្លួន។ ជាការណ៍ពិតណាស់ កត្តាទាំងនេះនឹងនាំមកនូវភាពរឹងមាំ និងការ អភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ឱ្យមានកំពស់ ហើយនឹងបន្តវង្សត្រកូលរបស់ខ្លួនឱ្យគង់វង្ស ទៅថ្ងៃអនាគត។


ព្រះសង្ឃនិង គ្រហស្ថ
ទិសខាងលើ
មិត្តនិងសហសេវិក
ទិសខាងជើង
មាតាបិតានិងបុត្ត
ទិសខាងកើត
ប្រព័ន្ធ
ទំនាក់ទំនង
សង្គម
ស្វាមីនិងភរិយា
ទិសខាងលិច
គ្រូបាចារ្យនិងសិស្ស
ទិសខាងត្បូង
ចៅហ្វាយនាយនិងកម្មករ
ទិសខាងក្រោម

## កត្តាខ្លះដែលនាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្ន

ដូចដែលបានរៀបរាប់មកពីខាងដើមហើយ ថាគោលគំនិតរបស់ព្រះពុទ្ធសាសនាចំពោះសេចក្តីសុខ គឺជំរុញឱ្យប្រជាពុទ្ធបរិស័ទ សម្រេចបានព្រះនិព្វាន ដែលជាសេចក្តីសុខដ៏ឧត្តម។ ប៉ុន្តែ ព្រះពុទ្ធអង្គទ្រង់យល់ឃើញថា សេចក្តីសុខដ៏ឧត្តមនេះ គឺមិនអាចសម្រេចបានភ្លាមៗនោះទេ ចំពោះមនុស្សបុថុជ្ជន។ ដើម្បីតម្រូវនូវសេចក្តីត្រូវការរបស់ពួកគេ ព្រះអង្គត្រូវតែសំដែងព្រះធម៌របស់ព្រះអង្គ ទៅតាមកាលៈទេសៈនិងស្ថានភាពនានា។ ទោះបីជាធ្វើយ៉ាងនេះក៏ដោយ ក៏ព្រះអង្គមិនបានកែប្រែនូវចំណុចសំខាន់ៗឬផ្លូវនៃព្រះធម៌របស់ព្រះអង្គឡើយ គឺដូចដែលបានបង្ហាញនៅក្នុង **ព្យគ្ឃបជ្ជ សូត្រ** ស្រាប់។ អ្វីដែលព្រះអង្គទ្រង់បានធ្វើនោះ គឺការបង្រៀនឱ្យពុទ្ធបរិស័ទ ចាប់ផ្តើមអនុវត្តនូវទ្រឹស្តីទាំងនេះបន្តិចម្តងៗ ដើម្បីឱ្យបានសម្រេចនូវសេចក្តីសុខក្នុងលោក។ ក្នុងន័យនេះ គឺចង់បង្ហាញថា ជាសេចក្តីសុខដែលកើតចេញពីទ្រព្យសម្បត្តិ ឬសម្ភារៈហើយដែលអាចធានាបាននូវសេចក្តីសុខក្នុងជាតិខាងមុខ ហើយនៅទីបំផុតសម្រេចបានសេចក្តីសុខដ៏ឧត្តមពោលគឺព្រះនិព្វាន។ ពាក្យប្រៀនប្រដៅអំពីការអនុវត្តនីប្រតិបត្តិជាសន្សឹមៗ បន្តិចម្តងៗនេះ ព្រះពុទ្ធសាសនា បានពិភាក្សាអំពីប្រភេទនៃ សេចក្តីសុខដែលមានលក្ខណៈផ្សេងៗគ្នា ហើយលក្ខណៈនេះជាទូទៅ គឺសង្កត់ធ្ងន់ទៅ លើសេចក្តីសុខរបស់ឃរាវាស **គិហិសុខ**។

ទោះបីគោលដៅរបស់ព្រះពុទ្ធសាសនា គឺការសម្រេចបាននូវព្រះនិព្វាន ក៏ដោយ ក៏ព្រះពុទ្ធសាសនាមិនមានគំនិតថា ប្រភេទនៃសេចក្តីសុខរបស់ឃរាវាសប្រឆាំង

ទៅនឹងគំនិតនៃសេចក្ដីសុខដ៏ឧត្ដម ឬព្រះនិព្វានទាំងស្រុងនោះឡើយ។ **ធម្មិក សូត្រ** បានបង្ហាញថា ជីវិតឃរាវាស គឺមិនមែនជាជីវិតថោកទាប ឬឱនថយឡើយ ប្រសិនបើរស់នៅសមរម្យទៅតាមសម្មាអាជីវ គឺការចិញ្ចឹមជីវិតត្រូវ ប្រកបទៅដោយគន្លងធម៌នោះ។ ការមានសេចក្ដីសុខក្នុងជីវិតឃរាវាស មានសារៈសំខាន់ណាស់។ ប្រសិនបើបុគ្គលមិនមានសេចក្ដីសុខ ក្នុងជីវិតឃរាវាសនាពេលបច្ចុប្បន្ននេះទេ បុគ្គលមិនអាចធ្វើការអភិវឌ្ឍន៍ រីកចំរើនខាងផ្លូវចិត្តបានឡើយ។ ដើម្បីធ្វើជីវិតឃរាវាស ឱ្យកាន់តែមានសេចក្ដីសុខ និងមានប្រយោជន៍ទ្វេឡើង ចំពោះខ្លួនឯង ក៏ដូចជាចំពោះសមាជិកគ្រួសារ និងមនុស្សទាំងឡាយ ក្នុងសហគមន៍ធំទាំងមូល ព្រះពុទ្ធសាសនាក៏បានផ្ដល់ឱ្យនូវខ្សែបន្ទាត់ និងដំបូន្មានជាច្រើន។ នៅក្នុងគម្ពីរព្រះពុទ្ធសាសនា មានព្រះសូត្រជាច្រើនដែលបានផ្ដល់នូវដំបូន្មានល្អៗទាំងនោះ សម្រាប់គ្រហស្ថគោរពប្រតិបត្តិ ក្នុងការដឹកនាំនាវាជីវិតប្រចាំថ្ងៃរបស់ពួកគេ ឱ្យមានសេចក្ដីសុខ។ ក្នុងចំណោមព្រះសូត្រដ៏សំខាន់ៗទាំងនោះមានដូចជា **បរាភវសូត្រ មង្គលសូត្រ**.....ជាដើម។

ព្រះសូត្រ ដ៏សំខាន់ជាងគេគឺ **សិង្គាលក សូត្រ** ក្នុងគម្ពីរទីឃនិកាយ ដែលស្ដីអំពីកត្តា ដែលនាំមកនូវសេចក្ដីសុខ ដល់បុគ្គលអ្នកនៅគ្រប់គ្រង់ផ្ទះ។ ព្រះសូត្រនេះបានផ្ដល់ឱ្យនូវដំបូន្មានល្អៗជាច្រើន ចំពោះការទំនាក់ទំនងរវាងមនុស្សក្នុងសង្គម ដោយបានចែកបុគ្គលទៅជា ៦ ក្រុម ដែលតំណាងឱ្យទិសទាំង ៦ ហើយទិសទាំង ៦ នោះគប្បីគោរពប្រតិបត្តិដោយល្អ។

មិនត្រឹមតែប៉ុណ្ណោះ ព្រះសូត្រនេះក៏បានដាក់ចុះផងដែរ នូវធម្មនិយមឬបទដ្ឋាន

ដែលជារបៀបដែលសមាជិកនីមួយៗ គប្បីបំពេញឱ្យបានល្អ។ នៅពេលដែលកាតព្វកិច្ច ឬតួនាទីទាំងនោះ ត្រូវបានបំពេញដោយល្អហើយនោះ ជាលទ្ធផល គឺបុគ្គលម្នាក់ៗ នឹងទទួលបាននូវសិទ្ធិរបស់ខ្លួន ដែលជាហេតុនាំមកនូវសេចក្ដីសុខ សន្តិភាព និង សហប្រតិបត្តិការល្អ ក្នុងសង្គម។ លើសពីនេះទៅទៀត ព្រះសូត្រនេះក៏បានបង្ហាញ នូវកត្តាដ៏សំខាន់ៗ ដើម្បីជ្រើសរើសរកបុគ្គល ជាកល្យាណមិត្រដែលអាចនាំឱ្យយើងទទួលបាននូវសេចក្ដីសុខ។ ព្រះសូត្រ បានបង្ហាញនូវកត្តា ៦ យ៉ាង ដែលជាហេតុនាំមកនូវសេចក្ដីវិនាស ឬសូន្យទ្រព្យ ដែលសព្ទបាលីហៅថា **ភោគអបាយមុខ**។ កត្តានេះមានសារៈសំខាន់ណាស់ ដែលអាចជួយធ្វើឱ្យបុគ្គលយល់ដឹង នូវសេចក្ដីវិនាស ហើយជៀសវាង បន្ទាប់មកប្រតិបត្តិតាមផ្លូវល្អ ដើម្បីកែទម្រង់ជីវភាពរបស់ខ្លួន ឱ្យរួចផុតពីភាពក្រីក្រ។ ការជៀសវាងនូវអបាយមុខនេះ បុគ្គលអាចគេចផុតពីបញ្ហាផ្សេងៗ ក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ហើយអាចរក្សាទ្រព្យសម្បត្តិ ដែលខ្លួនមានឱ្យបានគង់វង្សទៀតផង។ ហេតុដែលនាំមកនូវការសូន្យទ្រព្យមាន ៦ យ៉ាងគឺ៖

១- **សុរាមេរយមជ្ជប្បមាទដ្ឋានុយោគ** ការសេពនូវទឹកស្រវឹង និងគ្រឿងញៀន

២- **វិកាលសិក្ខាចរិយានុយោគ** ការដើរលេងខុសពេលវេលា

៣- **សមជ្ជាភិចរណំ** ការដើរមើលល្បែងមហោស្រព

៤- **ជូនុយោគ** ការលេងល្បែងភ្នាល់

៥- **បាបមិត្តានុយោគ** ការសេពគប់មនុស្សអាក្រក់ជាមិត្ត

៦- **អាលស្សានុយោគ** ការខ្ជិលច្រអូសចំពោះការងារ

នៅក្នុង **សិង្គាលក សូត្រ** មាននូវខ្សែបន្ទាត់ និងដំបូន្មានដ៏មានតម្លៃ ដែលអាចប្រតិបត្តិ ដើម្បីដឹកនាំជីវិតឃរាវាសឱ្យមានសុភមង្គល។

# ជៀសវាងការស្រមើស្រមៃក្នុងសង្គមថ្មី នៃវិទ្យាសាស្ត្រជឿនលឿន

រាល់សកម្មភាពទាំងឡាយ ដែលយើងកំពុងធ្វើ គប្បីមានការប្រុងប្រយ័ត្នជាប់ជានិច្ច ដើម្បីកុំឱ្យក្លាយខ្លួនទៅជានុយ ធ្លាក់ចូលក្នុងអន្ទាក់ នៃការស្រមើស្រមៃ ដែល ជាលក្ខណៈដ៏សាមញ្ញបំផុត ក្នុងសង្គមសម័យបច្ចុប្បន្ន។ ប្រសិនបើយើងមិនបានត្រិះរិះ គិតពិចារណា និងមានសតិរឭកជាប់ជានិច្ច អំពីបរិយាកាស អំពីគ្រឿងបញ្ឆោតចិត្តផ្សេងៗ និងការស្រើបស្រាលទាំងឡាយ ដែលដឹកនាំយើងឱ្យប្រាសចាកមាគ៌ាល្អ យើងមិនអាចធានាបាននូវសុវត្ថិភាព នៃសេចក្តីសុខរបស់យើងបានឡើយ។ គ្រឿងបញ្ឆោតចិត្តដ៏មានឥទ្ធិពល និងមានប្រសិទ្ធិភាពម្យ៉ាង ដែលកំពង់ធ្វើប្រតិបត្តិការ ក្នុងពេលបច្ចុប្បន្ននេះ គឺបណ្តាញឃោសនា និង ទំនាក់ទំនងពាណិជ្ជកម្ម ទាំងផ្នែកការបោះពុម្ពផ្សាយ និង អេឡិចត្រូនិច។ គ្រឿងទាំងនេះ មានឥទ្ធិពលខ្លាំងក្លា ដែលអាចបង្ហាញឱ្យឃើញជាក់ស្តែង នូវរបៀបរស់នៅរបស់មនុស្សយើង។ ការរស់នៅរបស់មនុស្សយើងគ្រប់រូប ស្ទើរតែត្រូវបានដឹកនាំ ដោយគ្រឿងទាំងអស់នោះទៅហើយ។ នៅក្នុងពិភពលោកបច្ចុប្បន្ន អ្វីៗទាំងឡាយ ទាក់ទងជាមួយនឹងជីវិតរស់នៅរបស់មនុស្ស ត្រូវបានចង្អុលបង្ហាញ និងដាក់ក៏រិតហើយនៅទីបំផុត អនុមតិដោយគ្រឿងបច្ចេកវិជ្ជាទាំងនោះ។

អ្វីៗដែលយើងទទួលទាន សំលៀកបំពាក់ដែលយើងស្លៀកពាក់ ថ្នាំដែលយើងត្រូវប្រើដើម្បីលាបផ្ទះរបស់យើងឱ្យមានសោភ័ណភាពល្អ របៀបសិតសក់ ម៉ូតសក់

យ៉ាងណា ដែលយើងគួរយក ថ្នាំលាបសក់ប្រភេទណា ដែលយើងគួរប្រើ សេម្ពូ សាប៊ូ ហើយនិងអ្វីដែលយើងប្រើប្រាស់ទាក់ទងទៅនឹងការរស់នៅរបស់យើង គឺបានដាក់ចុះ និងចង្អុលបង្ហាញដោយ មេឌា ទាំងអស់ជាពិសេស គឺអីនធឺនែត និងបណ្ដាញ ទូរទស្សន៍។ អ្វីដែលយើងព្រួយបារម្ភខ្លាំងនោះ គឺវាមានឥទ្ធិពលគាបសង្កត់ ត្រួតត្រា ទៅលើការគិត គំនិតរបស់យើង។ ប្រសិនបើយើងមិនមានសតិសម្បជញ្ញៈទេនោះ ពី យើង បាត់បង់នូវសេរីភាពក្នុងការគិតជាប្រាកដ ហើយជីវិតរស់នៅរបស់យើង គឺមិន មែនជាជីវិត ដែលយើងបង្កើត និង ដឹកនាំដោយខ្លួនឯងទេ ប៉ុន្តែ គឺអ្វីដែលគ្រឿងប្រព័ន្ធ ផ្សព្វផ្សាយទាំងនោះបានគូសបួងឱ្យយើង។

យើងគ្រប់គ្នាស្ទើរតែប្រៀបបានទៅនឹង កូនតុក្កតាទៅហើយ។ នៅក្នុងចំនុច នេះ សេចក្ដីសន្តោស ត្រូវបានបង្ហាញជាសញ្ញានៃព្រេងវាសនានិយម ឬ ព្រហ្មលិខិត និយម។ បណ្ដាញឃោសនា និង ការទំនាក់ទំនង ទាំងនោះកំពុងតែធ្វើសកម្មភាព ផ្សព្វផ្សាយ លើកតម្កើងនូវគំនិតនៃសង្គមពាណិជ្ជកម្ម របស់មនុស្សលោកបច្ចុប្បន្ន "ដរាបណាអ្នក ប្រើវត្ថុថ្លៃៗ ដរាបនោះសេចក្ដីសុខរបស់អ្នកក៏មានច្រើនដែរ "នេះ គឺអ្វី ដែល អ្នកឃោសនាបានប្រកាស។ ដូច្នេះ គ្រប់រូប គឺត្រូវបានបង្ខំឱ្យជឿទៅលើអ្នក ឃោសនាទាំងនោះ ពីព្រោះអ្នកឃោសនាទាំងនោះឆ្លាតណាស់ ក្នុងការផ្សព្វផ្សាយ និងបង្កើតនូវទំនុកចិត្តយើងរាល់គ្នា ធ្វើឱ្យយើងជាប់ចិត្ត ផ្លាស់ប្ដូរនូវអ្វីដែលហៅថា "ចង់បាន" ឱ្យក្លាយទៅជា"សេចក្ដីត្រូវការ"។ ចូរសាកល្បងពិចារណាមើលជុំវិញខ្លួន យើងឱ្យបាន ល្អិតល្អន់ទៅមើល តើមនុស្សប៉ុន្មាន ដែលទទួលរងទុក្ខវេទនាពីការ

តំឃ្លាន រោគតម្លានេះ ងាយស្រួលជាទីបំផុតក្នុងការព្យាបាល ប្រសិនបើត្រូវបាន ជួយ ឬ សង្គ្រោះនោះ។ តើសេចក្តីទុក្ខលំបាកនៃអ្នកដទៃ មិនមែនជាហេតុធ្វើឱ្យអ្នក កើតទុក្ខព្រួយបារម្ភទេឬ? តើការជួយសំរាលនូវសេចក្តីទុក្ខលំបាកអ្នកដទៃ ជាហេតុធ្វើ ឱ្យអ្នកគ្មានសេចក្តីសុខឬ? តើអ្នកគិតថា សេចក្តីសុខក្នុងអារម្មណ៍ដ៏អស្ចារ្យនឹងបាន ទទួល ប្រសិនបើអ្នក បានជួយនរណាម្នាក់ ឱ្យរួចចាកផុតពីសេចក្តីទុក្ខ មានសេចក្តីសុខ សុភមង្គលក្នុងជីវិត របស់ពួកគេ? តើសេចក្តីសុខបែបនេះ មិនអាចធ្វើឱ្យអ្នកពេញចិត្ត ហើយមានការសន្តោសឬ? ។

ចូរក្រឡេកមើល តើចំនួនប៉ុន្មានម៉ោង ដែលអ្នកចំណាយទៅលើការតាមដាន ទូរទស្សន៍ មើលរឿងអាស្រូវទាំងឡាយ ធ្វើឱ្យរំភើបញាប់ញ័រ ពោរពេញទៅដោយ អំពើហិង្សា រំលោភបំពាន ចាប់ជីវិត និង ទិដ្ឋភាពទាំងឡាយ ដែលធ្វើឱ្យមានការរំខាន ដល់ផ្លូវចិត្ត អារម្មណ៍របស់យើង។ ប្រហែលជាបុគ្គលមួយចំនួនគិតថា គេកំពុង សប្បាយ នូវអ្វីដែលគេតាមដាននោះហើយមើលទៅ ប៉ុន្តែទីបំផុត តើអ្វីមាននៅក្នុង ការសប្បាយរីករាយប្រភេទនោះ? ចិត្តរបស់បុគ្គលមានភាពមិនប្រក្រតី សៅហ្មង វិលវល់ ញាំញី ស្រមើស្រមៃ ទៅនឹងរឿងទាំងនោះ រំខានដល់អារម្មណ៍ ហើយរាល់ គំនិតរបស់ខ្លួននឹងត្រូវបានក្លាយទៅជាសភាវៈគ្មានតម្លៃ។

មាតាបិតាទាំងឡាយ តែងតែដាស់តឿនបុត្តធីតាទាំងឡាយ ឱ្យជៀសវាងការ ញៀនជាប់ចិត្តទៅនឹងការតាមដានទូរទស្សន៍ ប៉ុន្តែជាញឹកញាប់ពួកគេខកខាននូវបំណង នេះ ហើយទីបំផុតលទ្ធផល គឺកូនៗប្រឡងធ្លាក់។ ជាមួយនឹងការបាត់បង់ទៅនៃការ

សិក្សា ខ្វះការអប់រំ ពួកគេក្លាយខ្លួនទៅជាជនអនាថា រត់ចោលផ្ទះ សេពគប់មិត្តអាក្រក់ បង្កជាជម្លោះផ្សេងៗ ដើរលួច ឆក់ ប្លន់ទ្រព្យសម្បត្តិជនដទៃ ហិតការសេពសុរា និង គ្រឿងញៀនផ្សេងៗ ជាប់ចិត្តជិតអារម្មណ៍ ទៅលើស្ត្រីផ្កាមាសទាំងឡាយ ចម្លងរោគ អេដស៍ ធ្វើឱ្យសង្គមវឹកវរចលាចលគ្មានសន្តិភាព។ មាតាបិតាព្រួយបារម្ភ អន្ទះអន្ទែង ខ្វល់ខ្វាយ ហើយទីបំផុត សុភមង្គលគ្រួសារត្រូវបានបាត់បង់។ ចំណងគ្រួសារល្អ ដែលធ្លាប់ទទួលនូវសេចក្តីសុខ ស្រាប់តែធ្លាក់ចុះជ្រៅ ក្នុងរណ្តៅនៃសោកនាដកម្ម។ តើយើងបានចាប់អារម្មណ៍ ទៅនឹងអន្លង់អន្ទាក់នៃសេចក្តីគ្រោះថ្នាក់នេះ ដែរឬទេ? តើអន្លង់ អន្ទាក់នៃសេចក្តីគ្រោះថ្នាក់នេះ អាចជៀសវាងបានឬទេ?។

ទាំងនេះគឺជាបញ្ហាមួយចំនួន ដែលយើងរាល់គ្នា គួរតែពិចារណា។ ប្រសិនបើយើងអាចជៀសវាងបានបន្តិចម្តងៗ យើងគួរតែធ្វើ ហើយជាការណ៍ពិតសេចក្តីសុខសុភមង្គលនឹងកើតឡើងបន្តិចម្តងៗ មិនខានឡើយ។

# សេចក្តីសុខនិងជីវិតគ្រួសារ

សេចក្តីសុខ មានសារៈសំខាន់ណាស់ក្នុងជីវិតគ្រួសារ។ ស្ថេរភាព និង និរន្តរ៍ភាពគ្រួសារ គឺវាអាស្រ័យទៅលើសេចក្តីសុខ ដែលមាននៅក្នុងគ្រួសារ។ ឫសកែវរបស់គ្រួសារ គឺស្វាមី និង ភរិយា។ សេចក្តីសុខរបស់ពួកគេ គឺវាអាស្រ័យនៅលើការចេះយល់ចិត្តយល់ថ្លើមគ្នា ត្រៀមខ្លួនជាស្រេច ដើម្បីសម្របសម្រួលខ្លួន ទៅតាមកាលៈទេសៈ និងបូជាគ្រប់បែបយ៉ាងចំពោះគ្នានឹងគ្នា។ ដើម្បីឱ្យបានសម្រេចនូវគុណលក្ខណៈទាំងអស់នេះ បុគ្គលត្រូវលះបង់បន្តិចម្តងៗ នូវភាពអាត្មានិយម ពីព្រោះភាពអាត្មានិយមនេះ គឺជាឧបសគ្គ នៃសេចក្តីសុខ ហើយវាក៏ជាមូលហេតុនៃជម្លោះទាំងឡាយផងដែរ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់បានពន្យល់បង្ហាញយ៉ាងច្បាស់នូវសេចក្តីសុខក្នុងគ្រួសារ ដែលនឹងអាចត្រូវបានទទួលសម្រាប់ជីវិតឃរាវាស។ កត្តាដ៏ចម្បងនោះគឺ ទាំងពីរនាក់ប្តីនិងប្រពន្ធ គប្បីចាត់ទុកគ្នាជាដៃគូស្មើភាពគ្នា ក្នុងស្ថាប័នគ្រួសារ។ ហើយពួកគេត្រូវតែចែករំលែកនូវតួនាទី និងភារៈកិច្ចរៀងៗខ្លួន។ នៅពេលធ្វើដូច្នេះបុគ្គលមិនគប្បីគិតថា ខ្លួនមានតួនាទីធំ និង សំខាន់ជាងតួនាទីរបស់ដៃគូខ្លួនឡើយ។ ព្រះសម្មាសម្ពុទ្ធនៅក្នុង **សិង្គាលកសូត្រ** ទ្រង់បានប្រទាននូវដំបូន្មាន ល្អៗចំពោះ ស្វាមី និង ភរិយា ដែលគប្បីប្រតិបត្តិ ដើម្បីនាំមកនូវសេចក្តីសុខក្នុងជីវិត អាពាហ៍ពិពាហ៍របស់ខ្លួន។ ក្នុងការដាក់ចុះនូវទ្រឹស្តីនេះ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់បានពិនិត្យមើលដោយយកចិត្តទុកដាក់ ហើយទ្រង់យល់ច្បាស់ថា ទាំងពីរនាក់ប្តី និង ប្រពន្ធ

មិនបានបាត់បង់ អំណាច សេរីភាព ឬ សេចក្ដីថ្លៃថ្នូររបស់ខ្លួនឡើយ។ តួនាទីត្រូវបា ដាក់ចុះ ដើម្បីតម្រង់ផ្លូវ នៃការទំនាក់ទំនងរវាងដៃគូនីមួយៗ។ ទស្សនៈនេះ គឺវាផ្ទុ ស្រឡះ ទៅនឹងទ្រឹស្ដី ព្រហ្មញ្ញសាសនា ឬ សាសនាហិណ្ឌូ ដែលចាត់ទុកការទំនា ទំនងស្មើគ្នារវាងប្ដី និង ប្រពន្ធ ជារឿងឥតប្រយោជន៍ ដោយគេយល់ឃើញថា គឺមិនមែនជាទស្សនៈ ឬ ទ្រឹស្ដីដែល អាទិទេពផ្ដល់ឱ្យ។ ដូច្នេះ ផ្អែកទៅលើទ្រឹស្ ព្រហ្មញ្ញសាសនា ប្រពន្ធត្រូវបានចាត់ទុក ដូចជាខ្ញុំកំដររបស់ប្ដី។ ស្ត្រីនៅក្នុងសង្គ ព្រាហ្មណ៍ គឺគ្មានសេរីភាពអ្វីទាំងអស់ នៅក្នុងជីវិតរបស់នាង។ ពេលនាងកើតម គឺនៅក្រោមការគ្រប់គ្រង របស់ឪពុកម្ដាយ នៅពេលនាងមានប្ដី គឺនាងនៅក្រោមកា គ្រប់គ្រងរបស់ប្ដី ហើយនៅពេលចាស់ជរា គឺនាងនៅក្រោមការគ្រប់គ្រងរបស់កូ ប្រុស លើសពីនេះទៅទៀត ប្រសិនបើប្ដីស្លាប់មុន នាងក៏ត្រូវបានគេបង្ខំ ឱ្យលោតចូ ភ្លើងសំលាប់ខ្លួន ទៅតាមប្ដីរបស់នាងដែរ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ឱ្យដំបូន្មាន ចំពោះស្ត្រីជាប្រពន្ធ ឱ្យមានស្វាមីភ ចំពោះប្ដីរបស់នាង ហើយទន្ទឹមជាមួយគ្នានេះដែរ បុរសជាប្ដីក៏ត្រូវមានស្វាមីភ ចំពោះប្រពន្ធខ្លួនវិញដែរ។ កត្តាដែលយើងបានដឹងរួចមកហើយគឺថា ភាពសុខសាន្តក្ សង្គមគ្រួសារ បាត់បង់ទៅបានក៏ដោយសារភាពអស្វាមីភក្តិ របស់បុរសជាប្ដីដែរ។ ព្រហ្មញ្ញសាសនា ហាក់បីដូចជាមិនបានពិចារណាដោយយកចិត្តទុកដាក់ទៅលើកំហុ ទាំងឡាយខាងបុរសជាប្ដីឡើយ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានទស្សនៈខុ ស្រឡះ ពីលទ្ធិព្រហ្មញ្ញសាសនា ថ្វីត្បិតតែព្រះអង្គទ្រង់ប្រសូតនៅក្នុងបរិយាកា

ព្រាហ្មណ៍ក៏ដោយ។ ព្រះអង្គទ្រង់ចង្អុលបង្ហាញថា ស្វាមីភក្តិក្នុងជីវិតគ្រួសារ គប្បីមានទាំងដៃគូសងខាង។ **បរាភវសូត្រ** ក្នុងគម្ពីរសុត្តនិបាត បានបង្ហាញថា គ្រោះថ្នាក់អាចធ្លាក់ ទៅលើបុរសអ្នកត្រេកអរចំពោះស្ត្រីផ្កាមាស ឬ ប្រពន្ធកូនអ្នកដទៃ។ គាថាក្នុង **បរាភវសូត្រ** នោះបានពោលថា:

**"សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ**

**បទុស្សតិ ទុស្សតិ បរទារេសុ តំ**

**បរាភវតោ មុខំ"**[១] ។

"ជនមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹងស្រីពេស្យា ទ្រុស្ត នឹងប្រពន្ធកូនជននានា ហេតុនោះទៅជានាំឱ្យវិនាស"។

"If a husband, being unsatisfied with his wife seeks the company of either prostitute or goes behind the wives of others, then this would cause his down-fall"[1]

ភាពស្វាមីភក្តិ ជាកត្តាដ៏សំខាន់ដែលបង្កើតនូវសេចក្តីទុកចិត្ត មនោសញ្ចេតនា និងយល់ចិត្តថ្លើមគ្នាទៅវិញទៅមក ដើម្បីធ្វើឱ្យជីវិតគ្រួសារមានសុភមង្គល។

បន្ទាប់ពីបានសិក្សារួចមក អំពីទ្រឹស្តីទាំងឡាយ ដែលមាននៅក្នុង **សិង្គាលកសូត្រ** បុគ្គលអាចយល់បានថា ពាក្យប្រៀនប្រដៅទាំងនោះអាចជួយធ្វើ ឱ្យជីវិតគ្រួសារមានសេចក្តីសុខចំរើនទ្វេឡើង។ ដូច្នេះ ប្តីត្រូវតែមានធម៌ ៥ យ៉ាងហើយ ប្រពន្ធក៏ត្រូវមានធម៌ ៥ យ៉ាងដែរ សម្រាប់សង្គ្រោះគ្នាទៅវិញទៅមក។

ទំនាក់ទំនងរវាង ប្តីនិងប្រពន្ធ គប្បីកសាងឡើង ដោយផ្អែកទៅលើ ទ្រឹស្តីជាមូលដ្ឋាន ដែលបានចែងនៅក្នុង **សិង្គាលកសូត្រ** ពីព្រោះវាអាចដឹកនាំជីវិតគ្រួសារឱ្យមានសេចក្តីសុខចំរើន។ ម្យ៉ាងវិញទៀត នៅត្រង់លក្ខណៈនេះវាអាចមានឥទ្ធិពលទៅលើបុត្រធីតារបស់ខ្លួនផងដែរ។ ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់បានសម្តែងផងដែរ នូវលក្ខណៈផ្សេងៗគ្នារបស់ស្ត្រីជាប្រពន្ធ ដែលអាចធ្វើឱ្យជីវិតអាពាហ៍ពិពាហ៍មានសេចក្តីសុខចំរើន ឬ រងទុក្ខវេទនា។ ព្រះអង្គទ្រង់បានចង្អុលបង្ហាញនូវលក្ខណៈស្ត្រី ៧ ជំពូក ដូចតទៅ:

១-**វធក ភរិយា** ភរិយាដូចជាឃាតករ។ នេះគឺជាប្រភេទនៃស្ត្រីដែលពោរពេញទៅដោយ កំហឹងជានិច្ច មានចំណង់ចំពោះបុរសដទៃ មានគំនុំគំគួនចង់សម្លាប់ប្តីរបស់ខ្លួនជានិច្ច ចង់ឱ្យតែប្តីរបស់ខ្លួនស្លាប់។

២-**ចោរភរិយា** ភរិយាដូចជាចោរ។ នៅពេលដែលស្វាមីរបស់ខ្លួនរកទ្រព្យសម្បត្តិបានមក នាងតែងតែមានចិត្តផិតក្បត់ កេងកិប លួចលាក់ទ្រព្យទាំងនោះ ដើម្បីជាប្រយោជន៍ខ្លួន។

៣-**អយ្យាភរិយា** ភរិយាដូចជាចៅហ្វាយនាយ។ នេះគឺជាស្ត្រី ដែលពោរពេញទៅដោយសេចក្តីខ្ជិលច្រអូស ចូលចិត្តជួបជុំអ្នកដទៃ និយាយរឿងឥតប្រយោជន៍ និយាយតែពាក្យអាក្រក់ ពាក្យបំបែកបំបាក់អ្នកដទៃ។ រាល់កិច្ចការទាំងឡាយ ប្រចាំតែប្តី ទុកប្តីរបស់ខ្លួនដូចជាខ្ញុំកំដរ បាវព្រាវរបស់ខ្លួន។

៤-**មាតាភរិយា** ភរិយាដូចជាមាតា។ នេះគឺជាស្ត្រីដែលមានគុណធម៌ជាម្ដាយ មានទឹកចិត្តសន្ដោសប្រណីជួយស្វាមីជានិច្ច។ មិនត្រឹមតែប៉ុណ្ណោះ ចេះជួយថែរក្សាការពារ ស្វាមីរបស់នាង ប្រៀបបីដូចជាម្ដាយរក្សាកូន តែមួយជាទីស្រឡាញ់របស់ខ្លួន អញ្ចឹង។

៥-**ភគិនីភរិយា** ភរិយាដូចជាប្អូនស្រី។ នាងគោរពស្រឡាញ់ ប្រតិបត្តិប្ដី ប្រៀបដូចជាប្អូនស្រី រួមម្ដាយឪពុកតែមួយ។ នាងតែងតែអត់ធ្មត់ នូវរាល់កិច្ចការទាំងពួង ហើយគោរពតាមដំបូន្មានប្ដីនាងជានិច្ច។

៦-**សខីភរិយា** ភរិយាដូចជាមិត្តសំឡាញ់។ នាងមានសេចក្ដីសប្បាយរីករាយនៅទីចំពោះមុខប្ដី មានក្ដីព្រួយបារម្ភ ពេលប្ដីមិននៅ ទទួលស្វាគមន៍ពេលឃើញប្ដី ត្រឡប់មកវិញ ដូចបុគ្គលទទួលស្វាគមន៍រាក់ទាក់ មិត្តរបស់ខ្លួនដែលបានបែកគ្នាយូរណាស់មកហើយ។ នាងមានគុណធម៌ល្អ ហើយតែងតែមានចិត្តស្មោះត្រង់ចំពោះប្ដីជានិច្ច។

៧-**ទាសភរិយា** ភរិយាដូចជាអ្នកបំរើ។ ទោះបីជាមានការស្ដីបន្ទោសពីប្ដី នាងតែងតែខំាមាត់សង្កត់ចិត្ត មិនខឹងតបទៅនឹងប្ដីរបស់នាងវិញឡើយ។ នាងតែងតែភ័យខ្លាចពីការដាក់ទណ្ឌកម្មពីប្ដីជានិច្ច។ នាងគោរពកោតខ្លាចស្វាមី គ្មានបំណងផិតក្បត់ ចងពៀរវេរានឹងប្ដីនាងឡើយ។ នាងតែងតែគោរពតាមដំបូន្មាន និង-បំណងប្ដីជានិច្ច។

ចំពោះលក្ខណៈទាំងប៉ុន្មានខាងលើនេះ ទុកឱ្យស្ត្រីគ្រប់រូបជាអ្នកវិនិច្ឆ័យដោយ

ខ្លួនឯងចុះ ថាតើនាងឋិតនៅក្នុងស្ត្រីជំពូកណា។ ក្រៅពីនេះទាំងពីរនាក់ ប្តី និង ប្រពន្ធ គប្បីមានគុណធម៌ ចរិតលក្ខណៈដូចគ្នា ដើម្បីដឹកនាំជីវិតអាពាហ៍ពិពាហ៍របស់ខ្លួនឱ្យមានសុភមង្គល។ មានពាក្យចាស់បូរាណបានពោលថា "*នាងរត់រកអ្នក មេខាតលក្ខណ៍រត់រក អាក់បាក់អន្សា*" ។ នៅក្នុង គម្ពីរអង្គុត្តរនិកាយ ព្រះសម្មាសម្ពុទ្ធទ្រង់បានបែងចែកគូស្វាមី ភរិយាជា ៤ ជំពូកដូចតទៅ:

១- ប្តីដូចខ្មោច (**ឆវោ**) រស់នៅជាមួយប្រពន្ធ ដូចខ្មោច(**ឆវា**)

- បានន័យថា ប្តីគ្មានសីល ប្រពន្ធក៏គ្មានសីល។

២- ប្តីដូចខ្មោច (**ឆវោ**) រស់នៅជាមួយប្រពន្ធដូចទេពធីតា(**ទេវី**)

- បានន័យថា ប្តីគ្មានសីល តែប្រពន្ធមានសីល។

៣- ប្តីដូចទេវបុត្រ (**ទេវោ**) រស់នៅជាមួយប្រពន្ធ ដូចខ្មោច(**ឆវា**)

- បានន័យថា ប្តីមានសីល តែប្រពន្ធគ្មានសីល។

៤- ប្តីដូចទេវបុត្រ (**ទេវោ**) រស់នៅជាមួយប្រពន្ធ ដូចជាទេពធីតា(**ទេវី**)

- បានន័យថា ប្តីមានសីល ប្រពន្ធក៏មានសីលដូចគ្នា។ តើអ្នកណាគឺជាប្តីដូចខ្មោចរស់នៅជាមួយប្រពន្ធដូចខ្មោច? ទាំងនេះ គឺជាបុគ្គលអាក្រក់ ប្រព្រឹត្ត ឬ ប្រកបតែមុខរបរខុសទាំងឡាយ ដូចជា ការសំលាប់ លួច ឆក់ ប្លន់ សេពមេថុនធម្ម ជាមួយស្រីផ្កាមាស និយាយកុហក និយាយតែពាក្យញុះញង់ ពាក្យចាក់ដោត បំបែកបំបាក់អ្នកដទៃ និយាយពាក្យឥតប្រយោជន៍ មានចិត្តគំនិតអាក្រក់ ស្ថិតកំណាញ់ក្រៅតម្រា មានចិត្តគំកួន និង ជាមនុស្សមិច្ឆាទិដ្ឋិ

គ្មានជំនឿសាសនា។

ម្យ៉ាងទៀត តើប្ដីដូចទេវបុត្រ រស់នៅជាមួយប្រពន្ធដូចជាទេពធីតានោះយ៉ាងណា? ទាំងនោះគឺជាបុគ្គលប្រកបដោយគុណធម៌ល្អ ដែលផ្ទុយពីបុគ្គលមួយជំពូកដែលបានរៀបរាប់ហើយ " ប្ដីដូចខ្មោចរស់នៅជាមួយប្រពន្ធដូចខ្មោច "។

ក្នុងជំពូកទី ៤នេះ គឺជាចំនុចដ៏ល្អ ដែលអាចនាំមកនូវសេចក្ដីសុខដ៏ឧត្ដម ក្នុងជីវិតគ្រួសារ។ រីឯពីរជំពូក ក្រៅពីនេះទុកឱ្យអ្នកអានស្វែងយល់ដោយខ្លួនឯងចុះ។

ទន្ទឹមនឹងការសំដែងអំពីលក្ខណៈ របស់ភរិយា ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់បានសំដែងអំពីលក្ខណៈ ស្វាមី ៧ ជំពូកផងដែរ។ លក្ខណៈទាំង ៧ ជំពូករបស់បុរសក៏ស្រដៀងគ្នាទៅនឹងលក្ខណៈ ៧ ជំពូករបស់ស្ត្រីផងដែរ ដូច្នេះក្នុងទីនេះ ខ្ញុំគ្រាន់តែលើកយកមករៀបរាប់ជាគោល១ ដោយពុំចាំបាច់អធិប្បាយឡើយ។

លក្ខណៈ ៧ ជំពូករបស់បុរសនោះគឺៈ

១- **វធក ស្វាមី** ស្វាមីដូចជាឃាតករ

២- **ចោរ ស្វាមី** ស្វាមីដូចជាចោរ

៣- **អយ្យា ស្វាមី** ស្វាមីដូចជាចៅហ្វាយនាយ

៤- **បិតា ស្វាមី** ស្វាមីដូចជាឪពុក

៥- **ជេដ្ឋា ស្វាមី** ស្វាមីដូចជាបងប្រុស

៦- **សខា ស្វាមី** ស្វាមីដូចជាមិត្តសំឡាញ់

### ៧- ទាស ស្វាមី ស្វាមីដូចជាអ្នកបំរើ

ស្វាមីទាំង ៧ ជំពូកខាងលើនេះ ទុកឱ្យបុរសខ្លួនឯងជាស្វាមីពិចារណា និង វិនិច្ឆ័យចុះ ថាខ្លួនឋិតនៅក្នុងជំពូកណា។ ម្យ៉ាងវិញទៀត ការបំពេញតួនាទីរបស់ខ្លួន រវាងឪពុកម្តាយ និង បុត្រធីតា ក៏ជាកត្តានាំមកនូវសេចក្តីសុខ ក្នុងសង្គមគ្រួសារផង ដែរ។ នៅក្នុង **សិង្គាលកសូត្រ** ព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែងថា មាតាបិតាគប្បី សង្គ្រោះបុត្រធីតា ដោយស្ថាន ៥ យ៉ាង ហើយបុត្រធីតា ក៏គប្បីសង្គ្រោះមាតាបិតា ដោយស្ថាន ៥ យ៉ាងវិញដែរ។ នៅពេលដែលរាល់សមាជិក ក្នុងសង្គមគ្រួសារបាន បំពេញនូវតួនាទីរបស់ខ្លួនបានល្អហើយ គ្រួសារនោះ ពិតជាមានសេចក្តីសុខចំរើន គ្មាន ជម្លោះ ឬ ការយល់ច្រឡំរវាងគ្នានឹងគ្នាឡើយ។ រាល់បញ្ហាទាំងអស់ ដែលកើតឡើង ជាយថាហេតុនឹងត្រូវបានដោះស្រាយដោយស្រួល។

---

១ បរាភវសូត្រ សុត្តនិបាត-(៥៤)-៣៩

[1]Parabhava Sutta (stanza. 180) P46, Sutta Nipada, Text and translation by N A J

# សេចក្តីសុខ៤យ៉ាង

ព្រះពុទ្ធសាសនា ក្នុងនាមជាសាសនាមួយ ដែលមានដំណោះស្រាយចំពោះបញ្ហាជីវិត បានពិចារណាឃើញថាទ្រព្យសម្បត្តិ គឺជាកត្តាដ៏ចាំបាច់ ក្នុងដំណើរឆ្ពោះទៅរកសេចក្តីសុខ របស់ឃរាវាសនាពេលបច្ចុប្បន្ន។ យោងតាមគោលគំនិតនេះ ព្រះពុទ្ធសាសនាបានបង្ហាញអំពីសេចក្តីសុខ ៤ យ៉ាងដែលជាប់ទាក់ទង ជាមួយនឹងជីវិតឃរាវាស។ ដើម្បីដឹងថា តើសេចក្តីសុខរបស់ខ្លួននោះ មានលក្ខណៈយ៉ាងណា ឃរាវាសគប្បីសិក្សាស្វែងយល់ដោយខ្លួនឯងថា អ្វីទៅសេចក្តីសុខ ៤ យ៉ាងនោះ។ សេចក្តីសុខ ៤ យ៉ាងរបស់គ្រហស្ថនោះ គឺមានសំដែងនៅក្នុង **ឥណសូត្រ** នៃគម្ពីរអង្គុត្តរនិកាយ។ សេចក្តីសុខ ៤ យ៉ាងនោះ គឺ:

១-**អត្ថិសុខ** សេចក្តីសុខកើតមកពីការមានទ្រព្យ

២-**ភោគសុខ** សេចក្តីសុខកើតមកពីការចាយវាយទ្រព្យ

៣-**អនណសុខ** សេចក្តីសុខកើតមកពីការមិនជំពាក់បំណុលគេ

៤-**អនវជ្ជសុខ** សេចក្តីសុខកើតមកពីការគ្មានទោស គ្មានការស្តីបន្ទោសពីអ្នកដទៃ។

ព្រះសូត្រក៏បានសំដែងថា ទាំងនេះគឺជាសេចក្តីសុខ ៤ យ៉ាងដែលគ្រហស្ថចាំបាច់ត្រូវស្វែងរក។ **អត្ថិសុខ** គឺជាសេចក្តីសុខដែលបុគ្គលទទួលបាន និងសប្បាយ

រីករាយ នៅពេលណាបុគ្គលដឹងថា ខ្លួនមានទ្រព្យសម្បត្តិល្មមគ្រប់គ្រាន់ ដែលរកបាន ដោយសេចក្តីព្យាយាមដោយកំលាំងស្មងខ្លួន ដែលប្រកបដោយសម្មាអាជីវោ។ នៅពេលដែលបុគ្គលបានដឹងច្បាស់យ៉ាងនេះហើយ គឺខ្លួនមានអារម្មណ៍ សប្បាយរីករាយថា ខ្លួនមានទ្រព្យ ទោះទ្រព្យនោះមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី។ ទ្រព្យសម្បត្តិទាំងនេះ អាចធ្វើឱ្យបុគ្គលប្រើប្រាស់កក់ក្តៅ ដោយនឹកគិត និងសង្ឃឹម ជឿទុកចិត្តថា ខ្លួនពុំមាន ការក្រក្សត់ដោយហេតុផ្សេងៗឡើយ។ ប្រសិនបើបុគ្គលណាមួយ មានទ្រព្យសម្បត្តិ បុគ្គលនោះតែងតែមានមុខមាត់ក្នុងទីប្រជុំនានា និយាយស្តីអ្វីទៅ គឺគេយកចិត្តទុកដាក់ ស្តាប់ អ្នកដទៃមិនហ៊ានមើលងាយមើលថោកឡើយ។ ប៉ុន្តែចូរចងចាំថា ទ្រព្យសម្បត្តិ ដែលរកបានមក ហើយផ្តល់ឱ្យសេចក្តីសុខដល់ខ្លួននោះ គឺជាទ្រព្យសម្បត្តិ ដែលរកបាន មកដោយសុចរិតត្រឹមត្រូវ តាមគន្លងធម៌ មិនមែនជាទ្រព្យសម្បត្តិ ដែលរកបានមក ដោយ អំពើទុច្ចរិត អយុត្តិធម៌ កេងប្រវ័ញ្ច លួច ឬ ឆក់ប្លន់គេឡើយ។

នៅពេលដែលបុគ្គល ដឹងដូច្នេះហើយ បុគ្គលនឹងអាចមានការសប្បាយពេញ ចិត្ត។ លក្ខណៈនេះផ្តល់ឱ្យបុគ្គលនូវសេចក្តីពេញចិត្តមួយប្រភេទ ដែលឱ្យឱកាសដល់ខ្លួន ដើម្បីងាកមើលនូវស្ថានភាព រីកចំរើនផ្នែកខាងសេដ្ឋកិច្ចរបស់ខ្លួន។ នេះគឺធ្វើឱ្យបុគ្គល បញ្ឈប់នូវការប្រណាំងប្រជែងជាមួយនឹងជីវិត ក្នុងការស្វែងរកទ្រព្យសម្បត្តិ។ ដូច្នេះ ហើយ បានជានៅក្នុងធម្មបទ មានពាក្យមួយកន្លែងចែងថា សន្តុដ្ឋី ជាទ្រព្យដ៏ឧត្តម។

នៅពេលដែលបុគ្គលដឹងថា ខ្លួនមានទ្រព្យសម្បត្តិគ្រប់គ្រាន់ បុគ្គលនោះពិតជា

មានការសប្បាយរីករាយ សមស្របជាមួយនឹងទ្រព្យនោះ។ ព្រះពុទ្ធអង្គ បានពន្យល់ផងដែរនូវអ្វីដែលហៅថា ការសប្បាយរីករាយ ចាយវាយទ្រព្យរបស់ខ្លួន។ ត្រង់ចំណុចនេះ គឺបានដល់សេចក្តីសុខមួយទៀតគឺ **ភោគសុខ** ដែលមានន័យថា អ្នកមានទ្រព្យសម្បត្តិត្រូវតែចេះចាយវាយទៅតាមកាលគួរ មិនត្រូវខ្ជះខ្ជាយ ឬ ត្បិតត្បៀតហួសពេក។ ជាមួយនឹងទ្រព្យសម្បត្តិ ដែលខ្លួនរកបានតាមផ្លូវសុចរិតត្រឹមត្រូវ បុគ្គលត្រូវតែចេះសន្សំទុក និង បំពេញតួនាទីរបស់ខ្លួនឱ្យបានល្អ ចំពោះសមាជិកគ្រួសារ ញាតិសន្តាន មិត្រសំឡាញ់ និងមនុស្សដែលក្រក្សត់ អភ័ព្វទុគ៌ត ក្នុងសង្គម។ បុគ្គលក៏ត្រូវតែធ្វើបុណ្យកុសលផ្សេងៗ កប់ទុកជាកំណប់ទ្រព្យរបស់ខ្លួន ទៅជាតិខាងមុខ។ ឆ្លងកាត់ការសប្បាយរីករាយ ជាមួយនឹងទ្រព្យសម្បត្តិដែលខ្លួនមានបែបនេះ ក៏ដោយសារបុគ្គលបានដឹង និង យល់ច្បាស់ថា ទ្រព្យដែលខ្លួនរកបាន ដោយអំពើសុចរិតត្រឹមត្រូវ ហើយចាយវាយ ក៏ត្រឹមត្រូវក្នុងលក្ខណៈ ដែលធ្វើប្រយោជន៍ដល់អ្នកដទៃនិងបុគ្គលខ្លួនឯងផង។ សេចក្តីសុខនេះ គឺមានតម្លៃណាស់ ពីព្រោះបុគ្គលដឹងថាខ្លួនមិនបានចាយវាយខ្ជះខ្ជាយទ្រព្យ ដែលខ្លួនបានរកតាមសម្មាអាជីវ ប៉ុន្តែបានបំពេញកាតព្វកិច្ចរបស់ខ្លួន បានយ៉ាងល្អប្រពៃ។ ធ្វើដូច្នេះ បុគ្គលនឹងបានជាទីស្រឡាញ់រាប់អានកោតសរសើរអំពីមនុស្សទាំងឡាយក្នុងសង្គម។

សេចក្តីសុខទី៣ ដែលគ្រហស្ថតែងតែប្រាថ្នាចង់បាននោះគឺ **អនណសុខ** ជាសេចក្តីសុខដែលបុគ្គលដឹងថា ខ្លួនគ្មានជាប់បំណុលនរណាម្នាក់។ ពាក្យថាបំណុលនេះ គឺជាការខ្ចីបុលប្រាក់កាស ទ្រព្យសម្បត្តិរបស់ជនដទៃ មកចាយវាយក្នុងគោលបំណង

ផ្សេងៗរបស់ខ្លួន។ ដរាបណា បុគ្គលខ្ចីបុលគេហើយ ៗមិនបានសងគេវិញទាន់ពេលកំណត់ ដរាបនោះ ការប្រាក់ក៏កាន់តែកើនឡើងជាលំដាប់។ ការជំពាក់បំណុលអ្នកដទៃនោះពុំមែនស្រួលឡើយ គឺប្រហែលគ្នានឹងអោបទុក្ខប៉ុនភ្នំអញ្ចឹង បើបំណុលតិច ទុក្ខក៏តិច បើបំណុលច្រើន ទុក្ខក៏ច្រើន។ ជួនកាលបំណុលនោះ បន្តិចបន្តួចទេ ប៉ុន្តែសេចក្ដីទុក្ខធំក៏មាន។មានស័ព្ទបាលីមួយកន្លែង បានពោលថា "**ឥណាទានំ ទុក្ខំ លោកេ**" *មានន័យថា* ការជំពាក់បំណុលគេ ជាទុក្ខក្នុងលោក។ មានសេចក្ដីប្រៀបធៀបថា មនុស្សក្រីក្រលំបាកក្ដី មនុស្សល្ងង់ខ្លៅក្ដី មនុស្សមានជំងឺក្ដី មនុស្សជំពាក់បំណុលជនដទៃក្ដី ទាំងអស់សុទ្ធតែមានទុក្ខដូចគ្នា។

ដូចដែលបាននិយាយហើយថា ការជាប់ជំពាក់បំណុលគេ គឺជាហេតុនាំមកនូវសេចក្ដីទុក្ខដ៏ខ្លាំងចំពោះបុគ្គលមិនរើសមុខ។ តាមការណ៍ពិត មានបុគ្គលជាច្រើនដែលទទួលរងទុក្ខ ក្រោមបន្ទុកនៃការខ្ចីបុលគេច្រើន។ ហេតុមួយដែលនាំឱ្យមានការជំពាក់បំណុលគេគឺ រស់នៅជាជីវិតខ្ជះខ្ជាយហួសព្រំដែន។ នេះគឺជាហេតុផលមួយ ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់នៃយើង ទ្រង់រំលឹកដាស់តឿន ដល់បរិស័ទរបស់ព្រះអង្គ អំពីភាពចាំបាច់នៃការអនុវត្តន៍តាម **សមជីវិតា**។ បុគ្គលត្រូវតែរស់នៅតាមមធ្យោបាយរបស់ខ្លួន តាមធនធានដែលខ្លួនមាន។ប្រសិនបើមិនដូច្នោះទេបុគ្គលនឹងត្រូវធ្លាក់ខ្លួនជាអ្នកជំពាក់បំណុលគេ ជាមួយនឹងប្រាក់ការឡើងជាបន្តបន្ទាប់នៅទីបំផុតគ្មានសេចក្ដីសុខក្នុងផ្លូវចិត្តឡើយ។ **ឥណសូត្រ** នៃគម្ពីរអង្គុត្តរនិកាយ បានបង្ហាញនូវហេតុនៃសេចក្ដីទុក្ខ ភាពជាជនអ្នកជំពាក់បំណុលគេ ជាមួយនឹងការបាត់បង់ជំនឿ និង

សេចក្ដីគោរព ចំពោះខ្លួនឯង។ ព្រះសូត្រនេះ ក៏បានចង្អុលបង្ហាញផងដែរ អំពីការទទួលរងទុក្ខទោស ទាំងផ្លូវកាយ វាចាអំពីម្ចាស់បំណុល ហើយទីបំផុតត្រូវបានគេប្ដឹង ចាប់ដាក់គុកក៏មាន។ មានបុគ្គលមួយភាគតិចណាស់ ដែលបានទទួលសេចក្ដីសុខ ដែលកើតអំពីការគ្មានបំណុលនេះ ពីព្រោះបុគ្គលភាគច្រើន តែងតែសប្បាយជ្រុល ភ្លេចខ្លួនជាមួយនឹងការរីកចម្រើនទៅនៃពិភពលោក។ ដោយការវិវឌ្ឍន៍រីកចំរើននេះហើយ បានធ្វើឱ្យគេ ភាន់ភាំងស្មារតី ភ្លេចគិតអំពីទ្រឹស្ដីនៃ **សមជីវិតា** ហើយចេះតែចំណាយទៅហួសលទ្ធភាពរបស់ខ្លួន លទ្ធផលនេះគឺធ្លាក់ខ្លួន ជាអ្នកជាប់បំណុលគេ។ រាល់បញ្ហាទាំងអស់នេះ នឹងអាចជៀសវាងបាន ប្រសិនបើបុគ្គលដើរតាមដំបូន្មាន របស់ព្រះ-សម្មាសម្ពុទ្ធគឺ **សមជីវិតា** ការចិញ្ចឹមជីវិតតាមសមគួរ ការចិញ្ចឹមជីវិតតាមសមរម្យ **អប្បិច្ឆតា** គឺជីវិត សាមញ្ញធម្មតា ជាអ្នកប្រាថ្នាតិច។

សេចក្ដីសុខទី ៤ គឺ **អនវជ្ជសុខ** ជាសេចក្ដីសុខដែលកើតមកពីការគ្មានទោស គ្មានការស្ដីបន្ទោសពីអ្នកដទៃ។ សេចក្ដីសុខប្រភេទនេះ គឺជាសុខដែលបណ្ដាលមកពីការប្រព្រឹត្តល្អបរិសុទ្ធ សុចរិតត្រឹមត្រូវ យុត្តិធម៌តាមផ្លូវកាយ វាចា និង ចិត្តរបស់ខ្លួន។ សុខដែលកើតអំពីការប្រព្រឹត្តប្រតិបត្តិធម៌ គឺជាសុខដ៏សំខាន់ជាងសុខដែលកើតអំពីការមានទ្រព្យ។ តាមការណ៍ពិត មនុស្សមានទ្រព្យ តែគ្មានធម៌ក្នុងខ្លួន ហើយស្វែងរកទ្រព្យតាមផ្លូវអាក្រក់ មិនអាចទទួលបាននូវសេចក្ដីសុខឡើយ ពីព្រោះគេតែងតែនឹកគិតបារម្ភ អំពីអំពើអាក្រក់ទាំងឡាយ ដែលខ្លួនបានប្រព្រឹត្ត។ ការរលឹកអំពីអំពើអាក្រក់ដែលខ្លួនបានធ្វើ គឺជាប់តាមខ្លួនបុគ្គលជានិច្ច។ ដូចមានសេចក្ដីមួយកន្លែងក្នុង

ធម្មបទអដ្ឋកថា បានពោលថា បើបុគ្គលមានចិត្តប្រទុស្តហើយ ទោះធ្វើក្តី និយាយក្តី ព្រោះអំពើអាក្រក់នោះឯងហើយ សេចក្តីទុក្ខរមែង ដេញជាប់តាមពីក្រោយបុគ្គលនោះ ដូចជាកង់រទេះវិលតាមដានជើងគោ ដែលអូសនឹមរទេះ ឬ ក៏ដូចជាស្រមោលអន្ទោលតាមប្រាណ របស់បុគ្គលនោះយ៉ាងដូច្នេះឯង។ ដូច្នេះហើយបានជា ព្រះពុទ្ធអង្គទ្រង់ជានិច្ចកាលតែងតែដាស់តឿន គ្រើនរំលឹកដល់មនុស្សទាំងឡាយ ឱ្យវៀរចាក ឬ ជៀសវាងនូវមុខរបរ ឬ ជំនួញដែលខុស ប្រាស់ចាកគន្លងធម៌ ដូចជាការជួញអាវុធគ្រឿងញៀន ជាដើម។ នៅពេលដែលបុគ្គល ត្រិះរិះឃើញអំពីវិធីដែលខ្លួនរកទ្រព្យសម្បត្តិតាមសុចរិតត្រឹមត្រូវ បុគ្គលនឹងបានទទួលនូវ **អនវជ្ជសុខ**។ បុគ្គលប្រភេទនេះនឹងគ្មានបញ្ហាអ្វីដែលត្រូវព្រួយបារម្ភ ឬ ភ័យខ្លាចឡើយ ពីព្រោះគេដឹងថាខ្លួនគេគ្មានទោស។ នេះគឺជាសេចក្តីសុខដ៏ឧត្តម របស់ឃរាវាស នាពេលបច្ចុប្បន្ន កាលលោកីយ៍នេះ។

# ការជៀសវាងនូវភាពលំអៀង

ដើម្បីធ្វើឱ្យគ្រួសារមួយ មានដំណើរទៅមុខ ប្រកបដោយសេចក្ដីសុខនោះ សមាជិកអ្នកកាន់អំណាច ដូចជារៀមច្បង ជាពិសេសគឺមាតាបិតា គប្បីចាត់ទុកមនុស្សក្នុងគ្រួសារទាំងអស់ស្មើភាពគ្នា ជាពិសេសគឺ កូនៗទាំងឡាយ ដោយមិនស្រឡាញ់កូនម្នាក់ ជាងកូនម្នាក់ទៀត។ ភាពអនុគ្រោះនិយម និង ភាពលំអៀង គឺជាប្រភពដែលនាំមកនូវការយល់ខុស យល់ច្រឡំ និងទំនាស់ រវាងគ្នានឹងគ្នា។ ប្រសិនបើឪពុកម្ដាយស្រឡាញ់កូនម្នាក់ជាងកូនម្នាក់ទៀត កូនដែលមិនបានទទួលការស្រឡាញ់ស្មើនោះ យល់ច្រឡំ និងមានការអាក់អន់ចិត្ត នឹកគិតចងគំនុំគុំកូន ហើយថ្ងៃណាមួយ នឹងកើតមានរឿងជាប្រាកដ ទីបំផុតសេចក្ដីសុខក្នុងគ្រួសារ នឹងត្រូវបាត់បង់។ ចំណងគ្រួសារនឹងត្រូវបែកបាក់ ហើយការទុកចិត្តគ្នា ក៏នឹងត្រូវហើរទៅតាមខ្យល់នៃវាយោ ដែរ។ បញ្ហា ឬទំនាស់ទាំងនោះ អាចបង្កឱ្យកើតជាបក្ស ហើយអាចមានរឿងប្ដឹងគ្នាឡើងទៅដល់តុលាការក៏អាចមាន។ បើវាបញ្ចប់ត្រឹមនេះ គឺជាសំណាងល្អ ប៉ុន្តែជួនកាលស្ថានភាពបែបនេះ អាចនាំទៅរកការវាយប្រយុទ្ធគ្នា ដោយសង្គ្រាមពាក្យសំដី ឬដោយកំលាំងកាយ ជួនកាលមានទៅដល់ប្រើអាវុធទៀតផង ហើយវាប្រហែលជានឹងត្រូវបញ្ចប់ត្រឹមដេកនៅក្នុងមន្ទីរពេទ្យ ឬ ប៉ាឆា ឬក៏ក្នុងពន្ធនាគារ ជាដើម។

អ្វីដែលមិនអាចទាយទុកមុនបាន គឺចរិយាមារយាទមនុស្សលោក! កំហុសបន្តិចបន្តួច អាចជាហេតុនាំមកនូវជម្លោះរវាងសមាជិកគ្រួសារ ឬសង្គម ជួនកាលរវាង

មនុស្សក្នុងសង្គមធំទាំងមូល ហើយលើសពីនេះទៅទៀតនោះ គឺអាចជាជម្លោះរវាងជាតិសាសន៍ទៀតផង។ ដូច្នេះហើយបុគ្គលម្នាក់ៗ ត្រូវតែគិតរំពៃ និងមានសតិសម្បជញ្ញៈ រាល់ពេលវេលាក្រែងមានបញ្ហាទាំងនេះ កើតឡើងដោយថាហេតុ។ ប្រសិនបើមានបញ្ហានេះកើតឡើងមែននោះ បុគ្គលត្រូវតែដាក់វិធានការឱ្យបានឆាប់រហ័សដើម្បីរក្សាការពារ នូវសេចក្ដីសុខក្នុងគ្រួសារ។ ព្រះពុទ្ធបរមគ្រូជាម្ចាស់នៃយើងតែងតែរំលឹកដាស់តឿនយើងរាល់គ្នា កុំឱ្យមានអគតិធម៌ ពីព្រោះអគតិធម៌នេះឯងហើយ ដែលជាហេតុនាំមកនូវជម្លោះ។

ការអភិវឌ្ឍន៍ផ្នែកខាងសេដ្ឋកិច្ច ត្រូវតែមាន សម្រាប់សុភមង្គលក្នុងគ្រួសារ។ គ្រប់សមាជិកទាំងអស់ ត្រូវពិនិត្យមើលឱ្យបានហ្មត់ចត់ថា ទ្រព្យសម្បត្តិក្នុងគ្រួសារពិតជាមិនបានចំណាយ ខ្ជះខ្ជាយឥតប្រយោជន៍ ពីព្រោះកត្តានេះ គឺជាការទទួលខុសត្រូវទាំងស្រុង របស់សមាជិកគ្រប់រូបក្នុងគ្រួសារ ទោះបីអ្នកនោះជាអ្នករកក្ដី ឬមិនរកក្ដី។ មានបុគ្គលក្នុងគ្រួសារមួយចំនួន ដែលជាអ្នករកទ្រព្យសម្បត្តិ ហើយព្យាយាមបង្ហាញខ្លួនគេជាអ្នករក ទោះបីធ្វើអ្វី ចង់ចាយវាយយ៉ាងណា ក៏ស្រេចតែគេ គ្មាននរណាមានសិទ្ធិមករារាំងឡើយ ត្រង់ចំនុចនេះ បុគ្គលមិនគ្រាន់តែបង្ហាញភាពល្ងង់ខ្លៅរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្ហាញឱ្យឃើញ នូវការមិនទទួលខុសត្រូវចំពោះគ្រួសារទាំងមូលទៀតផង។ ទន្ទឹមជាមួយនឹងគ្នានេះដែរ ក៏មានប្រពន្ធមួយចំនួន បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ដែលប្ដីរកបានមកផងដែរ។ នៅក្នុងលក្ខណៈស្ត្រីទាំង ៧ ជំពូក ក្នុងនោះក៏មានចំនុចមួយដែរ ដែលនិយាយអំពី ភរិយាប្រៀបដូចជាចោរ ឬ

ចោរភរិយា។ មិនត្រឹមតែប៉ុណ្ណោះ ក៏មានកូនមួយចំនួនបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ឪពុកម្ដាយដោយការចាយវាយខ្ជះខ្ជាយ សេពគប់មិត្រអាក្រក់ ប្រព្រឹត្តអំពើអបាយមុខទាំងឡាយមានស្រី ស្រា ល្បែងពាលាជាដើមផងដែរ។ ឥទ្ធិពលទាំងនេះក៏អាចជាកត្តាមួយដែលធ្វើឱ្យកិត្តិយសគ្រួសារ បាត់បង់ហើយខ្លួនឯងជាអ្នកប្រព្រឹត្ត ក៏នឹងមានទោសផងដែរ។

# បញ្ចពលី

ការបំពេញនូវកាតព្វកិច្ច ឬ តួនាទីរបស់ខ្លួនជាគ្រហស្ថបានល្អអាចជួយសំរាលនូវបញ្ហាខ្លះៗមួយចំនួននៅក្នុងគ្រួសារ ក៏ដូចជានៅក្នុងសង្គម ហើយអាចធ្វើឱ្យអារម្មណ៍ធូរស្រាល និងធ្វើឱ្យជីវិតរបស់យើងមានលទ្ធភាពចូលរួមសប្បាយ នូវអ្វីដែលយើងមានផងដែរ។ តើអ្វីទៅហៅថា "**ពលី** " ហើយមានប៉ុន្មានយ៉ាង? ពាក្យថា"**ពលី**"នេះគឺជាភាសារបាលី ដែលមានអត្ថន័យថា"ការសង្គ្រោះ ឬ កាតព្វកិច្ច"ដែលបុគ្គលជាគ្រហស្ថគប្បីប្រតិបត្តិ ហើយពលីនេះមាន ៥ យ៉ាង។ ដូច្នេះផ្អែកទៅលើទ្រឹស្ដីព្រះពុទ្ធសាសនាជាមួយនឹង ទ្រព្យសម្បត្តិ ដែលខ្លួនរកបានមកដោយសម្មាអាជីវៈ បុគ្គលគប្បីបែងចែកបំពេញពលី ៥ យ៉ាងដូចតទៅ:

១-សង្គ្រោះញាតិ **ញាតិពលី**

២-ទទួលភ្ញៀវ **អតិថិពលី**

៣-ធ្វើបុណ្យឧទ្ទិសផល ជូនបុព្វការីជន ដែលបានធ្វើមរណៈកាលទៅកាន់លោកខាងមុខ **បុព្វេប្បេតពលី**

៤-បង់ពន្ធជូនរដ្ឋ ឬ រាជរដ្ឋាភិបាល ជាអ្នកគ្រប់គ្រងផែនដី **រដ្ឋ** ឬ **រាជពលី**

៥-ធ្វើបុណ្យឧទ្ទិសផល ជូនដល់ទេវតា អ្នករក្សាទឹកដី **ទេវតាពលី**

ទាំងនេះគឺជាភារកិច្ច ដែលបុគ្គលត្រូវបំពេញ ដើម្បីធ្វើជីវិតរបស់ខ្លួនឱ្យបានសប្បាយ បន្ទាប់មកទំនុកបំរុងប្រពន្ធកូន។ ប្រសិនបើបុគ្គលមិនមានគ្រួសារ ក៏មានឪពុកម្ដាយ បងប្អូន ដែលត្រូវជួយផងដែរ។ នៅពេលបុគ្គលបានបំពេញនូវកាតព្វកិច្ច

ទាំងអស់នេះហើយ ជាមួយនឹងទ្រព្យសម្បត្តិដែលខ្លួនរកបានមក ដោយសុចរិតត្រឹមត្រូវ បុគ្គលគប្បីធ្វើនូវពលី ៥ យ៉ាង ឬ **បញ្ចពលី**។

ជួយសង្គ្រោះញាតិរបស់ខ្លួន ដែលមានការលំបាកខ្វះខាត នូវគ្រឿងឧបភោគបរិភោគទាំងឡាយ គឺជាកាតព្វកិច្ចរបស់គ្រួសារល្អ។ ព្រះពុទ្ធទ្រង់បានសំដែងផងដែរថា បុគ្គលនៅពេលដែលខ្លួនមានទ្រព្យសម្បត្តិ លុយកាក់ បុណ្យសក្តិ មិនគប្បីបំភ្លេចចោលសាច់ញាតិក្រីក្ររបស់ខ្លួនឡើយ។ អ្នកខ្លះដែលមករកយើង គឺដោយហេតុភេទផ្សេងៗ ជួនកាលអ្នកខ្លះមករកដើម្បីឱ្យយើងជួយ ហើយជួនកាលអ្នកខ្លះទៀត គ្មាន ឬមានបំណងផ្សេងៗទៀត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទាំងនេះគឺជាកាតព្វកិច្ច និងភារកិច្ច របស់សប្បុរសបុគ្គល ដែលគប្បីជួយសង្គ្រោះញាតិរបស់ខ្លួនតាមលទ្ធភាព និងសមត្ថភាពរបស់ខ្លួន។ រាល់ការជ្រុំជ្រែង ទំនុកបំរុងទាំងអស់នេះ ចំពោះញាតិរបស់ខ្លួនគប្បីធ្វើឡើងនូវរបៀបយ៉ាងណា កុំឱ្យញាតិរបស់ខ្លួនមានអារម្មណ៍រង្កៀស ខ្លាចក្រែងចិត្តរបស់យើង។ ម្យ៉ាងវិញទៀត ទោះបីការជួយនោះជាសម្ភារៈក្តី ឬ ជាជំនួយខាងផ្លូវចិត្តក្តី គប្បីធ្វើឡើងតាមវិធីណាដែលពួកគេមានអារម្មណ៍ថា ពួកគេត្រូវបានទទួលរាក់ទាក់ ដោយយកចិត្តទុកដាក់ ដូចជាមនុស្សរួមគ្រួសារតែមួយ។

ភ្ញៀវ ឬ អ្នកមកលេង ប្រហែលជាញាតិមិត្រ ឬ អ្នកដទៃជាអ្នកមកសួរសុខទុក្ខ គួរតែទទួលរាក់ទាក់ឱ្យបានសមរម្យកក់ក្តៅ និងយកចិត្តទុកដាក់សមតាមកាលៈទេសៈ។ ប្រសិនបើភ្ញៀវមកលេងចំពេលបាយត្រូវអញ្ជើញឱ្យពិសារបាយជាមួយនឹងយើង។ ជាការណ៍ពិត ភ្ញៀវ គឺជាអ្នកនាំមកនូវកិត្តិយសគ្រួសារយើង ហើយក៏ជាអ្នកនាំ

រឿងអាក្រក់ពីគ្រួសារយើងទៅទីដទៃដែរ។ ដូច្នេះ យើងទាំងឡាយគប្បីទទួលរាក់ទាក់ភ្ញៀវ ដែលមកលេងផ្ទះយើងឱ្យបានល្អ ធ្វើបែបនេះគេនឹងនាំកិត្តិយសគ្រួសារយើងទៅផ្សាយក្នុងទីដទៃ។

បុគ្គលជាទីស្រឡាញ់ ជាទីគោរព ដែលបានធ្វើមរណៈកាលទៅកាន់លោកខាងមុខ ជាពិសេសគឺមាតាបិតា មិនត្រូវបំភ្លេចលោកឡើយ។ ព្រះពុទ្ធសាសនាបានបង្រៀនថា ការធ្វើបុណ្យកុសល ឧទ្ទិសផលជូនទៅដល់មាតាបិតា សាច់សាលោហិត គឺមានប្រយោជន៍ច្រើនណាស់ ដោយអាចជួយរំដោះនូវសេចក្ដីទុក្ខលំបាក របស់ពួកអ្នកទាំងនោះ ប្រសិនបើពួកគេមានវិបត្តិភ្លាត់សតិ ទៅកើតត្រង់ទីកន្លែងណា មិនសមរម្យ មានប្រេត នរក តិរច្ឆាន អសុរកាយ ជាដើម។ ការធ្វើបុណ្យឧទ្ទិសកុសលជូនចំពោះអ្នកដែលធ្វើមរណៈកាលទៅនោះ គឺជាប្រពៃណី ទំនៀមទំលាប់ក្នុងពុទ្ធសាសនាដ៏យូរណាស់មកហើយ។ ម្យ៉ាងវិញទៀតប្រពៃណីទំនៀមទំលាប់ និង កតញ្ញូតាធម៌នេះ គឺជាគុណជាតិដែលអាចជួយរិតចំណងសាមគ្គីភាពគ្រួសារ ឱ្យរឹងរិតតែមាំទ្វេឡើង។ ការបន្តធ្វើនូវប្រពៃណី ទំនៀមទំលាប់នេះ វាគឺជាកត្តាមួយដ៏សំខាន់ ដែលជះឥទ្ធិពលទៅលើមនុស្សជំនាន់ក្រោយ។ ទាំងនេះគឺជារង្វាន់ដួងចិត្ត ដ៏មហាប្រសើរ ចំពោះអ្នកដ៏មានគុណទាំងឡាយ ដែលបានធ្វើមរណៈកាលទៅកាន់លោកខាងមុខ ហើយក៏ជាការបង្ហាញឱ្យឃើញថា ពួកគេមានការអាឡោះអាល័យពីក្រុមគ្រួសារ សាច់ញាតិ ដែលកំពុងរស់នៅសព្វថ្ងៃ។

មនុស្សគ្រប់រូបក្នុងលោកនេះ មានតួនាទី និង ភារកិច្ចចំពោះសង្គម និង

ប្រទេសដែលខ្លួនរស់នៅ នេះគឺសំដៅទៅលើ **រាជ** ឬ **រដ្ឋពលី**។ បុគ្គលម្នាក់ៗ ត្រូវតែបំពេញតួនាទីរបស់ខ្លួន ក្នុងនាមខ្លួនជាប្រជាពលរដ្ឋល្អក្នុងសង្គម ឬ ប្រទេសនោះៗ ដោយបង់ពន្ធអាករទាំងឡាយ មានដូចជាថ្លៃទឹក ភ្លើង ភាសុី ប៉ាតង់ ជាដើម។ រាល់កាតព្វកិច្ចទាំងអស់ គប្បីបំពេញប្រសិនបើ បុគ្គលចង់បានសេចក្តីសុខ សន្តិភាព ខាងផ្លូវកាយ និងផ្លូវចិត្តក្នុងជីវិតសុភមង្គលរបស់ខ្លួន។

នៅពេលដែល កាតព្វកិច្ចទាំងអស់នោះ ត្រូវបានបំពេញរួចហើយ បុគ្គលមិនត្រូវបំភ្លេចចោល នូវតួនាទីមួយទៀតចំពោះ សាសនារបស់ខ្លួនឡើយ។ ការបំពេញកាតព្វកិច្ចជូនសាសនាខ្លួន អាចកាត់បន្ថយនូវសេចក្តីលោភពីខន្ធសន្តានផងដែរ ហើយក៏អាចនាំមកនូវសេចក្តីសុខក្នុងបច្ចុប្បន្នជាតិ និង អនាគតជាតិ។ មួយផ្នែកនៃទ្រព្យសម្បត្តិរបស់ខ្លួន ដែលរកបានមកដោយសុចរិតត្រឹមត្រូវ បុគ្គលគប្បីរក្សាទុក ដើម្បីធ្វើបុណ្យ ឬ ចំណាយទៅលើកិច្ចការផ្សេងៗក្នុងផ្លូវសាសនា។ ដើម្បីបំពេញកាតព្វកិច្ច ឬពលីទាំងនោះឱ្យបានល្អប្រសើរ បុគ្គលគប្បីចាត់ចែងគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារឱ្យបានហ្មត់ចត់។ លក្ខណៈនេះ បុគ្គលគប្បីដឹងប្រមាណក្នុងការចាយវាយ។ បុគ្គលប្រហែលជាមានអារម្មណ៍ថា ប្រាក់ចំណូលរបស់ខ្លួន មិនគ្រប់គ្រាន់ក្នុង ការបំពេញនូវតួនាទីទាំងអស់នោះទេ ប៉ុន្តែទាំងនោះគឺមិនមែនជាលេស ក្នុងការដោះសារ ដើម្បីគេចវេះពីការបំពេញនូវតួនាទីរបស់ខ្លួនឡើយ។ មនុស្សគ្រប់រូបក្នុងសង្គម គប្បីបំពេញ នូវតួនាទីទាំងអស់ឱ្យបានល្អ ប្រសិនបើមិនដូច្នេះទេ បុគ្គលមិនអាចមាន លទ្ធភាពដឹកនាំជីវិតសុភមង្គលរបស់ខ្លួនបានឡើយ។

# មិត្តភាពនិងសេចក្តីសុខ

ការសេពគប់មិត្ត គឺជាការសំខាន់ណាស់ សម្រាប់ជីវិតជ័យជំនះរបស់មនុស្ស។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសំដែងថា ក្នុងមួយជីវិតរបស់មនុស្សគប្បីជាជីវិតព្រហ្មចារីយ៍ ហើយជីវិតព្រហ្មចារីយ៍នេះ គឺជាជីវិតដែលកើតឡើងដោយភាពបរិសុទ្ធត្រឹមត្រូវ។ នៅត្រង់ចំណុចនេះ ព្រះអានន្ទ បានទូលសួរព្រះសម្មាសម្ពុទ្ធថា តើពាក់កណ្តាលនៃជីវិតព្រហ្មចារីយ៍ជាជីវិតត្រូវការមិត្តភាពឬ? ព្រះអង្គទ្រង់មានព្រះបន្ទូលថា ម្នាលអានន្ទ! មិនមែនត្រឹមតែពាក់កណ្តាលទេ គឺមួយជីវិតនេះតែម្តង គឺជាជីវិតមិត្តភាព។ ដូច្នេះហើយ បានជាការសេពគប់មិត្តល្អ ឬ កល្យាណមិត្ត ត្រូវបានជំរុញ និង លើកទឹកចិត្តនៅក្នុងពុទ្ធសាសនា។ ប៉ុន្តែវាមិនមែនជាការងាយឡើយ ក្នុងការស្វែងរកមិត្តល្អនោះ។ ដើម្បីកុំឱ្យមានការស្តាយក្រោយ បុគ្គលម្នាក់ៗត្រូវប្រយ័ត្ន មុនពេលនឹងសម្រេចចិត្តជ្រើសរើសយកបុគ្គលណាម្នាក់ មកធ្វើជាមិត្តរបស់ខ្លួន។ មានមិត្តមួយចំនួនគឺជាសត្រូវក្លែងបន្លំ ចូរប្រយ័ត្នចំពោះបុគ្គលប្រភេទនេះ ពីព្រោះពិបាកយល់ និង ចាប់កំហុសណាស់។ បុគ្គលមួយចំនួន ធ្វើជាមិត្តស្និតស្នាលនឹងយើង គឺគ្រាន់តែប្រាថ្នាចង់បានប្រយោជន៍ពីយើងប៉ុណ្ណោះ។ មានមិត្តមួយចំនួន ជាអ្នកពូកែខាងបញ្ជោរ ក្នុងគោលបំណងឱ្យយើងស្និតហោចៅតែប៉ុណ្ណោះ។ មានមិត្តមួយចំនួនទៀត ពូកែនិយាយសន្យាហើយថែមទាំងហ៊ានលះបង់ជីវិតរបស់គេ ដើម្បីអ្នកទៀតផង ប៉ុន្តែនៅពេលអ្នកមានអាសន្ន គេគេចចេញ រត់យកតែរូបខ្លួនយកលេសថា មានរវល់នេះ រវល់នោះ និយាយអំពីការជួយពេលអតីត ហើយសន្យាថានឹងជួយក្នុងពេលអនាគត ហើយការជួយរបស់

គេនោះ គឺបានត្រឹមតែពាក្យសម្ដីប៉ុណ្ណោះ។ មានមិត្តមួយប្រភេទទៀត តែងតែប្រាប់អ្នកឱ្យចេះសន្សំសំចៃ កុំចាយទ្រព្យខ្ជះខ្ជាយ ប៉ុន្តែ គេបង្ហាញអ្នកនូវផ្លូវទាំងឡាយ ដែលជាការខ្ជះខ្ជាយទ្រព្យ គេនាំអ្នកទៅកាន់កន្លែងកំសាន្ត បង្រៀនអ្នកឱ្យចេះលេងល្បែងស៊ីសង ល្បែងភ្នាល់ នាំអ្នកឱ្យចេះសេពនូវទឹកស្រវឹង និង គ្រឿងញៀនទាំងឡាយ។ លក្ខណៈមិត្តទាំងនោះ គឺគេមានគោលបំណងឱ្យអ្នកខាតបង់ ហើយនឹងដើម្បីប្រយោជន៍ផ្ទាល់ខ្លួនរបស់គេប៉ុណ្ណោះ ដូចមានគាថាមួយកន្លែងបានពោលថា:

**ភជន្តិ សេវន្តិ ច ការណត្ថា និក្ការណា ទុល្លភា**

**អជ្ជ មិត្តា អត្តដ្ឋបញ្ញា អសុចី មនុស្សា ឯកោ ចរេ**

**ខគ្គវិសាណកប្បោ.តិ**[១]។

ពួកមនុស្សមានប្រយោជន៍ជាហេតុ ទើបគប់រកផង បំរើផង ពួកមិត្រសំឡាញ់ទាំងឡាយ ដែលឥតហេតុរកបានដោយកម្រ សព្វថ្ងៃនេះ ពួកមនុស្ស(ច្រើនតែ) មានប្រាជ្ញាចំពោះតែប្រយោជន៍របស់ខ្លួន ជាអ្នកប្រកបដោយអំពើមិនស្អាត បុគ្គលគប្បីត្រាច់ចរទៅ តែម្នាក់ឯងដូចកុយរមាស។

"True friend are rare to come by these days, a show of friendship very often hides some private ends. Man's mind is defiled by self-interest. So becoming disillusioned, raom alone like a rhinoceros"[1]

រាល់មិត្រប្រភេទនេះ គឺពិតជាសត្រូវក្លែងបន្លំ បុគ្គលអ្នកចង់ដឹកនាំជីវិតសុភមង្គលរបស់ខ្លួនទាំងឡាយ គប្បីប្រយ័ត្នប្រយ៉ែងឱ្យមែនទែន ចំពោះបញ្ហាទាំងនេះ

---

[១] ខគ្គវិសាណសូត្រ-សុត្តនិបាត ៩៥៤(១៣)

[1] Khaggavisana Sutta, (Stanza-75) P25. Sutta Nipata. Text and translation by N A J

ពីព្រោះបុគ្គលជំពូកនេះ មានល្បិចច្រើនណាស់ ក្នុងការធ្វើឱ្យអ្នកមានអារម្មណ៍ ជឿទុកចិត្តថាពួកគេស្មោះត្រង់ចំពោះអ្នក។ ប៉ុន្តែ ពិភពលោកមិនអត់ទេ កល្យាណមិត្តនោះ ការមានមិត្តដែលជាកល្យាណមិត្ត គឺជាសុភមង្គលដ៏ឧត្តម។ កល្យាណមិត្ត គឺជាទីពឹងពំនាក់របស់អ្នកបាន គេតែងតែជួយមើលការខុសត្រូវ និង យកចិត្តទុកដាក់មិត្ត នៅពេលណាមួយមិត្តរបស់គេមិននៅ គេជួយសង្គ្រោះមិត្តរបស់គេទាំងផ្លូវស្មារតី និង សម្ភារៈ នៅពេលមិត្តមានគ្រោះអាសន្ន។ មិត្តស្មោះត្រង់នឹងជឿទុកចិត្តអ្នក ហើយអ្នកក៏ជឿទុកចិត្តស្មោះត្រង់ចំពោះគេវិញដែរ។ កល្យាណមិត្ត តែងតែណែនាំអ្នកឱ្យវៀរចាកអំពើអាក្រក់ ហើយឱ្យតាំងនៅក្នុងសេចក្ដីល្អ ជួយអ្នកឱ្យមានចំណេះដឹងទូលំទូលាយ។ កល្យាណមិត្ត មានចិត្តសំដែងនូវសមានទុក្ខ ពេលឃើញមិត្តរបស់ខ្លួនមានវិបត្តិសប្បាយរីករាយសាទរ ពេលឃើញមិត្រមានជ័យជំនះ។ កល្យាណមិត្ត មិនដែលនិយាយអាក្រក់ពីមិត្ត ឬ អនុញ្ញាតឱ្យអ្នកដទៃនិយាយអាក្រក់ពីមិត្តខ្លួនឡើយ។ កល្យាណមិត្តពិតជាប្រភពនាំមកនូវសេចក្ដីសុខ សេចក្ដីចំរើន និង សុភមង្គលដល់មិត្ត របស់គេ និង មនុស្សទូទៅ។

ព្រះពុទ្ធសាសនាបានផ្ដល់នូវទស្សនវិជ្ជា សេដ្ឋកិច្ចដែលអាចអនុវត្តបាន ក្នុងការធានានូវសុវត្ថិភាព សន្តិចិត្ត និង សេចក្ដីសុខរបស់មនុស្សគ្រប់រូបក្នុងជីវិតបច្ចុប្បន្ន។ នៅពេលដែលពន្យល់នូវរបៀបធ្វើយ៉ាងណា ឱ្យបុគ្គលរករបរទទួលទានសមស្របទៅតាមសម្មាអាជីវៈ (គឺការចិញ្ចឹមជីវិតត្រូវ) ព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែង ទូន្មានដល់មនុស្សទាំងឡាយ ឱ្យជៀសវាងការខ្ជះខ្ជាយទ្រព្យសម្បត្តិ ដោយឥតប្រយោជន៍។

លើសពីនេះទៅទៀត ព្រះអង្គបានបង្ហាត់បង្រៀននូវរបៀបថែរក្សាទ្រព្យឱ្យរួចអំពីការបាត់បង់ ដោយឧប្បត្តិហេតុផ្សេងៗដូចជាភ្លើងឆេះ ទឹកជំនន់លិច ចោរលួច ឬប្លន់ ។ល។ កត្តាទាំងប៉ុន្មានខាងលើ សុទ្ធតែជាពន្លឺដល់មនុស្សទាំងឡាយយកទៅអនុវត្ត ដើម្បីសម្រាប់ជាប្រយោជន៍ និង សេចក្តីសុខដល់បុគ្គលក្នុងពេលបច្ចុប្បន្ន និង អនាគត ។

# សេចក្តីសុខគឺបុគ្គលខ្លួនឯងជាអ្នកសាង

សេចក្តីសុខ គឺមិនមែនជារង្វាន់ដែលព្រះអាទិទេពផ្តល់ឡើយ តែវាគឺជាសភាវៈដែលបុគ្គលខ្លួនឯងជាអ្នកបង្កើត។ វាមិនអាស្រ័យលើចំនួននៃទ្រព្យសម្បត្តិ មាសប្រាក់ លុយកាក់ របស់របរមានតំលៃផ្សេងៗ ដែលខ្លួនមានទាំងស្រុងនោះឡើយ។ ទ្រព្យសម្បត្តិទាំងនោះ គឺជាហេតុអាចនាំមកនូវសេចក្តីសុខ និង ទុក្ខទាំងពីរយ៉ាង។ ជាទូទៅ សេចក្តីសុខ គឺវាអាស្រ័យទៅលើមាគ៌ា ដែលបុគ្គលរស់នៅ ហើយមាគ៌ានេះ ត្រូវតែបានបណ្តុះផ្សាំ អប់រំជាប្រចាំដោយមានសតិសម្បជញ្ញៈរឭកខ្ពស់។ យើងមិនគួរឱ្យសេចក្តីសុខប្រហាក់ប្រហែលដឹកនាំយើងឡើយ។

នេះគឺជាកំហុសដែលមនុស្សមួយភាគធំបានប្រព្រឹត្ត យើងតែងតែរត់ប្រដេញតាមពីក្រោយសម្ភារៈ នឹកគិតថា សម្ភារៈទាំងនោះ នឹងអាចជួយ ផ្តល់បន្ថែមនូវសេចក្តីសុខដល់យើង ប៉ុន្តែការណ៍ពិតគឺមិនដូច្នេះឡើយ ។ដោយការរត់ប្រដេញតាមសេចក្តីសុខក្លែងក្លាយនេះឯងហើយ យើងឃ្លាងនូវវត្ថុ និង ព្រឹត្តិការណ៍ជាច្រើនដែលអាចផ្តល់នូវសេចក្តីសុខពិតដល់យើង។ ដូច្នេះ យើងត្រូវតែពិនិត្យចំណាំឱ្យបានច្បាស់លាស់ ត្រឹមត្រូវនូវអ្វី ដែលពិតជាផ្តល់ឱ្យយើងនូវជម្រៅនៃសេចក្តីសុខផ្លូវចិត្ត ហើយពោរពេញទៅដោយភាពពេញចិត្តអារម្មណ៍ ធ្វើឱ្យធូរស្រាលនូវភាពតានតឹងក្នុងខួរក្បាល។

ត្រង់នេះ គឺកន្លែងដែលព្រះពុទ្ធសាសនា បានផ្តល់ឱ្យនូវខ្សែបន្ទាត់ដ៏ត្រឹមត្រូវពិតប្រាកដមួយ។ វាបានបង្ហាញអ្នកឱ្យដឹងច្បាស់ រវាងសេចក្តីសុខក្លែងក្លាយ និង សេចក្តីសុខពិត ព្រោះព្រះពុទ្ធសាសនា បានពន្យល់នូវរបៀបនៃការទទួលបាននូវសេចក្តី

សុខសប្បាយសមរម្យជាមួយទ្រព្យសម្បត្តិ ដែលបុគ្គលមាន។ ដោយការអនុម័តយក និង ប្រតិបត្តិតាមដំបូន្មានដែលផ្តល់ឱ្យដោយព្រះសម្មាសម្ពុទ្ធ នៅក្នុងព្រះសូត្រ ដូចជា **មង្គលសូត្រ បរាភវសូត្រ វសលសូត្រ មេត្តសូត្រ សិង្គាលកសូត្រ** ដោយយកចិត្តទុកដាក់ បុគ្គលអាចធ្វើជីវិតរបស់ខ្លួន ប្រាសចាកជម្លោះ ខ្វែងគំនិត ក្តីបារម្ភហើយពោរពេញទៅដោយ ការសប្បាយរីករាយ និង សេចក្តីសុខសុភមង្គល។ បុគ្គលមិនគប្បីគិតថា សេចក្តីសុខ គឺជាអ្វីដែលគ្រាន់តែផុសចេញឡើងមួយរំពេចមានទំនាក់ទំនងជាមួយនឹងឧបទ្ទវហេតុអ្វីមួយ ហើយបាត់បង់ទៅវិញនោះទេ។ សេចក្តីសុខពិតនោះ គឺជាអារម្មណ៍ដែលរួចចាកទុក្ខកង្វល់ ហើយពោរពេញទៅដោយការសប្បាយរីករាយចិត្ត ត្រជាក់ចិត្ត ស្ងប់ស្ងាត់ ប្រាសចាកក្តីបារម្ភផ្សេងៗ។ លក្ខណៈនេះ វាគឺប្រហាក់ប្រហែលនឹងអ្វីដែលរាងកាយបានទទួល រាងកាយមានអារម្មណ៍ នៅពេលដែលយើងអង្គុយ កំសាន្តក្នុងរាត្រីកាលក្រោមពន្លឺរស្មីនៃដួងព្រះច័ន្ទដ៏ត្រជាក់ស្រទន់ ជាមួយនឹងខ្យល់ជំនោរបក់ត្រសៀកៗ ដែលបបោសអង្អែលនូវរាងកាយ និងធ្វើអារម្មណ៍របស់យើងឱ្យលង់លក់។ ប្រសិនបើសភាវៈផ្លូវចិត្តបែបនេះបានកើតឡើងយើងដឹងថា នេះគឺពិតជាសេចក្តីសុខ ដែលខ្លួនយើងជាអ្នកសាង។

# និព្វានគឺជាសេចក្តីសុខដ៏ឧត្តម

ព្រះនិព្វានគឺជាសេចក្តីសុខដ៏ឧត្តម **និព្វានំ បរមំ សុខំ**។ ព្រះនិព្វាន គឺជាគោលដៅតែមួយគត់របស់ព្រះពុទ្ធសាសនា។ មានបុគ្គលមួយចំនួនបានគិតថា និព្វានគឺជាកន្លែងដែលពោរពេញទៅដោយសេចក្តីសុខគ្រប់យ៉ាង។ ជាការណ៍ពិត ការគិតយ៉ាងនេះគឺមិនខុសទាំងស្រុងទេ ប្រសិនបើយើងពិនិត្យមើលអត្ថន័យថា "**បរមំ សុខំ**"។ ប៉ុន្តែ ត្រង់ចំណុចនេះ មិនមែនមានន័យថា **និព្វាន** គឺជាកន្លែងដែលពោរពេញទៅដោយលោកីយ៍សុខ ដែលមានបែបផែនផ្សេងៗឡើយ។ ដើម្បីធ្វើឱ្យមានការយល់កាន់តែច្បាស់ថែមទៀតអំពីសេចក្តីសុខ នៃព្រះនិព្វានបុគ្គលគប្បីចងចាំថា សេចក្តីសុខនៃព្រះនិព្វាន គឺមិនសំដៅយក"**វេទនា**" ឬ អារម្មណ៍ឡើយ។ ប្រសិនបើវាជាប់ទាក់ទងទៅនឹងអារម្មណ៍ គឺវាដឹកនាំទៅរកតណ្ហា។ ប៉ុន្តែ និព្វានគឺជាការអស់ទៅនៃតណ្ហា ដូច្នេះហើយបានជាសេចក្តីសុខដែលជាផលនៃការសម្រេច ព្រះនិព្វានត្រូវបានហៅថា"**អវេទយិតសុខ**"គឺសេចក្តីសុខដែលមិនប្រកបដោយវេទនា។ ម្យ៉ាងវិញទៀត និព្វានអាចហៅបានថា"**អន្តោទុក្ខស្ស**"ការបញ្ចប់ទៅនៃទុក្ខ។ អ្វីដែលផ្ទុយនឹងទុក្ខគឺសុខ ប៉ុន្តែ សុខនេះមិនមែនជាសុខដែលកើតអំពីកាមតណ្ហាឡើយ ។ព្រះពុទ្ធសាសនាទទួលស្គាល់ផ្លូវកណ្តាល (**មជ្ឈិមាបដិបទា**) ហើយបដិសេធ (**កាមសុខល្លិកានុយោគ**) ដែលជាផ្លូវពោរពេញទៅដោយកាមតណ្ហា។ ព្រះពុទ្ធសាសនា ក៏បានពន្យល់ថែមទៀតថា ទាំងនេះគឺជាផ្លូវដែលជាប់ជំពាក់ក្នុងកាមទាំងឡាយជាធម៌ថោកទាប ជាធម៌របស់អ្នកស្រុក ជាធម៌របស់បុថុជ្ជន មិនមែនជាធម៌របស់អរិយបុគ្គល ជាធម៌មិនប្រកបដោយប្រយោជន៍។

ដូច្នេះត្រង់ចំណុចនេះ យើងឃើញថា និព្វានគឺមិនជាប់ជំពាក់ជាមួយនឹងតណ្ហា ឬ កាមតណ្ហាអ្វីទាំងអស់។ តាមទស្សនៈព្រះពុទ្ធសាសនា សេចក្តីសុខដែលកើតមកពីចំណង់តណ្ហា មិនអាចដឹកនាំបុគ្គលទៅរកសេចក្តីសុខក្នុងឋានសុខពិតឡើយ។ កុំថាឡើយសេចក្តីសុខក្នុងលោកិយ៍ សូម្បីតែសេចក្តីសុខក្នុងឋានសួគ៌ ក៏មិនអាចប្រៀបផ្ទឹមនឹងសេចក្តីសុខនៃព្រះនិព្វានបានឡើយ ពីព្រោះសេចក្តីសុខក្នុងទេវលោក ក៏នៅតែប្រែប្រួល មិនទៀងទាត់ មិនឋិតថេរដែរ។

ព្រះនិព្វានគឺជាសេចក្តីសុខដ៏ឧត្តម ពីព្រោះវាបញ្ចប់ទៅនូវសេចក្តីទុក្ខទាំងពួង (**ភវនិរោធ**) បញ្ចប់ទៅនៃការកើតស្លាប់ (**ជាតិមរណស្ស អន្តំ**)[១]។ ការរស់នៅ កើត ចាស់ ឈឺ ស្លាប់ របស់សត្វលោកទាំងឡាយ ត្រូវបានដុតកំដៅដោយភ្លើង **រាគៈ ទោសៈ និង មោហៈ** (**សព្វំ អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ**)[២]។ ប៉ុន្តែ ជាមួយនឹងការយល់ច្បាស់ សម្រេចបានព្រះនិព្វាន ភ្លើងទាំងអស់នោះ គឺត្រូវបានរំលត់។ ពីព្រោះដោយសារ គ្មានការឆេះ ឬ ដុតកំដៅ គ្មានព្យាធិ គ្មានសេចក្តីសោកសៅ ដូច្នេះហើយ **និព្វាន** គឺជាសេចក្តីសុខដ៏ឧត្តម "**បរមំ សុខំ**" ពីព្រោះនិព្វាន គឺជាការបង់ទៅនូវទុក្ខ "**អន្តោ ទុក្ខស្ស**" សុខប្រាសចាកវេទនារម្មណ៍ **អវេទយិតសុខ**។

---

១-សុត្តនិបាត

២-សំយុត្តនិកាយ

# សេចក្តីសន្និដ្ឋាន

ដូចដែលបានរៀបរាប់មកពីខាងដើមហើយថា សេចក្តីសុខគឺជាការពិសោធន៍ ដ៏ស្មុគ្រស្មាញ។ វាមានកម្រិត និង មូលហេតុខុសៗគ្នា។ បើយើងទុកសេចក្តីសុខ ដ៏ឧត្តម (**និព្វាន**) ដែលជាគោលដៅធំបំផុតរបស់ព្រះពុទ្ធសាសនាមួយឡែកសិន យើងអាច សន្និដ្ឋានបានថា មនុស្សបុថុជ្ជន គឺចង់បាន ចង់ស្គាល់រស់ជាតិលោកីយ៍សុខណាស់។ បុថុជ្ជន មិនត្រឹមតែចង់បានលោកីយ៍សុខ ឬ កាមសុខប៉ុណ្ណោះទេ គេថែមទាំង ស្អប់ខ្ពើមជៀសវាង មិនចង់បានសេចក្តីទុក្ខ(**ទុក្ខបដិក្កូល**)ទៀតផង។ នេះគឺជា លក្ខណៈធម្មជាតិរបស់បុថុជ្ជន ជាគិហិកាមភោគីបុគ្គល។ ជាមួយនឹងការស្វែងរក សេចក្តីសុខរបស់ពួកគេ ព្រះពុទ្ធអង្គបានដាក់ចុះនូវច្បាប់សំរាប់គ្រហស្ថគោរពប្រតិបត្តិ ប្រសិនបើបុគ្គលពិតជាប្រាថ្នាចង់បាន នូវសេចក្តីសុខពិតប្រាកដមែននោះ។

ការចង្អុលបង្ហាញរួចមកហើយនេះ សបញ្ជាក់ឱ្យឃើញថា ព្រះសម្មាសម្ពុទ្ធ បរមគ្រូ ព្រះអង្គទ្រង់បានដឹងយ៉ាងច្បាស់នូវប្រភេទនៃសេចក្តីសុខ ដែលមនុស្សបុថុជ្ជន ប្រាថ្នាចង់បានរត់ប្រដេញតាមពីក្រោយ។ ទន្ទឹមជាមួយនឹងគ្នានេះដែរព្រះអង្គក៏បានបង្ហាញ ផ្លូវ ឬ មធ្យោបាយធ្វើយ៉ាងណាឱ្យបានសំរេច នូវសេចក្តីសុខនោះដល់ខ្លួន។ ម្យ៉ាងវិញ ទៀត ព្រះអង្គក៏ទ្រង់បានចង្អុលបង្ហាញ និង វិភាគអំពីឧបសគ្គទាំងឡាយ ដែលឈរ ស្ទាក់ពីមុខបុគ្គលគ្រប់រូបក្នុងការស្វែងរកនូវសេចក្តីសុខនោះផងដែរ។ ហើយប្រសិនបើ បុគ្គលប្រាថ្នាចង់បាននូវសេចក្តីសុខប្រភេទនោះ ពិតប្រាកដមែននោះ បុគ្គលគប្បីមាន សតិសម្បជញ្ញៈ រលឹកជាប់ជានិច្ចនូវគ្រោះថ្នាក់ និង ឧបសគ្គទាំងនោះ។

ក្នុងចំណោមកត្តាទាំងឡាយ ដែលនាំមកនូវសេចក្តីសុខគឺមាន **សន្តុដ្ឋិ** ដែលជាសេចក្តីសុខ មិនអាស្រ័យទៅលើចំនួន ទ្រព្យសម្បត្តិតែម្យ៉ាង។ ដូច្នេះហើយបានជាមានស័ព្ទបាលីមួយកន្លែងបានពោលថា"**សន្តុដ្ឋី បរមំ សុខំ**"មានន័យថា សេចក្តីសន្តោសគឺជាសេចក្តីសុខដ៏ឧត្តម។

កត្តាមួយទៀតគឺ ធម្ម ដែលជាការចិញ្ចឹមជីវិតត្រូវ " **សម្មាអាជីវ** " ការវៀរចាកនូវ "**មិច្ឆាអាជីវ**"គឺការចិញ្ចឹមជីវិតខុស និង អំពើអាក្រក់ផ្សេងៗ។ ជួនកាលបុគ្គលទទួលបាននូវសេចក្តីសុខ តាមមធ្យោបាយអាក្រក់ តែសេចក្តីសុខប្រភេទនោះមិនអាច ឋិតថេរយូរឡើយ សេចក្តីសុខនេះ នឹងក្លាយទៅជាសេចក្តីទុក្ខវិញមិនខាន។ បុគ្គលស្វែងរកសេចក្តីសុខ តាមមធ្យោបាយអាក្រក់ គ្មានសេចក្តីស្ងប់ខាងផ្លូវចិត្តឡើយ ការភ័យខ្លាច ការព្រួយបារម្ភ តែងតែជាប់តាមបុគ្គលនោះជានិច្ច ប្រៀបបីដូចជាស្រមោលអន្ទោលតាមប្រាណអញ្ចឹង។ បុគ្គលប្រភេទនោះប្រៀបបាននឹង សត្វក្តាមសប្បាយក្នុងទឹកឆ្នាំងលើចង្ក្រាន ដែលគេបំរុងនឹងដាំដូច្នេះឯង។ សេចក្តីសុខនេះនឹងក្លាយទៅជាសេចក្តីទុក្ខវិញយ៉ាងឆាប់រហ័ស។ ដូច្នេះ សេចក្តីសុខដែលប្រកបដោយគុណធមិ ទើបជាមធ្យោបាយដ៏ល្អតែមួយគត់ ដែលធ្វើឱ្យយើងសប្បាយរីករាយ និងឋិតថេរបានយូរអង្វែង។

# សិង្គាលកសូត្រ

ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវន ជាកន្ទកនិវាសនស្ថាន ជិតក្រុងរាជគ្រឹះ។ សម័យនោះឯង កូនគហបតីឈ្មោះសិង្គាលកៈ ក្រោកឡើងអំពីព្រឹក មានសំពត់ស្បៀកដណ្តប់ទទឹក នឹងសក់ទទឹកចេញពីក្រុងរាជគ្រឹះ ប្រណ្យអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូងខាងលិច ខាងជើង ខាងក្រោម និង ទិសខាងលើ។

លំដាប់នោះឯង ព្រះមានព្រះភាគ ស្តេចទ្រង់ស្បង់នឹងបាត្រ ចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចទ្រង់ចូលទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត។ ព្រះមានព្រះភាគទ្រង់ទតឃើញ សិង្គាលកគហបតិបុត្រ ក្រោកអំពីព្រលឹម មានសំពត់ស្បៀកដណ្តប់ទទឹក និងសក់ទទឹកចេញពីក្រុងរាជគ្រឹះ កំពុងផ្គងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងខាងលើ លុះទ្រង់ឃើញហើយ ទើបទ្រង់ត្រាស់សួរសិង្គាលកគហបតិបុត្តដូច្នេះថា នែគហបតិបុត្ត ហេតុអ្វីទើបអ្នកក្រោកអំពីព្រឹក មានសំពត់ស្បៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលីថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត.....ទិសខាងលើ។ សិង្គាលកគហបតិបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលព្រះបិតារបស់ខ្ញុំព្រះអង្គជិតនឹងធ្វើមរណភាព បានផ្តាំនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ហៃបា អ្នកត្រូវតែថ្វាយបង្គំទិសទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះធ្វើសក្ការៈគោរពរាប់អានបូជានូវពាក្យរបស់បិតា បានជាក្រោកអំពីព្រឹក មានសំពត់ស្បៀកដណ្តប់ទទឹក និងសក់

